# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# អនុប្បទាន និងការរំលត់សិទ្ធិលើបំណុល

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ឆួយ ម៉េងលាង**

លោក **ស៊ុម កុសល**

ណែនាំដោយ

លោក **ខាត់ ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឆូយ ម៉េងលាង** និង **ស៊ុម កុសល** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ឆ្នាំទី៤ ជំនាន់ទី២៣ ឆ្នាំសិក្សា២០១៩-២០២៣ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**។

**យើងខ្ញុំសូមលំឱនកាយវាចាចិត្តសម្តែងនូវគារវកិច្ច**
**ព្រមទាំងការដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ**

លោកឪពុក **អៀវ ចាន់ថាត** និងអ្នកម្តាយ **ហ៊ាន់ គឹមលុច** ព្រមទាំង លោកឪពុក **ស៊ួន ស៊ុម** និងអ្នកម្តាយឈ្មោះ **នោគ ហ៊ឹម** ។ កូនទាំងពីរសុំការអនុញ្ញាតសម្តែងនូវការដឹងគុណចំពោះគុណូបការៈដ៏ធំធេងបំផុតមិនអាចកាត់ថ្លៃបានរបស់លោកឪពុកអ្នកម្តាយដែលបានផ្តល់កំណើតដល់រូបកូន ចិញ្ចឹមបីបាច់ថែរក្សាពីបាតជើងក្រហមរហូតមកដល់ខ្លួនធំពេញវ័យ តែងតែអប់រំទូន្មានប្រៀនប្រដៅឱ្យកូនប្រកបដោយព្រហ្មវិហារធម៌ និងប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីផ្តល់ឱ្យកូននូវសុភមង្គល ភាពកក់ក្តៅ ក៏ដូចជាការទំនុកបម្រុងដើម្បីអនាគតកូនតាំងពីពេលឃើញពន្លឺថ្ងៃដំបូងរហូតដល់កូនៗបានចូលរៀនតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រដែលមានជំនាញដែលកូនស្រឡាញ់ និងស្រមៃនៅមហាវិទ្យាល័យដែលនៅឆ្ងាយពីផ្ទះ។

**ក្រសួងអប់រំ យុវជន និងកីឡា**, **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**, **ឯកឧត្តមសាកលវិទ្យាធិការ**, សាកលវិទ្យាធិការរង, ព្រឹទ្ធបុរស/ព្រឹទ្ធបុរសរង, លោក/លោកស្រីសាស្ត្រាចារ្យ, បុគ្គលិកនៃសាកលវិទ្យាល័យទាំងអស់, រាមច្បង និងមិត្តនិស្សិតគ្រប់ជំនាន់ដែលបានផ្តល់ទីកន្លែងអប់រំ និងបង្ហាត់បង្រៀនចំណេះដឹងដល់យើងខ្ញុំទាំងពីរជាច្រើនកន្លងមកតាំងពីឆ្នាំទី១ រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រនេះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរគ្មានអ្វីតបស្នងក្រៅពីបាតដៃទាំងទ្វេសម្តែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងសូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ និងបួងសួងដល់វត្ថុស័ក្តសិទ្ធិក្នុងអាណាចក្រខ្មែរ សូមជួយតាមថែរក្សាដល់អ្នកមានគុណទាំងបួន, លោក **ខាត់ ធី**, ឯកឧត្តមវិទ្យាធិការ វិទ្យាធិការរង, ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង, លោក/លោកស្រីសាស្ត្រចារ្យ, រួមទាំងសិស្សច្បងឱ្យទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំឈ្មោះ **ឆួយ ម៉េងលាង** និង **ស៊ុម កុសល** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ឆ្នាំទី៤ ជំនាន់ទី**២៣** ឆ្នាំសិក្សា**២០១៩-២០២៣** នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** សូមស្វាគមន៍យ៉ាងកក់ក្ដៅដល់មិត្តអ្នកអាន អ្នកស្រាវជ្រាវ អ្នកស្រឡាញ់ការសិក្សា ជាពិសេសអស់លោក/លោកស្រីសាស្ត្រាចារ្យជាទីគោរពដែលចូលមកអាន និងសិក្សាស្វែងយល់បន្ថែមពីសៀវភៅសារណានេះ។ អស់រយៈកាល៤ឆ្នាំកន្លងមកនេះ ក្នុងនាមជានិស្សិតនីតិសាស្ត្រ យើងទាំងពីរមានការខិតខំប្រឹងប្រែងប្រកបដោយការយកចិត្តទុកដាក់ក្រេបជញ្ជក់យកចំណេះដឹង ការផ្ដល់ដំបូន្មាន និងការអប់រំអំពីគុណធម៌ ព្រមទាំងសីលធម៌ រួមបញ្ចូលទាំងការចែករំលែកបទពិសោធន៍ជាច្រើនក្រៃលែងពីលោក/លោកស្រីសាស្ត្រាចារ្យគ្រប់មុខវិជ្ជា។

ជាលទ្ធផលដោយសារតែការខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ និងមានការជ្រោមជ្រែង ទាំងអស់នេះហើយធ្វើឱ្យយើងខ្ញុំមានឱកាសក្នុងការបង្ហាញស្នាដៃតាមរយៈការសិក្សាស្រាវជ្រាវ និងសរសេរចងក្រងជាសារណាមួយនេះលេចចេញជារូបរាងឡើង ដែលជាចំណាងដៃនៅក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់យើងខ្ញុំ។ អត្ថបទ "**អនុប្បទាន និងការរំលត់សិទ្ធិលើបំណុល**" ជាប្រធានបទមួយដ៏សំខាន់ដែលស្ទើរតែមាននៅគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា ដោយហេតុថាសកម្មភាពគតិយុត្តគ្រប់ប្រភេទដែលតែងតែកើតមានឡើងវាបង្កើតបានជាសិទ្ធិ និងកាតព្វកិច្ចនៅពេលនោះផងដែរ។ ហេតុដូច្នេះ ដើម្បីឱ្យមានភាពច្បាស់លាស់ត្រឹមត្រូវតាមផ្លូវច្បាប់ យើងខ្ញុំសូមជូនវិភាគទានដ៏សំខាន់នៅក្នុងការចូលរួមបំភ្លឺដល់ភាពស្រពិចស្រពិលនូវចំណុចសំខាន់ៗដែលទាក់ទងនឹងមូលហេតុនៃអនុប្បទាន និងការរំលត់សិទ្ធិលើបំណុល ដោយសារតែកន្លងមកពុំទាន់មានឯកសារ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនោះទេ ដូចនេះយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះនឹងអាចជួយចែករំលែកនូវចំណេះដឹង ថែមទាំងទុកជាឯកសារមួយសម្រាប់ផ្ដល់ជូនចំពោះអ្នកដែលចង់ចេះចង់ដឹង រួមទាំងមានចំណាប់អារម្មណ៍ធ្វើការសិក្សាស្រាវជ្រាវបន្ថែមអំពីអនុប្បទាន និងការរំលត់សិទ្ធិលើបំណុល នេះថាតើវាមានរបបគតិយុត្តប្រព្រឹត្តទៅយ៉ាងដូចម្ដេច? អ្វីដែលកាន់តែពិសេសជាងនេះទៅទៀតនោះ សារណាមួយនេះក៏ជា ឯកសារមួយយ៉ាងសំខាន់សម្រាប់បម្រើដល់បងប្អូនមិត្តនិស្សិតទាំងឡាយណាដែលចង់ធ្វើការ សិក្សាស្រាវជ្រាវអំពីបញ្ហានានាដែលពាក់ព័ន្ធនឹងសារណាមួយនេះដើម្បីទុកជាទុនមួយ និងជាឯកសារជំនួយស្មារតី ព្រមទាំងបំពេញសេចក្ដីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវដែលកំពុងតែជួបប្រទះនូវកង្វះខាតនាពេលបច្ចុប្បន្ននេះ។

ស្របជាមួយគ្នានេះដែរ យើងខ្ញុំសូមឱនកាយអភ័យទោសទុកជាមុននូវរាល់កង្វះខាតខ្លឹមសារទាំងឡាយ និងកំហុសឆ្គងអក្ខរាវិរុទ្ធដោយអចេតនាណាមួយនៅក្នុងសារណាមួយនេះ យើងខ្ញុំនឹងរង់ចាំទទួលការរិះគន់ដើម្បីស្ដាបនាពីសំណាក់អ្នកសិក្សាស្រាវជ្រាវ មិត្តអ្នកអាន ក៏ដូចជាបងប្អូនមិត្តនិស្សិតទាំងអស់គ្នាគ្រប់វិនាទី។

ជាសេចក្ដីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោក/លោកស្រី សាស្ត្រាចារ្យ សិស្សនិស្សិត បងប្អូនមិត្តអ្នកអានទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងយកចិត្តទុកដាក់ក្នុងការអានអត្ថបទសារណារបស់យើងខ្ញុំ។ យើងខ្ញុំសូមជូនពរឱ្យទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច ពោរពេញទៅដោយក្ដីស្រលាញ់ មានតែស្នាមញញឹម និងសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


**១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ** ........ ១

**២. ចំណោទបញ្ហា** ........ ២

**៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ** ........ ២

**៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ** ........ ២

**៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ** ........ ៣

**៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ** ........ ៣

**៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ** ........ ៤


## ជំពូកទី១

## សាវតានៃកាតព្វកិច្ច


**ផ្នែកទី១. ប្រភពនៃកាតព្វកិច្ច** ........ ៥

កថាភាគទី១. កាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ........ ៥

១.១. កិច្ចសន្យា ........ ៥

១.២. សកម្មភាពឯកតោភាគី ........ ៦

កថាភាគទី២. កាតព្វកិច្ចដែលកំណត់ដោយច្បាប់ ........ ៦

២.១. ការគ្រប់គ្រងដោយឈឺឆ្អាល ........ ៧

២.២. សេចក្តីចម្រើនដោយឥតហេតុ ........ ៨

២.៣. អំពើអនីត្យានុកូល ........ ៩

**ផ្នែកទី២. ប្រភេទនៃកាតព្វកិច្ច** ........ ១០

កថាភាគទី១. កាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើសកម្មភាព ........ ១០

១.១. កាតព្វកិច្ចផ្ទេរ ...................................................................................................១០

១.២. កាតព្វកិច្ចឱ្យធ្វើសកម្មភាព.........................................................................................១១

កថាភាគទី២. កាតព្វកិច្ចដែលមានគោលបំណងមិនឱ្យធ្វើសកម្មភាព ..........................................១១

២.១. កាតព្វកិច្ចមិនឱ្យធ្វើសកម្មភាពដែលបានកំណត់ក្នុងកិច្ចសន្យា ................................. ១២

២.២. កាតព្វកិច្ចមិនឱ្យធ្វើសកម្មភាពដែលបានកំណត់ដោយច្បាប់.................................... ១២

## **ជំពូកទី២**

## **របបគតិយុត្តនៃអនុប្បទានសិទ្ធិលើបំណុល**

**ផ្នែកទី១. លក្ខខណ្ឌដើម្បីធ្វើអនុប្បទានសិទ្ធិលើបំណុល**..........................................................១៤

កថាភាគទី១. ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល.........................................................១៥

កថាភាគទី២. ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន ..........................................................១៦

**ផ្នែកទី២. លក្ខខណ្ឌតតាំង**....................................................................................................... ១៧

កថាភាគទី១. ការតតាំងចំពោះកូនបំណុល ....................................................................................១៨

កថាភាគទី២. ការតតាំងចំពោះតតិយជន .......................................................................................១៨

**ផ្នែកទី៣. ការទទួលកាតព្វកិច្ច** ..................................................................................................១៩

កថាភាគទី១. លក្ខខណ្ឌដើម្បីបង្កើតនូវការទទួលកាតព្វកិច្ច.........................................................១៩

កថាភាគទី២. អានុភាពនៃការទទួលកាតព្វកិច្ច ........................................................................... ២១

កថាភាគទី៣. ការទទួលការអនុវត្តកាតព្វកិច្ច និងការតវ៉ាក្នុងការទទួលកាតព្វកិច្ច........................... ២១

៣.១. ការទទួលការអនុវត្តកាតព្វកិច្ច.........................................................................................២៣

៣.២. ការតវ៉ាក្នុងការទទួលកាតព្វកិច្ច ......................................................................................២៣

**ផ្នែកទី៤. អនុប្បទានឋានៈក្នុងកិច្ចសន្យា**.......................................................................................២៣

កថាភាគទី១. លក្ខខណ្ឌដើម្បីបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា ..............................................២៣

កថាភាគទី២. លក្ខខណ្ឌតតាំង.................................................................................................... ២៤

កថាភាគទី៣. អានុភាពនៃអនុប្បទានឋានៈក្នុងកិច្ចសន្យា.......................................................២៥

**ជំពូកទី៣**

**របបគតិយុត្តនៃការរំលត់សិទ្ធិលើបំណុល**

**ផ្នែកទី១. ការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពគូភាគី**.................................................២៧

កថាភាគទី១. ការសង ...........................................................................................២៧

១.១. អ្នកសង ...........................................................................................២៧

១.២. សមត្ថភាពចាត់ចែងរបស់អ្នកសង.......................................................................២៧

១.៣. សិទ្ធិទទួលការសង និងការកម្រិតសិទ្ធិទទួលការសងដោយការរឹបអូស.......................២៨

១.៣.១. សិទ្ធិទទួលការសង ...........................................................................២៨

១.៣.២. ការកម្រិតសិទ្ធិការសងដោយការរឹបអូស...............................................២៩

១.៤. វិធីសង...........................................................................................២៩

១.៤.១. ការសងមួយភាគ ...........................................................................២៩

១.៤.២. ការសងដោយយកវត្ថុជំនួស...............................................................៣០

១.៥. ការកាត់បំណុល ...........................................................................................៣០

១.៥.១. ការកាត់បំណុលដោយការជ្រើសរើស ...................................................៣០

១.៥.២. ការកាត់បំណុលតាមច្បាប់បានកំណត់...................................................៣១

កថាភាគទី២. ការទូទាត់...........................................................................................៣១

២.១. លក្ខខណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ ...................................................៣២

២.២. កិច្ចសន្យាទូទាត់...........................................................................................៣២

២.៣. វិធីទូទាត់ ...........................................................................................៣២

កថាភាគទី៣. ការលើកលែងរបស់ម្ចាស់បំណុល ...........................................................៣៣

៣.១. ការលើកលែងតែមួយផ្នែក ...........................................................................៣៤

៣.២. ករណីដែលកម្រិតការលើកលែង ............................................................ ៣៤

កថាភាគទី៤. នវកម្ម ............................................................ ៣៤

៤.១. នវកម្មដោយការប្តូរគោលបំណងនៃកាតព្វកិច្ច ............................................................ ៣៥

៤.២. នវកម្មដោយការជំនួសម្ចាស់បំណុល ............................................................ ៣៥

៤.៣. នវកម្មដោយការប្តូរកូនបំណុល ............................................................ ៣៥

កថាខណ្ឌទី៥. ព្យាកុលភាព ............................................................ ៣៥

**ផ្នែកទី២. ការរំលត់សិទ្ធិលើបំណុលតាមបញ្ញត្តិច្បាប់** ............................................................ ៣៦

កថាភាគទី១. អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ............................................................ ៣៧

កថាភាគទី២. ការរំលាយកិច្ចសន្យា ............................................................ ៣៧

២.១. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ............................................................ ៣៨

២.២. ប្រភេទនៃការរំលាយកិច្ចសន្យា ............................................................ ៣៩

កថាភាគទី៣. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ............................................................ ៣៩

៣.១. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ............................................................ ៤១

៣.១.១. ការទាមទារតាមផ្លូវតុលាការ ............................................................ ៤២

៣.១.២. សកម្មភាពអនុវត្តដោយបង្ខំ ឬសកម្មភាពចាត់ចែងរក្សាការពារ ............................................................ ៤៣

៣.១.៣. ការទទួលស្គាល់កាតព្វកិច្ច ............................................................ ៤៣

៣.២. អានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ............................................................ ៤៤

៣.៣. ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ............................................................ ៤៤

៣.៣.១. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយការដាស់តឿនរបស់គូភាគី ............................................................ ៤៥

៣.៣.២. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយការដាស់តឿនតាមផ្លូវតុលាការ ............................................................ ៤៥

៣.៣.៣. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ............................................................ ៤៦

៣.៣.៤. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលរវាងប្តីប្រពន្ធ ....................................៤៦
៣.៣.៥. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ .............៤៧
៣.៤. អានុភាពនៃការបង្អង់អាជ្ញាយុកាល ........................................................................៤៨
កថាភាគទី៤. ការអនុវត្តសិទ្ធិលុបចោល ...........................................................................៤៨
៤.១. លក្ខខណ្ឌនៃការលុបចោល.....................................................................................៤៨
៤.១.១. វិការៈក្នុងការបង្ហាញឆន្ទៈ..........................................................................៤៩
៤.១.២. កង្វះសមត្ថភាពខាងឆន្ទៈ...........................................................................៥១
៤.១.៣. ជនកម្រិតសមត្ថភាព.................................................................................៥១
៤.២. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល ............................................................. ៥២
៤.៣. អានុភាពនៃការលុបចោល...................................................................................... ៥៣
៤.៤. លក្ខខណ្ឌនៃការមោឃៈភាព.................................................................................. ៥៣
៤.៤.១ ការបង្ហាញឆន្ទៈមិនពិត............................................................................... ៥៣
៤.៤.២. កិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ..................................................៥៤
៤.៤.៣. កិច្ចសន្យាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ..................៥៤
៤.៤.៤. កិច្ចសន្យាផ្ទុយនឹងទម្រង់នៃច្បាប់កំណត់.....................................................៥៥
៤.៥. អានុភាពនៃការមោឃៈភាព...................................................................................៥៥
**សេចក្តីសន្និដ្ឋាន** ...............................................................................................................៥៦
**អនុសាសន៍**y ..........................................................................................................៥៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

បច្ចុប្បន្នយើងសង្កេតឃើញថា ប្រទេសកម្ពុជាកំពុងតែមានភាពរីកចម្រើនខាងវិស័យសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់។ ដូច្នេះវាក៏បានឆ្លុះបញ្ចាំងអំពីសក្តានុពលនៃសេដ្ឋកិច្ចទីផ្សារសេរីដែលកំពុងតែបោះពួយយ៉ាងលឿនសំដៅដល់ការអភិវឌ្ឍន៍នៅក្នុងសង្គមជាតិទាំងមូល។ ការអភិវឌ្ឍន៍ គឺពិតជាអ្វីដែលប្រជាជាតិទាំងមូលត្រូវការជាចាំបាច់ ប៉ុន្តែទន្ទឹមនឹងនេះនៅក្នុងការរីកចម្រើនក៏មាននូវបញ្ហាដ៏ស្មុគស្មាញដែលត្រូវធ្វើការដោះស្រាយដើម្បីបន្តនូវវិវត្តន៍ភាពឆ្ពោះទៅអនាគតដ៏វែងឆ្ងាយ។ ជាក់ស្តែងវិវាទតែងតែកើតមាន និងរឹតតែមានជាញឹកញាប់នៅក្នុងកិច្ចសន្យានានា ដោយសារតែប្រជាពលរដ្ឋកម្ពុជាមិនទាន់យល់ដឹងឱ្យបានច្បាស់លាស់ និងស៊ីជម្រៅនៅឡើយទៅលើវិធាននានា និងច្បាប់ដែលពាក់ព័ន្ធមួយចំនួន។ ទាំងអស់នេះហើយ គឺជាមូលហេតុដែលងាយនឹងបង្កើតនូវជម្លោះតតឈប់ឈរ។

ជាក់ស្តែង អនុប្បទានសិទ្ធិលើបំណុលយើងតែងតែសង្កេតឃើញមាននៅស្ទើរតែគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា។ ចំពោះអនុប្បទានសិទ្ធិលើបំណុល វាជាប្រតិបត្តិការមួយដែលមានពីរភាគីតែប៉ុណ្ណោះគឺអនុប្បទាយី និងអនុប្បទានិក ដោយអនុប្បទាយី គឺជាម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលលើកូនបំណុលរីឯអនុប្បទានិក គឺជាតតិយជន។ យើងនៅតែអាចសង្កេតមើលឃើញថានៅប្រទេសកម្ពុជា ចំពោះអនុប្បទានសិទ្ធិលើបំណុល អាចជាយន្តការមួយសម្រាប់ឱ្យសហគ្រាសដែលមិនមានអចលនវត្ថុ ដូចជាសហគ្រាសធុនតូចនិងមធ្យមអាចទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់សិទ្ធិលើបំណុលដែលម្ចាស់សហគ្រាសអាចបង្កើតបានពីប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ពួកគេធ្វើជាទ្រព្យធានាលើប្រាក់កម្ចី ឬតាមរយៈការលក់សិទ្ធិលើបំណុលដោយផ្ទាល់។

ចំណែកឯ ការរំលត់សិទ្ធិលើបំណុលវិញឃើញថាប្រជាពលរដ្ឋយើងមួយចំនួនក៏នៅតែមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការរំលត់កាតព្វកិច្ចនេះ។ ដោយហេតុថាប្រជាជនយើងនៅតែប្រើប្រាស់វិធីសាស្ត្រនៅក្រៅផ្លូវច្បាប់ច្រើនជាងការយកមកប្រើប្រាស់នូវច្បាប់ដែលមានជាធរមាននៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ បើក្រឡេកទៅមើលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិអំពីការរំលត់សិទ្ធិលើបំណុល ដោយការរំលត់សិទ្ធិលើបំណុលត្រូវបានបែងចែងជាពីរ ការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពគូភាគី និងការរំលត់សិទ្ធិលើបំណុលតាមបញ្ញត្តិច្បាប់។

ដោយមើលឃើញការខ្វះខាតការយល់ដឹងពីបញ្ហាទាំងអស់នេះហើយ ទើបយើងទាំងពីរនាក់ខិតខំស្វែងរកនូវឯកសារ និងសរសេរចងក្រងសារណានេះឡើងដើម្បីជាគន្លឹះដោះស្រាយរាល់ចម្ងល់ ក៏ដូចជាបញ្ចៀសនូវវិវាទដែលប្រុងនឹងកើតមានឡើង។

## ២. ចំណោទបញ្ហា

ជាការពិតណាស់នៅក្នុងការប្រាស្រ័យទាក់ទងគ្នារវាងបុគ្គលមួយទៅបុគ្គលមួយរមែងបង្កើតនូវចំណងគតិយុត្តដែលលេចចេញនូវកូនបំណុល និងម្ចាស់បំណុល។ នៅពេលកាតព្វកិច្ចកើតមានឡើងតើមានបច្ចុប្បន្នភាពគតិយុត្តនៃអនុប្បទានសិទ្ធិលើបំណុល និងអនុប្បទានឋានៈក្នុងកិច្ចសន្យាប្រព្រឹត្តទៅបែបណា? ប្រសិនបើភាគីមាន បំណងរំលត់កាតព្វកិច្ច តើមានរបបគតិយុត្តនៃការរំលត់សិទ្ធិលើបំណុល និងការទទួលកាតព្វកិច្ចយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ មានគោលបំណងដ៏សំខាន់ក្នុងការស្រាវជ្រាវឱ្យបានស៊ីជម្រៅ និងស្វែងយល់ពីលក្ខខណ្ឌ ក៏ដូចជារបបគតិយុត្តនៃអនុប្បទាន និងការរំលត់សិទ្ធិលើបំណុល។ ដោយសារតែកន្លងមកពុំទាន់មានឯកសារ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនោះទេ ដែលជាហេតុនាំឱ្យមានភាពលំបាកក្នុងការសិក្សាស្រាវជ្រាវ និងអនុវត្តថែមទៀតផង។ ដូចនេះយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសារណាមួយនេះនឹងអាចជួយចែករំលែកនូវចំណេះដឹង ព្រមទាំងជាឯកសារសម្រាប់ផ្តល់ជូនចំពោះ អ្នកដែលចង់ចេះ ចង់ដឹងអ្វីដែលកាន់តែពិសេសជាងនេះទៅទៀតនោះ សារណាមួយនេះក៏ជាឯកសារមួយយ៉ាងសំខាន់សម្រាប់បម្រើដល់បងប្អូនមិត្តនិស្សិតទាំងឡាយណាដែលចង់ធ្វើការសិក្សាស្រាវជ្រាវអំពីបញ្ហានានា ដែលពាក់ព័ន្ធនឹងសារណាមួយនេះដើម្បីទុកជាទុន និងជាឯកសារជំនួយស្មារតី ព្រមទាំងបំពេញសេចក្តីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវដែលកំពុងតែជួបប្រទះនូវកង្វះខាតនាពេលបច្ចុប្បន្ននេះ។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវសម្រាប់ការសរសេរសារណាដែលមានប្រធានបទ **"អនុប្បទាន និងរំលត់សិទ្ធិលើបំណុល"** យើងទាំងពីរនាក់បានខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវអំពីប្រធានបទមួយនេះដែលមានទំហំ និងដែនកំណត់ដោយផ្តោតសំខាន់ទៅលើលក្ខខណ្ឌ និងអានុភាព ដែលបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ តែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការបង្កើតជាសៀវភៅសារណានេះមានអត្ថប្រយោជន៍ជាជំនួយស្មារតី ជាពុទ្ធិ និងពង្រីកចំណេះដឹង ក៏ដូចជាការជំនួយក្នុងការស្រាវជ្រាវសម្រាប់មិត្តនិស្សិត និងអ្នកចង់ស្វែងយល់អំពីប្រធានបទរបស់ពួកយើង។ ប្រធានបទខាងលើបានផ្តល់ជាមេរៀនយ៉ាងល្អមកកាន់យើងទាំងពីរនាក់ ឱ្យកាន់តែយល់យ៉ាងស៊ីជម្រៅអំពីទំនាក់ទំនងភាគីដែលទាក់ទងទៅនឹងការផ្ទេរកាតព្វកិច្ច ឬហៅថាអនុប្បទាន និងការរំលត់ ឬបញ្ចប់ទៅនៃកាតព្វកិច្ចភាគីនៅក្នុងកិច្ចសន្យាណាមួយ។ ជាពិសេសប្រធានបទខាងលើនេះ ក៏មានសារៈសំខាន់សម្រាប់ការរស់នៅ និងការស្វែងយល់ដែលទាក់ទងទៅនឹងកិច្ចសន្យានៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលកំពុងប្រើប្រាស់កិច្ចសន្យានានាៗដែលមានគោលបំណងក្នុងការផ្ទេរ និងរំលត់សិទ្ធិលើបំណុលនៅក្នុងកិច្ចសន្យា។ ម្យ៉ាងវិញទៀត យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាប្រធានបទដែលពួកយើងបានធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងខាងលើនេះអាចជួយដោះស្រាយបញ្ហារបស់បងប្អូនប្រជាពលរដ្ឋបានទោះបីតិចក្តីច្រើនក្តី ក៏ជាក្តីសង្ឃឹមដែលពួកយើងចង់បានដើម្បីធ្វើការកាត់បន្ថយវិវាទ និងបញ្ចៀសជម្លោះដែលបញ្ជូនទៅតុលាការ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ យើងខ្ញុំទាំងពីនាក់បានខិតខំប្រឹងប្រែងដកស្រង់ និងប្រមូលឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងរបបគតិយុត្តនៃអនុប្បទាន និងការរំលត់សិទ្ធិលើបំណុលតាមរយៈសៀវភៅរបស់សាស្ត្រាចារ្យ ឯកសារដែលមាននៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបទប្បញ្ញត្តិនានាដែលចូលជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាដែលក្នុងនោះមានដូចជា ក្រមរដ្ឋប្បវេណី សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ព្រមទាំងឯកសារមួយចំនួនទៀតដែលទទួលបានតាមរយៈបណ្តាញសង្គមអ៊ីនធឺណេត។ មិនត្រឹមតែប៉ុណ្ណោះ យើងខ្ញុំទាំងពីរនាក់តែងតែធ្វើការពិភាក្សាគ្នា ផ្លាស់ប្តូរគំនិត សួរយោបល់ពីរៀមច្បង សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ ជាពិសេសលោកគ្រូណែនាំផ្ទាល់ក្នុងការសរសេរសារណានេះតែម្តង។

ក្រោយពីបានប្រមូលឯកសារសំខាន់ៗដែលពាក់ព័ន្ធនឹងសារណា ក៏ដូចជាទទួលបានការពន្យល់ណែនាំពីសំណាក់លោកគ្រូដឹកនាំផ្ទាល់ក្នុងការសរសេរសារណានេះ យើងខ្ញុំបានប្រមូលយកទិន្នន័យមកធ្វើការសិក្សាវិភាគយ៉ាងល្អិតល្អន់ និងស៊ីជម្រៅដើម្បីធ្វើការវិភាគរកចំណុចខ្លាំងចំណុចខ្សោយ និងឈានឆ្ពោះទៅរកការសន្និដ្ឋានជារួម ព្រមទាំងផ្តល់អនុសាសន៍។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាចំពោះប្រធានបទខាងលើស្តីអំពី "**អនុប្បទាន និងការរំលត់សិទ្ធិលើបំណុល**" យើងខ្ញុំទាំងពីរនាក់សូមធ្វើការបែងចែកជា ៣ ជំពូកធំៗដូចខាងក្រោមៈ

☞ **ជំពូកទី១ ៖ សាវតានៃកាតព្វកិច្ច**

☞ **ជំពូកទី២ ៖ របបគតិយុត្តនៃអនុប្បទានសិទ្ធិលើបំណុល**

☞ **ជំពូកទី៣ ៖ របបគតិយុត្តនៃការរំលត់សិទ្ធិលើបំណុល**

# ជំពូកទី១

# សាវតានៃការពុកិច្ច

# ជំពូកទី១

# សាវតានៃកាតព្វកិច្ច

## ផ្នែកទី១. ប្រភពនៃកាតព្វកិច្ច

កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត[1]។ បន្ថែមលើនេះ កាតព្វកិច្ចត្រូវបានគេឱ្យនិយមន័យមួយបែបទៀតថា គឺជាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថាកូន **«បំណុល»** មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ហៅថា **«ម្ចាស់បំណុល»**[2]។

ដោយអនុលោមតាមមាត្រា ៣០៩ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិថា កាតព្វកិច្ចកើតមានឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនឥតហេតុ ដោយអំពើអនីត្យានុកូល និងដោយបញ្ញត្តិនៃច្បាប់។

### កថាភាគទី១. កាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី

កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និងដោយសកម្មភាពឯកតោភាគី គឺជា**កាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី**[3]។ ត្រង់អត្ថន័យនេះបានសេចក្តីថា ភាគីមានគោលបំណងបង្កើតឥទ្ធិពលនៃកាតព្វកិច្ចនោះ ហើយអានុភាពគតិយុត្តក៏ត្រូវបានទទួលស្គាល់តាមគោលបំណងនេះដែរ។

#### ១.១. កិច្ចសន្យា

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច [4]។ មានន័យថាគូភាគីអាចបង្កើតកិច្ចសន្យា និងមានអានុភាពបាននៅពេលដែលមានសំណើ និងស្វីការត្រូវគ្នា[5]។ ជាមួយគ្នានេះដែរ គូភាគីក្នុងកិច្ចសន្យាក៏អាចធ្វើការកែប្រែនូវលក្ខខណ្ឌមួយចំនួននៅក្នុងកិច្ចសន្យាបានតាមរយៈ

[1] មាត្រា ៣០៩, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[2] សន្ទានុក្រម ផ្នែករដ្ឋប្បវេណីទំព័រទី១

[3] មាត្រា ៣០៩, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[4] មាត្រា ៣១១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[5] មាត្រា ៣៣៦, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ស្នើការដោយមានបន្ថែមការកែប្រែ[6]។ លើសពីនេះទៅទៀត គូភាគីក៏អាចរំលត់កាតព្វកិច្ចនៅក្នុងកិច្ចសន្យាដោយសកម្មភាពឯកតោភាគី និងតាមរយៈបញ្ញត្តិច្បាប់កំណត់[7]។

***ឧទាហរណ៍៖*** *កិច្ចសន្យាលក់ទិញឡានមួយគ្រឿងមានតម្លៃ ១៥០ ០០០ ដុល្លាអាមេរិក ដែលបង្កើតឡើងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ រវាងលោក ក ជាអ្នកលក់ និងកញ្ញា ខ ជាអ្នកទិញ។ ដូច្នេះអ្នកលក់មានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញឱ្យទៅអ្នកទិញ រីឯអ្នកទិញមានកាតព្វកិច្ចបង់ថ្លៃលក់ទៅអ្នក។*

### ១.២. សកម្មភាពឯកតោភាគី

យោងតាមមាត្រា ៣១២ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់។ ដូច្នេះយើងអាចធ្វើការបកស្រាយបានថាសកម្មភាពឯកតោភាគី សំដៅលើករណីដែល កាតព្វកិច្ចកើតឡើងដោយការបង្ហាញឆន្ទៈជាឯកតោភាគីពីភាគីតែម្ខាង ឬមិនតម្រូវឱ្យមានការព្រមព្រៀងពីភាគីម្ខាងទៀតនោះទេ។

***ឧទាហរណ៍៖*** *ផ្អែកទៅតាមកិច្ចសន្យាខ្ចីបរិភោគ ដែលកូនបំណុលបានខ្ចីប្រាក់ពីម្ចាស់ បំណុលចំនួន ៥០០០ ដុល្លាអាមេរិក។ នៅថ្ងៃមួយម្ចាស់បំណុលបានលើកលែងកាតព្វកិច្ច ១០០០ ដុល្លាអាមេរិកចំពោះកូនបំណុល។ក្នុងករណីនេះ គឺជាសកម្មភាពឯកតោភាគីរបស់ម្ចាស់បំណុល។*

***ឧទាហរណ៍៖*** *ក្រោយពីម្ដាយមីងរបស់លោក ក បានស្លាប់ទៅ ម្ដាយមីងបានបន្សល់ទុកបណ្ដាំមួយច្បាប់ (មតកសាសន៍) ដែលមានខ្លឹមសារថានឹងប្រគល់ដីចម្ការចំនួន ១០ ហិកតាទៅឱ្យ លោក ក។ ក្នុងករណីនេះ ដីដែលមានទំហំ ១០ ហិកតា គឺជាអច្ច័យទាន មានកំណត់ដែលម្ដាយមីង (ម្ចាស់បណ្ដាំ) បានប្រគល់ឱ្យលោក ក (ហៅថា អច្ច័យលាភី)។*

## កថាភាគទី២. កាតព្វកិច្ចដែលកំណត់ដោយច្បាប់

ជាការពិតណាស់ កាតព្វកិច្ចកើតឡើងដោយកិច្ចសន្យា និងសកម្មភាពឯកតោភាគី មានន័យថាភាគីមានគោលបំណងក្នុងការបង្កើតនូវកាតព្វនោះដោយការបង្ហាញឆន្ទៈ។ ផ្ទុយទៅវិញ កាតព្វកិច្ចទាំងឡាយណាដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្ដីចម្រើនឥតហេតុ ដោយអំពើអនីត្យានុកូល

[6] មាត្រា ៣៤២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[7] មាត្រា ៤៣៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

និងដោយបញ្ញត្តិច្បាប់ ក្នុងករណីកាតព្វកិច្ចទាំងនេះបានបំពេញលក្ខខណ្ឌដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ គឺជា**កាតព្វកិច្ចដែលកំណត់ដោយច្បាប់**[8]។

### ២.១. ការគ្រប់គ្រងដោយឈឺឆ្អាល

ការគ្រប់គ្រងដោយឈឺឆ្អាល សំដៅដល់ការគ្រប់គ្រងកិច្ចការអ្វីមួយដើម្បីប្រយោជន៍បុគ្គលដទៃ បើទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ។ រីឯបុគ្គលដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហៅថាអ្នកគ្រប់គ្រងដោយឈឺឆ្អាល។ ក៏ប៉ុន្តែអ្នកគ្រប់គ្រង់ដោយឈឺឆ្អាល ត្រូវធ្វើការគ្រប់គ្រងដោយសុចរិតប្រុងប្រយ័ត្នតាមវិធីដែលសមរម្យតាមដែលអាចធ្វើបាន។ ក្នុងករណីដែលអ្នកគ្រប់គ្រង់ដោយឈឺឆ្អាលបានដឹងអំពីឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រង់ដោយឈឺឆ្អាលត្រូវធ្វើតាមឆន្ទៈនោះ[9]។ ត្រង់នេះមានន័យថា ការគ្រប់គ្រងដោយឈឺឆ្អាលមិនមែនកើតឡើងដោយឆន្ទៈព្រមព្រៀងរបស់គូភាគីទេ ក៏ប៉ុន្តែវាមានអានុភាពបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចដូចការព្រមព្រៀងដែរ។ ទោះបីជាខ្លួនគ្មានករណីកិច្ចតាមច្បាប់ ឬកាតព្វកិច្ចតាមរយៈកិច្ចសន្យាក៏ដោយ ប្រសិនបើបុគ្គលណាម្នាក់បានធ្វើសកម្មភាពអ្វីមួយក្នុងគោលបំណងការពារ ឬទប់ស្កាត់ស្ថានភាពណាមួយដើម្បីផលប្រយោជន៍ដល់បុគ្គលម្នាក់ទៀត។ ជាមួយគ្នាផងដែរ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃទោះបើជាគ្មានសិទ្ធិអំណាច ឬករណីយកិច្ចតាមផ្លូវច្បាប់ ដើម្បីធ្វើបែបនេះក៏ដោយការចេះជួយគ្នាទៅវិញទៅមក និងការសាមគ្គីភាពគ្នាមានសារៈសំខាន់សម្រាប់ទំនាក់ទំនងក្នុងសង្គម ។

ដើម្បីកំណត់ពីអត្ថិភាពនៃការគ្រប់គ្រងដោយឈឺឆ្អាល ត្រូវតែបំពេញលក្ខខណ្ឌមួយចំនួនរួមមាន៖

- **ការគ្រប់គ្រងដោយឈឺឆ្អាលដែលធ្វើឡើងដោយគ្មានសិទ្ធិអំណាច**[10]
- **ការគ្រប់គ្រងធ្វើឡើងដើម្បីអ្នកដទៃ**[11]
- **អ្នកគ្រប់គ្រងចាប់ផ្ដើមគ្រប់គ្រងកិច្ចការ**[12]
- **ការគ្រប់គ្រងធ្វើឡើងទៅតាមវិធីដែលសមរម្យជាងគេ ឬផ្អែកតាមឆន្ទៈរបស់បុគ្គលជាសាមីខ្លួន**[13]។

---

[8] មាត្រា ៣០៩, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[9] មាត្រា ៧២៩, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[10] មាត្រា ៧២៩, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[11] សេក្ដីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០, មាត្រា ៧២៩

[12] សេក្ដីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០, មាត្រា ៧២៩

[13] សេក្ដីពន្យល់ក្រមរដ្ឋប្បវេណី ភាគ២ ឆ្នាំ២០១៣, ទំព័រ៧៧

***ឧទាហរណ៍៖*** *លោក ក និងលោក ខ រស់នៅផ្ទះជាប់គ្នា ស្រាប់តែថ្ងៃមួយលោក ក មានធុរៈត្រូវទៅក្រៅប្រទេស បានទុកសត្វឆ្កែមួយក្បាលឱ្យចាំផ្ទះ និងបានទុកចំណីមួយចំនួនផងដែរ។ នៅថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០២២ ចំណីសត្វឆ្កែនោះក៏បានអស់ ហើយសត្វឆ្កែក៏បានឈឺ ដោយឃើញយ៉ាងដូច្នះលោក ខ ដែលជាអ្នករស់នៅផ្ទះជាប់គ្នានោះក៏បានយកសត្វឆ្កែនោះទៅព្យាបាល និងទិញចំណីឱ្យសត្វឆ្កែនោះដោយអស់ថវិការចំនួន ១០០ ដុល្លាអាមេរិក។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលដែលលោក ខ យកសត្វឆ្កែ របស់លោក ក ទៅព្យាបាល លោក ខ មិនបានទៅធ្វើការងារចំនួន២ថ្ងៃ ដែលក្នុងមួយថ្ងៃគាត់អាចទទួលបានប្រាក់ពីការងាររបស់គាត់ជាមធ្យម ១០ ដុល្លាអាមេរិក ក្នុងមួយថ្ងៃ។ នៅក្នុងករណីបែបនេះ លោក ខ អាចធ្វើការទាមទារប្រាក់ដែលបានចំណាយថ្លៃព្យាលសត្វឆ្កែ និងថ្នាំព្យាបាលពីលោក ក វិញបាន។*

### ២.២. សេចក្តីចម្រើនដោយឥតហេតុ

សេចក្តីចម្រើនដោយឥតហេតុ គឺជាការទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬពលកម្មរបស់អ្នកដទៃដោយគ្មានមូលហេតុតាមផ្លូវច្បាប់ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃដោយសារការទទួលផលនោះ[14]។ ទោះបីជា ពុំមានការព្រមព្រៀងគ្នាជាមុន ក៏ការបង្កើតនូវទំនាក់ទំនងនៃសិទ្ធិលើបំណុល និងកាតព្វកិច្ចដែលបង្កើតឡើងក្រៅពីឆន្ទៈរបស់ភាគីដែលបានដាក់បន្ទុកឱ្យបុគ្គលណាមួយដែលគ្មានមូលហេតុ គតិយុត្តក្នុងការទទួលបាននូវផលប្រយោជន៍សងត្រឡប់នូវអ្វីដែលខ្លួនបានទទួលឱ្យទៅបុគ្គលដែលបានបាត់បង់ផលប្រយោជន៍ និងបានផ្តល់សិទ្ធិឱ្យភាគីដែលបាត់ផលប្រយោជន៍អាចធ្វើការទាមទារយកមកវិញនូវអ្វីដែលបានបាត់បង់ដោយគ្មានមូលហេតុតាមផ្លូវច្បាប់។

ដើម្បីកំណត់ពីអត្ថិភាពនៃសេចក្តីចម្រើនឥតហេតុ ត្រូវតែបំពេញលក្ខខណ្ឌមួយចំនួនរួមមាន[15]៖

- **ការទទួលបានផលប្រយោជន៍**
- **ការបាត់បង់ផលប្រយោជន៍**
- **ទំនាក់ទំនងហេតុ និងផលរវាងការទទួលផលប្រយោជន៍ និងការបាត់បង់ផលប្រយោជន៍**
- **ភាពមិនមានមូលហេតុលើផ្លូវច្បាប់ក្នុងការទទួលបានផលប្រយោជន៍។**

***ឧទាហរណ៍៖*** *លោក ក បានបង្កើតកិច្ចសន្យាលក់ទិញរថយន្តមួយគ្រឿងមានតម្លៃ ៨០០០ ដុល្លាអាមេរិកជាមួយលោក ខ នៅថ្ងៃទី០១ ខែ មីនា ឆ្នាំ២០១៩ ដោយកំណត់ឱ្យលោក ក ដែលជាអ្នកលក់ត្រូវប្រគល់រថយន្តនៅថ្ងៃទី០២ ខែ មីនា ឆ្នាំ២០១៩ ហើយលោក ខ ដែលជាអ្នកទិញត្រូវប្រគល់ប្រាក់នៅថ្ងៃទី០៣ ខែ មីនា*

[14] មាត្រា ៧៣៦, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[15] សេក្តីពន្យល់ក្រមរដ្ឋប្បវេណីឆ្នាំ២០១៣ ភាគី២, ទំព័រ៨២

*ឆ្នាំ២០១៩ ។ នៅពេលដែលលោក ក បានប្រគល់រថយន្ត ឱ្យលោក ខ បានមួយសប្តាហ៍គាត់បានដឹងថាការបង្កើតកិច្ចសន្យាលក់ទិញរថយន្តនោះអាចធ្វើជាកម្មវត្ថុនៃការលុបចោល ដោយសារការភាន់ច្រលំទៅលើតម្លៃរថយន្ត ដែលតម្លៃរថយន្តពិតប្រាកដមានចំនួន ១៥០០០ ដុល្លាអាមេរិក ឯណោះ។ អាស្រ័យហេតុនេះ នៅពេលដែល លោក ក ធ្វើការលុបចោលកិច្ចសន្យាលក់ទិញរថយន្តជាមួយលោក ខ ពិតប្រាកដណាស់លោក ក អាចទាមទារ រថយន្តពីលោក ខ វិញបានតាមរយៈសេចក្តីចម្រើនឥតហេតុ។*

### ២.៣. អំពើអនីត្យានុកូល

នៅពេលដែលមានអង្គហេតុមួយកើតឡើងរវាងភាគីដែលពុំមានទំនាក់ទំនងគតិយុត្តជាមួយគ្នាជាមុនដូចជាទំនាក់ទំនងនៃកិច្ចសន្យា ជាអាទិ៍ ហើយភាគីម្ខាងទៀតបានប្រព្រឹត្តអំពើណាមួយ ទោះបីជាចេតនា ឬអចេតនាបានបណ្តាលឱ្យភាគីម្ខាងទៀតទទួលរងការខូតខាត ដែលជាមូលហេតុនាំឱ្យភាគីដែលបានប្រព្រឹត្តអំពើនោះត្រូវទទួលខុសត្រូវសងសំណងខូតខាតចំពោះជនរងគ្រោះដោយស្ថានភាពនេះហៅថា អំពើអនីត្យានុកូល[16]។

ដើម្បីកំណត់ពីអត្ថិភាពនៃអំពើអនីត្យានុកូល ត្រូវបំពេញតាមលក្ខខណ្ឌសំខាន់ៗរួមមាន[17]៖

- **កំហុស (ចេតនា ឬអចេតនា**
- **សមត្ថភាពទទួលខុសត្រូវ**
- **ព្យសនកម្ម**
- **ទំនាក់ទំនងហេតុផល**
- **ការបំពានសិទ្ធិ ឬផលប្រយោជន៍ដោយខុសច្បាប់។**

***ឧទាហរណ៍៖*** *នៅក្នុងកម្មវិធីបុណ្យអុំទូក ដែលប្រារព្ធធ្វើឡើងនៅខេត្តរតនៈគិរីនៅថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ លោក ក បានទៅដើរលេងកម្សាន្តនៅទីរួមខេត្ត។ បន្ទាប់ពីដើរលេងរួចមក លោក ក បានចូលក្លឹបកម្សាន្តមួយកន្លែង ព្រមទាំងបានជួបជាមួយលោក ខ ដែលជាអ្នកដើរលេងក្លឹបកម្សាន្តផងនោះ អ្នកទាំងពីរបានរាំកម្សាន្តនៅក្នុងក្លឹបជាមួយគ្នា ពេលនោះលោក ក បានឃើញមុខលោក ខ ឌឺពេកក៏បានវាយឱ្យលោក ខ ឱ្យសន្លប់បាត់បង់ស្មារតី។ នៅក្នុងករណីខាងលើ លោក ក វាយលោក ខ បែបនេះត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ យ៉ាងណាមិញ បើក្រឡេកមកមើលច្បាប់ស៊ីវិល លោក ខ ដែលជាជនរងគ្រោះដែលត្រូវបានលោក ក វាយគាត់អាចធ្វើការទាមទារសំណងការ*

[16] មាត្រា ៧៤២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[17] មាត្រា ៧៤៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

*ខូចខាតបានដោយផ្អែកលើអំពើអនីត្យានុកូល ព្រោះនេះជាបេបគតិយុត្តមួយដែលការពារជនដែលត្រូវបានគេបំពានសិទ្ធិ និងផលប្រយោជន៍ដោយខុសច្បាប់។*

## ផ្នែកទី២. ប្រភេទនៃកាតព្វកិច្ច

ដូចដែលបានពន្យល់នៅចំណុចខាងលើរួចមក យើងអាចបកស្រាយបានថាកាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលបុគ្គលជាក់លាក់ម្នាក់ (កូនបំណុល) មានករណីយកិច្ចចំពោះបុគ្គលជាក់លាក់ម្នាក់ទៀត (ម្ចាស់បំណុល)។ ផ្អែកតាមមាត្រា ៣១៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា ក្រៅពីគោលបំណងផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់លើវត្ថុ ឬប្រាក់ កាតព្វកិច្ចអាចមានគោលបំណងធ្វើ ឬមិនធ្វើសកម្មភាពណាមួយ[18]។ ដូចនេះ ប្រភេទនៃកាតព្វកិច្ចមានពីរយ៉ាងពោលគឺ **កាតព្វកិច្ចដែលមានគោលបំណងធ្វើសកម្មភាព** និង**កាតព្វកិច្ចដែលមានគោលបំណងមិនឱ្យធ្វើសកម្មភាព**។

### កថាភាគទី១. កាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើសកម្មភាព

កាតព្វកិច្ចធ្វើសកម្មភាព មានកម្មវត្ថុជាការធ្វើសកម្មភាព ឬការបំពេញការងាររបស់កូនបំណុលនោះផ្ទាល់តែម្តង។

#### ១.១. កាតព្វកិច្ចផ្ទេរ

កាតព្វកិច្ចផ្ទេរ ជាផ្នែកមួយនៃប្រភេទកាតព្វកិច្ចដែលនាំឱ្យកូនបំណុល និងម្ចាស់បំណុលត្រូវប្រគល់វត្ថុឱ្យគ្នាទៅវិញទៅមក ដោយប្រភេទនៃកាតព្វកិច្ចមួយនេះត្រូវបានបែងចែងជាកាតព្វកិច្ចផ្ទេរប្រាក់ និងកាតព្វកិច្ចមិនផ្ទេរប្រាក់។ កាតព្វកិច្ចផ្ទេរប្រាក់ ជាកាតព្វកិច្ចដែលនាំឱ្យភាគីត្រូវអនុវត្តជាប្រាក់ ឬអាចអនុវត្តកាតព្វកិច្ចជារូបិយវត្ថុតាមការជ្រើសរើសរបស់ខ្លួនបាន។ ផ្ទុយមកវិញ ក្នុងករណីដែលភាគីបានកំណត់កាតព្វកិច្ចជារូបិយវត្ថុបរទេស កូនបំណុលអាចធ្វើការសងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែត្រូវគិតអត្រាប្តូររូបិយប័ណ្ណបរទេសនោះនៅកន្លែងអនុវត្តកាតព្វកិច្ច[19]។ ចំណែកឯកាតព្វកិច្ចមិនមែនជាប្រាក់ ត្រូវបានបែងចែកជាកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ និងកាតព្វកិច្ចកំណត់ប្រភេទវត្ថុ។ យោងតាមមាត្រា ៣១៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ក្នុងករណីកាតព្វកិច្ចប្រគល់វត្ថុជាក់លាក់អ្វីមួយ កូនបំណុលត្រូវមានករណីយកិច្ចថែរក្សាវត្ថុនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ។ រីឯកាតព្វកិច្ចកំណត់ប្រភេទនៃវត្ថុវិញ ប្រសិនបើម្ចាស់បំណុលបានកំណត់ប្រភេទនៃវត្ថុ ឬគុណភាពហើយនោះ កូនបំណុលត្រូវមានករណីយកិច្ចផ្តល់នូវវត្ថុដែលភាគីបានកំណត់ ក៏ប៉ុន្តែក្នុងករណី

[18] មាត្រា ៣១៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[19] មាត្រា ៣១៧, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ម្ចាស់បំណុលមិនបានកំណត់ប្រភេទនៃវត្ថុ ឬគុណភាពទេ កូនបំណុលមានករណីយកិច្ចផ្តល់ជូននូវវត្ថុដែលមានគុណភាពសមរម្យ។ ម្យ៉ាងវិញទៀត ប្រសិនបើកូនបំណុលបានកំណត់ប្រភេទនៃវត្ថុបានច្បាស់លាស់ហើយនោះ និងបានបញ្ចប់សកម្មភាពដើម្បីផ្តល់នូវវត្ថុនោះបានរួចរាល់ កូនបំណុលមានករណីយកិច្ចផ្តល់ជូនម្ចាស់បំណុលតែវត្ថុនោះប៉ុណ្ណោះ[20]។

### ១.២. កាតព្វកិច្ចឱ្យធ្វើសកម្មភាព

កាតព្វកិច្ចដែលមានគោលបំណងធ្វើសកម្មភាព គឺជាកាតព្វកិច្ចដែលភាគីម្ខាងជាកូនបំណុលធ្វើសកម្មភាពជាក់លាក់ណាមួយចំពោះភាគីម្ខាងទៀតដែលជាម្ចាស់បំណុល ឬនិយាយម្យ៉ាងទៀតបានថាកូនបំណុលត្រូវបំពេញករណីយកិច្ចដែលជាកម្មវត្ថុនៃកាតព្វកិច្ចដូចជាធ្វើអ្វីមួយ ឬច្រើនខានមិនបានទៅម្ចាស់បំណុល។ ចំពោះកាតព្វកិច្ចដែលមានគោលបំណងធ្វើសកម្មភាព វាអាចធ្វើឡើងតាមរយៈកិច្ចសន្យាអាណត្តិ កិច្ចសន្យាការងារ និងកិច្ចសន្យាម៉ៅការ ជាអាទិ៍។

***ឧទាហរណ៍៖*** *លោក ក ជាអ្នកម៉ៅការ និងលោកស្រី ខ ជាម្ចាស់ការ បានបង្កើតកិច្ចសន្យាម៉ៅការសាងសង់ផ្ទះមួយល្វែង នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២។ ក្នុងករណីនេះលោក ក ត្រូវតែធ្វើការសាងសង់ផ្ទះមួយល្វែងទៅតាមអ្វីដែលបានកំណត់ក្នុងកិច្ចសន្យាដោយពុំមានវិការៈឡើយ។*

***ឧទាហរណ៍៖*** *លោកស្រី ក ជាម្ចាស់ផលិតកម្មចម្រៀង និងកញ្ញា ក ជាតារាចម្រៀងបានបង្កើតកិច្ចសន្យានៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ដែលលោកស្រី ក បានដាក់លក្ខខណ្ឌ និងកំណត់អំឡុងពេល២ឆ្នាំឱ្យកញ្ញា ខ ធ្វើការច្រៀងនៅផលិតកម្មរបស់ខ្លួន ដោយមិនឱ្យច្រៀងនៅ ផលិតកម្មណាផ្សេងឡើយ។ ក្នុងករណីនេះ កញ្ញា ខ ត្រូវតែច្រៀងចម្រៀងនៅផលិតកម្មចម្រៀងរបស់លោកស្រី ក ក្នុងអំឡុងពេល២ឆ្នាំ។*

### កថាភាគទី២. កាតព្វកិច្ចដែលមានគោលបំណងមិនឱ្យធ្វើសកម្មភាព

ចំពោះកាតព្វកិច្ចដែលមានគោលបំណងមិនឱ្យធ្វើសកម្មភាពជាក់លាក់ណាមួយ ត្រូវបានឱ្យឈ្មោះថាកាតព្វកិច្ចមានគោលបំណងមិនឱ្យធ្វើសកម្មភាព។ បើទោះបីក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាមិនបានបញ្ញត្តិក៏ដោយ ក៏ប៉ុន្តែវាមានសុពលភាពដោយផ្អែកទៅលើគោលការណ៍សេរីភាពក្នុងការបង្កើតកិច្ចសន្យា និងកំណត់ដោយបញ្ញត្តិច្បាប់។

[20] មាត្រា ៣១៥, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.១. កាតព្វកិច្ចមិនឱ្យធ្វើសកម្មភាពដែលបានកំណត់ក្នុងកិច្ចសន្យា

ជាការពិតណាស់ កាតព្វកិច្ចមិនធ្វើសកម្មភាពដែលបានកំណត់ក្នុងកិច្ចសន្យា សំដៅលើកាតព្វកិច្ចដែលភាគីម្ខាងដែលជាម្ចាស់បំណុលបានធ្វើការហាមឃាត់មិនឱ្យកូនបំណុលធ្វើសកម្មភាពជាក់លាក់ណាមួយដែលបានកំណត់នៅក្នុងកិច្ចសន្យា។

***ឧទាហរណ៍៖*** *តារាសម្តែង លោក ក និងផលិតកម្មភាពយន្តបានបង្កើតកិច្ចសន្យានៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៨ ដោយផលិតកម្មភាពយន្តហាមតារាសម្តែង ក មិនឱ្យធ្វើសកម្មភាពសម្តែង ឬសកម្មណាមួយនៅក្នុងផលិតកម្មផ្សេងនៅក្នុងអំឡុងពេលកំណត់នៅក្នុងកិច្ចសន្យាឡើយ។*

### ២.២. កាតព្វកិច្ចមិនឱ្យធ្វើសកម្មភាពដែលបានកំណត់ដោយច្បាប់

ជាគោលការណ៍ កាតព្វកិច្ចមិនធ្វើសកម្មភាពភាគច្រើនកើតឡើងតាមរយៈលក្ខខណ្ឌក្នុងសន្យាដែលកូនបំណុល និងម្ចាស់បំណុលបានកំណត់ទុកជាមុន។ ប៉ុន្តែទោះបីជាគ្មានកំណត់លក្ខខណ្ឌក្នុងកិច្ចសន្យាក៏អាចមានកាតព្វកិច្ចមួយដែលមិនធ្វើសកម្មភាពត្រូវបានកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងៗ។

***ឧទាហរណ៍៖*** *មាត្រា៤ វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតនៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត បានបញ្ញត្តិថា រាជរដ្ឋាភិបាលអាចដាក់ចេញជាបណ្តោះអាសន្ននូវវិធានការ និងវិធានការផ្សេងទៀតដែលមានភាពចាំបាច់ និងមានប្រយោជន៍ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលាក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មានជាអាទិ៍៖*

- *ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ*
- *ការរឹតត្បិត ឬការហាមឃាត់ការជួបជុំ និងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនេះអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩*
- *ការហាមឃាត ឬការកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩*
- *ការបិទខ្ទប់តំបន់ ឬទីកន្លែងមួយចំនួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩*
- *ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩*
- *វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។*

*ក្នុងករណីបន្ទាប់ និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិអំណាចដល់ក្រសួងស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីដាក់ចេញនូវវិធានការខាងលើ និងធានាដល់ការអនុវត្តវិធានការសំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។*

ទាំងនេះ គឺជាកាតព្វកិច្ចដែលមិនឱ្យធ្វើសកម្មភាពចេញដោយរាជរដ្ឋាភិបាល ដើម្បីធ្វើការរារាំងព្រមទាំងទប់ស្កាត់ជម្ងឺរាតត្បាត ដោយបានកំណត់ឱ្យប្រជាពលរដ្ឋនៅក្នុងតំបន់ហាមឃាត់ណាមួយមិនត្រូវធ្វើសកម្មភាពចាកចេញ ឬផ្លាស់ទីពីលំនៅឋានរបស់ខ្លួនជាកំហិត។

# ជំពូកទី២
# របបគតិយុត្តនៃអនុប្បទានសិទ្ធិ
# លើបំណុល

# ជំពូកទី២

# របបគតិយុត្តនៃអនុប្បទានសិទ្ធិលើបំណុល

## ផ្នែកទី១. លក្ខខណ្ឌដើម្បីធ្វើអនុប្បទានសិទ្ធិលើបំណុល

សិទ្ធិលើបំណុលកើតឡើងនៅពេលមានវត្តមានកាតព្វកិច្ច។ កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និងសកម្មភាពឯកតោភាគី គឺជា**កាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី**[21]។ ចំណែកឯ **កាតព្វកិច្ចកើតឡើងតាមការកំណត់របស់ច្បាប់** មានជាអាទិ៍ អំពើអនីត្យានុកូល ការគ្រប់គ្រងដោយឈឺឆ្អាល សេចក្តីចម្រើនឥតហេតុ និងដោយបញ្ញត្តិនៃច្បាប់[22]។ ហេតុដូចនេះ កាលណាបុគ្គលមានសិទ្ធិលើបំណុល គាត់អាចធ្វើការចាត់ចែងដូចជា លក់សិទ្ធិលើបំណុល ធ្វើប្រទានកម្មចំពោះសិទ្ធិលើបំណុល ឬដូរសិទ្ធិលើបំណុល ទាំងអស់នេះហៅថា**ការធ្វើអនុប្បទានសិទ្ធិលើបំណុល**។ ចំពោះមូលហេតុដែលនាំឱ្យមានការបញ្ញត្តិអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុល វាមានផលប្រយោជន៍ដល់ប្រតិបត្តិការគតិយុត្តនានា ដោយបុគ្គលដែលជាប្រធាននៃសិទ្ធិអាចចាត់ចែងផ្លាស់ប្តូរសិទ្ធិដែលខ្លួនមានតាមសេចក្តីត្រូវការ។ ក៏ប៉ុន្តែការបើកសិទ្ធិបែបនេះអាចនឹងធ្វើឱ្យមានផលប៉ះពាល់ដល់ភាគីម្ខាងទៀតគឺ កូនបំណុល។ ហេតុនេះហើយទើបច្បាប់បានបញ្ញត្តិអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុលនេះ។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ពុំបានចែងអំពីនិយមន័យនៃពាក្យអនុប្បទានសិទ្ធិលើបំណុលនោះទេ ដោយហេតុថាពាក្យនេះអាចត្រូវបានស្វែងយល់ដោយពុំចាំបាច់មានការកំណត់។ អនុប្បទាន[23]សិទ្ធិលើបំណុល គឺជាការផ្ទេរសិទ្ធិលើបំណុលដែលកើតឡើងតាមរយៈការព្រមព្រៀង ឬបញ្ញត្តិច្បាប់ ឱ្យទៅភាគីម្ខាងទៀតក្រៅពីកូនបំណុលក្រោមរូបភាពជាការលក់ ដូរ ឬប្រទានកម្ម ជាអាទិ៍។

ជាគោលការណ៍ ដើម្បីធ្វើអនុប្បទានសិទ្ធិលើបំណុលបានតម្រូវឱ្យបំពេញលក្ខខណ្ឌដូចជា៖

- **មានការព្រមព្រៀងរវាងអនុប្បទាយី (ម្ចាស់បំណុល) និងអនុប្បទានិក (តតិយជន)**
- **សិទ្ធិលើបំណុលមានលក្ខណៈអាចធ្វើអនុប្បទានបាន**
- **គ្មានការសន្យាពិសេសដែលហាមមិនឱ្យធ្វើអនុប្បទាន**[24]។

[21] មាត្រា ៣០៩, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[22] មាត្រា ៣០៩, កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[23] សន្ទានុក្រមផ្នែករដ្ឋប្បវេណី, លេខរៀង១៨៩

[24] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ១, ទំព័រទី២៥៩

**កថាភាគទី១. ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល**

ក្រឡេកមកមើល ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ក៏មិនបានផ្តល់និយមន័យលើពាក្យសិទ្ធិលើបំណុលនោះទេ។ ទោះបីជាយ៉ាងណា តាមរយៈការសិក្សាលើបញ្ញត្តិស្តីពីកាតព្វកិច្ច គេអាចធ្វើការសន្និដ្ឋានបានថា សិទ្ធិលើបំណុល គឺជាកញ្ចក់ឆ្លុះបញ្ចាំងពីកាតព្វកិច្ចពីព្រោះនៅពេលដែលកាតព្វកិច្ចមួយត្រូវបានបង្កើតលើភាគីម្ខាង ដូច្នេះភាគីម្ខាងទៀតនឹងមានសិទ្ធិលើបំណុល។

***ឧទាហរណ៍៖*** *ក្នុងកិច្ចសន្យាលក់ទិញផ្ទះមួយ ម្ចាស់ផ្ទះមានកាតព្វកិច្ចក្នុងការប្រគល់តាវកាលិកដែលជាផ្ទះឱ្យទៅអ្នកទិញ ដែលក្នុងពេលនោះអ្នកទិញមានសិទ្ធិលើបំណុលលើអ្នកលក់ដែលអនុញ្ញាតឱ្យអ្នកទិញធ្វើការទាមទារឱ្យអ្នកលក់ប្រគល់ផ្ទះ។*

ចំពោះភាគីដែលមានសិទ្ធិលើបំណុលត្រូវបានហៅថា **ម្ចាស់បំណុល** ហើយភាគីម្ខាងទៀតដែលត្រូវបំពេញកាតព្វកិច្ចហៅថា **កូនបំណុល**[25]។ ស្របជាមួយគ្នានេះដែរ កាតព្វកិច្ចត្រូវបានបែងចែកជា កាតព្វកិច្ចក្នុងការធ្វើសកម្មភាពអ្វីមួយ និងកាតព្វកិច្ចមិនឱ្យធ្វើសកម្មភាពអ្វីមួយ[26]។ តួយ៉ាង កាតព្វកិច្ចក្នុងការធ្វើសកម្មភាពអ្វីមួយត្រូវបានបែងចែកជាប្រគល់ និងធ្វើសកម្មភាព ហើយកាតព្វកិច្ចក្នុងការប្រគល់ត្រូវបានបែងចែកជាប្រគល់ប្រាក់ និងការប្រគល់វត្ថុ។ ដោយហេតុថា កាតព្វកិច្ចបានឆ្លុះបញ្ចាំងអំពីសិទ្ធិលើបំណុលនោះវាក៏ត្រូវបានបែងចែកជាពីរប្រភេទធំៗនេះដែរ។ ទោះបីជាយ៉ាងណា មិនមែនគ្រប់ប្រភេទសិទ្ធិលើបំណុលអាចក្លាយជាកម្មវត្ថុនៃការធ្វើអនុប្បទានបាននោះទេ មានតែសិទ្ធិលើបំណុលដែលមានលក្ខណៈអាចធ្វើអនុប្បទានបានទើបត្រូវធ្វើអនុប្បទាន[27]។ ហេតុនេះ ក្នុងចំណោមសិទ្ធិលើបំណុលប្រភេទធំ និងប្រភេទតូចដែលបានរៀបរាប់ខាងលើនេះ សិទ្ធិលើបំណុលឱ្យធ្វើសកម្មភាព សិទ្ធិលើបំណុលមិនឱ្យធ្វើសកម្មភាព និងសិទ្ធិលើបំណុលប្រគល់វត្ថុមិនមានលក្ខណៈសម្រាប់ធ្វើអនុប្បទាននោះទេ **ពីព្រោះសិទ្ធិលើបំណុលទាំងនោះមិនមានតម្លៃសេដ្ឋកិច្ច**សម្រាប់តតិយជន ដោយមិនអាចសម្រេចបាននូវគោលបំណងនៃប្រតិបត្តិការអនុប្បទាន សិទ្ធិលើបំណុលនោះ។

**ហេតុនេះមានតែសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យប្រគល់ប្រាក់តែប៉ុណ្ណោះ ដែលមានលក្ខណៈសមស្របសម្រាប់ការធ្វើអនុប្បទាន**[28]។ បន្ថែមពីនេះទៀត សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យប្រគល់ប្រាក់ គឺកម្រិតត្រឹមសិទ្ធិលើបំណុលដែលកើតចេញពីកិច្ចសន្យាតែប៉ុណ្ណោះ។ ជាទូទៅ សិទ្ធិលើបំណុលដែលមាន

---

[25] មាត្រា ៣០៨, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[26] មាត្រា ៣១៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[27] មាត្រា ៥០១, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[28] ព្រឹត្តិបត្រច្បាប់សាលាត្រាជូ លេខ២, អនុប្បទានសិទ្ធិលើបំណុល ទំព័រទី៤២, ដោយ កញ្ញា តែ មុយគីម

គោលបំណងឱ្យប្រគល់ប្រាក់រួមមាន គណនេយ្យជំពាក់, ប្រាក់ដាក់ក្នុងកុងធនាគារ, ប្រាក់កក់សម្រាប់ជួល, អត្ថប្រយោជន៍ទទួលពីការធានារ៉ាប់រង, សំណងការ ខូចខាត, បំណុល ឬឥណទាន, ប្រាក់ឈ្នួលសម្រាប់ការជួល, ថ្លៃសេវាកម្ម, ប្រាក់ចេញពីការលក់វត្ថុអ្វីមួយ ជាដើម។

**កថាភាគទី២. ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន**

ដោយសារសិទ្ធិលើបំណុលអាចធ្វើអនុប្បទានដោយសេរី ជាគោលការណ៍ការចូលរួមរបស់កូនបំណុល គឺមិនតម្រូវឱ្យមាននោះទេ។ ហេតុដូច្នេះ នៅក្នុងករណីដែលកូនបំណុលមិនមានបំណងឱ្យម្ចាស់បំណុលធ្វើអនុប្បទានសិទ្ធិលើបំណុលទៅឱ្យអ្នកផ្សេងទេ កូនបំណុលតែត្រូវធ្វើការសន្យាពិសេសជាមួយនឹងម្ចាស់បំណុលជាមុន (ជាការបង្ហាញឆន្ទៈអំពីការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន)[29]។ ប៉ុន្តែការសន្យាបែបនេះគ្មានអានុភាពខ្លាំងនោះទេ ដោយសារតែការសន្យាហាមមិនឱ្យធ្វើអនុប្បទានមិនអាចតតាំងចំពោះតតិយជនសុចរិតដែលមិនបានដឹងពីការកម្រិតនេះ និងគ្មានកំហុសធ្ងន់ធ្ងរនោះទេ[30] លុះត្រាតែតតិយជននេះមានកំហុសធ្ងន់ធ្ងរក្នុងការមិនបានដឹង។ បើឈរលើទស្សនៈវិស័យរបស់កូនបំណុល ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទានសិទ្ធិលើបំណុលដោយសារតែមានមូលហេតុមួយចំនួន។ **មូលហេតុទីមួយ** គឺកូនបំណុលហាមឃាត់ការធ្វើអនុប្បទាន ដោយសារតែកូនបំណុលចង់រក្សាសិទ្ធិលើបំណុលសម្រាប់ធ្វើការទូទាត់[31]។ ការទូទាត់ គឺជាវិធីគតិយុត្តមួយដែលនាំឱ្យមានការរលត់កាតព្វកិច្ចរបស់កូនបំណុល ដែលពេលខ្លះត្រូវបានប្រើប្រាស់រវាងកូនបំណុល និងម្ចាស់បំណុល នៅពេលដែលម្ចាស់បំណុល និងកូនបំណុលមានសិទ្ធិលើបំណុលដែលមានប្រភេទដូចគ្នាលើគ្នាទៅវិញទៅមក។ **មូលហេតុទីពីរ** គឺកូនបំណុលចង់ជៀសវាងបញ្ហាការផ្លាស់ប្តូរម្ចាស់បំណុលដែលកូនបំណុលត្រូវសងប្រាក់ ពីព្រោះកូនបំណុលចង់ឱ្យម្ចាស់បំណុលរបស់ខ្លួនត្រូវកំណត់ឱ្យបានជាក់លាក់។ កូនបំណុលអាចចាត់ទុកថាការផ្លាស់ប្តូរម្ចាស់បំណុល គឺជាហានិភ័យក្នុងទំនាក់ទំនងពាណិជ្ជកម្ម ដោយសារតែកូនបំណុលមិនដឹងថាម្ចាស់បំណុលថ្មីអាចជាបុគ្គលដែលសុចរិត ឬទុចរិត ឬក៏កូនបំណុលយល់ឃើញថាការផ្លាស់ប្តូរម្ចាស់បំណុលនឹងនាំឱ្យមានភាពស្មុគស្មាញក្នុងការអនុវត្ត ខ និងលក្ខខណ្ឌនៃការសងប្រាក់ ពីព្រោះ ខ និងលក្ខខណ្ឌដែលកូនបំណុលមានជាមួយនឹងម្ចាស់បំណុលចាស់អាចខុសពី ខ និងលក្ខខណ្ឌដែលម្ចាស់បំណុលចាស់បានព្រមព្រៀងជាមួយនឹងម្ចាស់បំណុលថ្មី។ **មូលហេតុមួយទៀត** ដែលកូនបំណុលហាមឃាត់ការធ្វើអនុប្បទាន គឺកូនបំណុលចង់ជៀសវាងបញ្ហាសងប្រាក់ពីរដង ដោយហេតុថាការសងប្រាក់ពីរដង

[29] មាត្រា ៥០១, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] មាត្រា ៥០១, កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[31] មាត្រា ៤៦៤, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

កើតមាននៅពេលដែលមានការធ្វើអនុប្បទានច្រើនដងចំពោះសិទ្ធិលើបំណុលដដែល ព្រោះនៅពេលដែលមានអនុប្បទានិកច្រើន នៅពេលខ្លះកូនបំណុលមិនអាចកំណត់លំដាប់នៃការបំពេញលក្ខខណ្ឌតតាំងបានទេ ដែល ពេលខ្លះបញ្ហាសងប្រាក់ច្រើនដងទៅអនុប្បទានិកច្រើនអាចកើតមានឡើង។

## ផ្នែកទី២. លក្ខខណ្ឌតតាំង

ជាការពិតណាស់ អនុប្បទាយីត្រូវជូនដំណឹងទៅកូនបំណុល ឬកូនបំណុលត្រូវផ្តល់ការយល់ព្រមដល់អនុប្បទានិក ឬអនុប្បទាយីដើម្បីយកការធ្វើអនុប្បទានសិទ្ធិលើបំណុលទៅតតាំងជាមួយនឹងកូនបំណុល។ ការតតាំងក្នុងន័យនេះ ចង់សំដៅដល់ការដែលអនុប្បទានិកអាចទាមទារឱ្យកូនបំណុលសងបំណុលមកខ្លួនដោយផ្ទាល់ក្នុងនាមជាម្ចាស់បំណុលថ្មី។ ប្រសិនបើអនុប្បទានិកចង់តតាំងជាមួយតតិយជន អនុប្បទាយីត្រូវជូនដំណឹងទៅកូនបំណុល ឬទទួលបានការយល់ព្រមពីកូនបំណុលតាមរយៈ**លិខិតជូនដំណឹងដែលមានកាលបរិច្ឆេទស្ពាព**[32]។ យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មិនអនុញ្ញាតឱ្យអនុប្បទានិកជាអ្នកអនុវត្តលក្ខខណ្ឌតតាំងនោះទេ ពីព្រោះគេមានគោលបំណងការពារការបោកប្រាស់កូនបំណុល។ ក្នុងករណីអនុញ្ញាតឱ្យអនុប្បទានិកជាអ្នកជូនដំណឹងទៅកូនបំណុលពីការធ្វើអនុប្បទានវិញ អនុប្បទានិកក្លែងក្លាយអាចជូនដំណឹងទៅកូនបំណុលថាសិទ្ធិលើបំណុលត្រូវបានអនុប្បទាយីផ្ទេរមកឱ្យខ្លួន ហើយធ្វើការទាមទារឱ្យកូនបំណុលសងប្រាក់ឱ្យខ្លួន[33]។

ចំពោះគោលគំនិតដើមនៃការយកការជូនដំណឹងធ្វើជាលក្ខខណ្ឌតតាំង គឺយកលំនាំតាមលក្ខខណ្ឌតតាំងរបស់ចលនវត្ថុ។ ជាទូទៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ កម្មវត្ថុនៃប្រតិបត្តិការនីមួយៗកំណត់ពីរបៀបនៃលក្ខខណ្ឌតតាំង ប្រសិនបើកម្មវត្ថុជាអចលនវត្ថុ លក្ខខណ្ឌតតាំងត្រូវធ្វើឡើងដោយការចុះបញ្ជី។ ដោយឡែកបើកម្មវត្ថុជាចលនវត្ថុ អនុប្បទានិកត្រូវតែទទួលបានការផ្ទេរការកាន់កាប់កម្មវត្ថុដើម្បីតតាំងជាមួយតតិយជន[34] ដោយសារតែសិទ្ធិលើបំណុលត្រូវបានចាត់ទុកជាចលនវត្ថុអរូបី លក្ខខណ្ឌតតាំងត្រូវអនុវត្តតាមលក្ខខណ្ឌតតាំងរបស់ចលនវត្ថុដូច្នេះការជូនដំណឹងត្រូវចាត់ទុកថាជាការប្រគល់សិទ្ធិលើបំណុល [35]។

[32] មាត្រា៨ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

[33] ព្រឹត្តិបត្រច្បាប់សាលាត្រាជូ លេខ២, អនុប្បទានសិទ្ធិលើបំណុល ទំព័រទី៤៤, ដោយ កញ្ញា តែ មុយគីម

[34] មាត្រា ១៣៤, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[35] ព្រឹត្តិបត្រច្បាប់សាលាត្រាជូ លេខ២, អនុប្បទានសិទ្ធិលើបំណុល ទំព័រទី៤៥, ដោយ កញ្ញា តែ មុយគីម

**កថាភាគទី១. ការតតាំងចំពោះកូនបំណុល**

ការតតាំងនឹងកូនបំណុលមិនមែនជាលក្ខខណ្ឌសាមញ្ញធម្មតា ដែលតែងតែជួបប្រទះក្នុងប្រតិបត្តិការក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ នោះទេ។ ទោះបីជាកិច្ចសន្យា អនុប្បទានមានអានុភាពដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលក៏ដោយ ក៏កូនបំណុលនៅតែត្រូវបានជូនដំណឹងដែរ ពីព្រោះកូនបំណុលត្រូវដឹងពីអត្ថិភាពនៃអនុប្បទានសិទ្ធិលើបំណុល ដើម្បីឱ្យអនុប្បទានិកអាចទទួលបានការសងពីកូនបំណុល ហើយវាក៏ចាំបាច់ដើម្បីបង្ការការសងប្រាក់ពីរដងទៅអនុប្បទានិកផង និងអនុប្បទាយីផង។ ចំពោះការបង្ហាញការយល់ព្រមរបស់កូនបំណុល វាមិនមែនជាលក្ខខណ្ឌអានុភាពនៃកិច្ចព្រមព្រៀងអនុប្បទានទេ តែវាជាការបង្ហាញពីអត្តចរិកវិជ្ជមានរបស់កូនបំណុលចំពោះការធ្វើអនុប្បទាន[36]។

ជាគោលការណ៍ អនុប្បទានសិទ្ធិលើបំណុលដែលមានឈ្មោះមិនអាចធ្វើការតតាំងចំពោះកូនបំណុល ឬតតិយជនផ្សេងទៀតបានឡើយ ប្រសិនបើអនុប្បទាយីមិនបានជូនដំណឹងទៅកូនបំណុលពីអនុប្បទាននេះ ឬកូនបំណុលមិនបានផ្តល់នូវការយល់ព្រមអំពីអនុប្បទាននេះចំពោះអនុប្បទាយី ឬអនុប្បទានិក[37]។ នៅក្នុងអត្ថន័យនេះមានន័យថា កូនបំណុលអាចប្រកែកក្នុងការសងបំណុលទៅអនុប្បទានិកបានរហូតដល់មានការជូនដំណឹង ឬការយល់ព្រម។ បន្ទាប់ពីកូនបំណុលទទួលការជូនដំណឹង ឬផ្តល់ការយល់ព្រមរួច កូនបំណុលត្រូវសងបំណុលទៅអនុប្បទានិក។ ចំពោះទម្រង់នៃការជូនដំណឹង ឬការយល់ព្រម ពុំមានបញ្ជាក់ច្បាស់លាស់អំពីទម្រង់នោះទេ ហេតុដូច្នេះ ចំពោះការជូនដំណឹង ឬការយល់ព្រមអាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក៏បាន។

**កថាភាគទី២. ការតតាំងចំពោះតតិយជន**

ទោះបីជាយ៉ាងណាក្តី ការជូនដំណឹង ឬការយល់ព្រម មិនអាចតតាំងនឹងតតិយជនក្រៅពីកូនបំណុលបានឡើយ បើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ[38]។ បានសេចក្តីថា នៅក្នុងប្រតិបត្តិការអនុប្បទានសិទ្ធិលើបំណុល ការតតាំងធ្វើឡើងដោយការជូនដំណឹងតាមរយៈលិខិតដែលមានកាលបរិច្ឆេទស្ថាពរ ឬទទួលបានការអនុញ្ញាតពីកូនបំណុល។ ដូចគ្នាផងដែរ កូនបំណុលក៏ត្រូវផ្តល់ការយល់ព្រមតាមរយៈលិខិតដែលមានកាលបរិច្ឆេទស្ថាពរផងដែរ។ សូមបញ្ជាក់ផងដែរថា ការយល់ព្រមដើម្បីតតាំងជាមួយកូនបំណុលមិនចាំបាច់ឱ្យមានកាលបរិច្ឆេទស្ថាពរនោះទេ ពីព្រោះកូនបំណុលមានតែម្នាក់ ប៉ុន្តែការយល់ព្រមដើម្បី

[36] ព្រឹត្តិបត្រច្បាប់សាលាក្រោដូ លេខ២, អនុប្បទានសិទ្ធិលើបំណុល ទំព័រទី៤៧, ដោយ កញ្ញា តែ មុយគីម

[37] មាត្រា ៥០៣, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[38] មាត្រា ៥០៣, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

តតាំងជាមួយតតិយជនត្រូវតែមានកាលបរិច្ឆេទស្ថាពរ ដោយសារតែវាអាចមានប្រកួតប្រជែងរវាងអនុប្បទានិកច្រើននាក់។

ក្នុងករណីសិទ្ធិលើបំណុលត្រូវបានធ្វើអនុប្បទានដល់**បុគ្គលពីរនាក់ ឬច្រើននាក់** ប្រសិនបើអនុប្បទានិកណាដែលបានបំពេញលក្ខខណ្ឌតតាំង (ការជូនដំណឹង ឬការយល់ព្រមដែលមានចុះកាលបរិច្ឆេទស្ថាពរ) មុនគេត្រូវមានអាទិភាពដោយកំណត់ទៅតាមលំដាប់នៃការជូនដំណឹង ដែលធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរបានដល់កូនបំណុល ឬពេលដែលកូនបំណុលបានយល់ព្រមដោយលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។ ហេតុនេះ កូនបំណុលត្រូវសងបំណុលទៅអនុប្បទានិកដែលមានអាទិភាព[39]។

ដោយឡែក ក្នុងករណីដែលមិនអាចកំណត់លំដាប់នៃពេលដែលការជូនដំណឹងនីមួយៗបានដល់ ឬពេលដែលកូនបំណុលបានយល់ព្រមទេ ត្រូវចាត់ទុកថាការជូនដំណឹងនីមួយៗបានដល់កូនបំណុលនៅពេលជាមួយគ្នា ឬកូនបំណុលបានយល់ព្រមជាមួយគ្នា។ ដូច្នេះហើយ អនុប្បទានិកនីមួយៗអាចធ្វើការទាមទារឱ្យកូនបំណុលបានសងចំពោះសិទ្ធិលើបំណុលទាំងអស់ដែលខ្លួនបានទទួលអនុប្បទាន[40]។

## ផ្នែកទី៣. ការទទួលកាតព្វកិច្ច

ការទទួលកាតព្វកិច្ច សំដៅលើការផ្ទេរបន្ទុកពីកូនបំណុលដែលមានចំពោះម្ចាស់បំណុលទៅឱ្យតតិយជនក្រៅពីកូនបំណុលដោយកិច្ចព្រមព្រៀង។ ផ្ទុយទៅវិញ គូភាគីអាចហាមឃាត់មិនឱ្យតតិយជនទទួលកាតព្វកិច្ចបានឡើយដោយការបង្ហាញឆន្ទៈ[41] មានន័យថា គូភាគីអាចធ្វើការហាមឃាត់មិនឱ្យភាគីម្ខាងទៀតផ្ទេរកាតព្វកិច្ចបាន។

### កថាភាគទី១. លក្ខខណ្ឌដើម្បីបង្កើតនូវការទទួលកាតព្វកិច្ច

កាតព្វកិច្ច ជាសិទ្ធិមួយដែលមានលក្ខណៈមិនដាច់ខាតដោយមិនអាចយកទៅតតាំងជាមួយនរណាមួយក្រៅពីកូនបំណុល ឬម្ចាស់បំណុលបានទេដែលវាមានភាពខុសប្លែកពីសិទ្ធិប្រត្យក្សដោយអាចយកទៅតតាំងគ្រប់បុគ្គលទាំងអស់។ ដោយសារតែវាមានលក្ខណៈបែបនេះហើយបានជាក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបង្កើតនៅយន្តការដោះស្រាយក្នុងករណីដែលកូនបំណុលពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តកាតព្វកិច្ចក្រោយការបង្កើតកិច្ចសន្យា ឬករណីដែលចង់ឱ្យតតិយជនមកអនុវត្តកាតព្វជំនួស។

[39] សៀវភៅនីតិកាតពក្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ ៖ មេធាវី ហេង ប៉ូរ៉ា, ទំព័រទី១៥៣

[40] មាត្រា ៥០៤, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[41] មាត្រា ៥០៧, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដើម្បីឱ្យតតិយជនអាចអនុវត្តកាតព្វកិច្ចជំនួសកូនបំណុលបានត្រូវតែបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជា៖

- **ការព្រមព្រៀង**[42] : មានតែកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគីតែប៉ុណ្ណោះដែលជាកម្មវត្ថុនាំឱ្យមានការទទួលកាតព្វកិច្ច ដោយសារកាតព្វកិច្ចមួយនេះវាកើតឡើងដោយឆន្ទៈរបស់ភាគីក្នុងការបង្កើតឱ្យមាននូវករណីកិច្ចរវាងម្ចាស់បំណុល និងកូនបំណុល។ ដើម្បីឱ្យការទទួលកាតព្វកិច្ច អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីសំណាក់ភាគីបីរូបដូចជា **ម្ចាស់បំណុល កូនបំណុល និងអ្នកទទួល (តតិយជន)**។

***ឧទាហរណ៍៖*** *លោក ក មានសិទ្ធិលើបំណុលចំពោះលោក ខ ចំនួន ១០០០ ដុល្លាអាមេរិក តាមរយៈកិច្ចសន្យាខ្ចីបរិភោគ ដោយកំណត់សងនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១។ មុនពេលសងមក ដល់ចំនួន ៦ ខែ ស្រាប់តែលោក ខ ដែលជាអ្នកខ្ចីចង់ឱ្យលោកស្រី គ ធ្វើការអនុវត្តកាតព្វកិច្ចជំនួស។ នៅក្នុងករណីបែបនេះ លោក ខ អាចរួចផុតពីការអនុវត្តកាតព្វកិច្ចបាន លុះត្រាតែមានការយល់ព្រមព្រៀងពីម្ចាស់បំណុល (លោក ក) និងលោកស្រី គ (តតិយជន)។*

- **កាតព្វកិច្ចអាចអនុវត្តបាន**[43] : ប្រសិនបើកាតព្វកិច្ចត្រូវបានបង្កើតឡើង នោះនាំឱ្យភាគីរវាងកូនបំណុល និងម្ចាស់បំណុលត្រូវមានកាតព្វកិច្ចអនុវត្តឱ្យស្របតាមខ្លឹមសារនាពេលបង្កើត ប៉ុន្តែទោះបីជាបែបនេះក្តី កាតព្វកិច្ចមួយចំនួនកូនបំណុលអាចឱ្យតតិយជនជាអ្នកអនុវត្តជំនួសក៏បានដែរ ឱ្យតែកាតព្វកិច្ចអាចអនុវត្តដោយតតិយជនបាន។ តែផ្ទុយមកវិញ ប្រសិនបើកាតព្វកិច្ចដែលម្ចាស់បំណុល និងកូនបំណុលបានបង្កើតឡើងដោយមិនអាចឱ្យតតិយជនអនុវត្តជំនួសបានទេ បើទោះបីជាមានការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ព្រមទាំងតតិយជនក៏ដោយ ក៏មិនអាចប្រព្រឹត្តទៅបានដែរ។

***ឧទាហរណ៍៖*** *លោក ក បានបង្កើតកិច្ចសន្យាម៉ៅការជាមួយលោក ខ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ដោយមានកម្មវត្ថុតម្រូវឱ្យលោក ខ ដែលជាជាងគំនូរធ្វើការគូររូបប្រាសាទអង្គរវត្តដោយកំណត់តម្លៃ ១៥០០ ដុល្លាអាមេរិក និងត្រូវប្រគល់នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២។ ក្រោយបង្កើត កិច្ចសន្យាបាន១០ ថ្ងៃ ស្រាប់តែលោក ខ បានជួបគ្រោះថ្នាក់ចរាចរណ៍បណ្តាលឱ្យបាក់ដៃ ដោយមានការបញ្ជាក់ពីសំណាក់ក្រុមគ្រូពេទ្យថាលោក ខ នឹងជាសះស្បើយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ ជាកត្តានាំឱ្យលោក ខ មិនអាចអនុវត្តកាតព្វកិច្ចចំពោះលោក ក ឱ្យបានទាន់ពេលវេលា ហើយកាតព្វកិច្ចនោះក្លាយជាអលទ្ធភាពក្នុងការអនុវត្ត។ លោក ខ មិនអាចឱ្យតតិយជនផ្សេងមកអនុវត្តកាតព្វកិច្ចជំនួសបានទេ ព្រោះកាតព្វកិច្ចមិនមានលក្ខណៈអាច*

[42] មាត្រា ៥០៨, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[43] មាត្រា ៥០៧, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

*ឱ្យតតិជនអនុវត្តបាននោះទេ ដោយសារស្នាដៃការគូរគំនូរមិនមានលក្ខណៈដូចគ្នានោះទេ ជាពិសេសឈ្មោះអ្នកស្នាដៃតែម្តង។*

- **គ្មានការសន្យាពិសេស**[44] : មានតែកាតព្វកិច្ចដែលកើតឡើងដោយភាគីតែប៉ុណ្ណោះ ដែលជាកម្មវត្ថុនាំឱ្យតតិយជនមកអនុវត្តកាតព្វកិច្ចចំពោះកូនបំណុល និងម្ចាស់បំណុល ក៏ប៉ុន្តែប្រសិនបើកូនបំណុល ឬម្ចាស់បំណុលបានធ្វើការដាក់ខសន្យាពិសេសពុំឱ្យតតិយជនអនុវត្តជំនួសកូនបំណុល ប្រាកដណាស់កូនបំណុលគ្មានជម្រើសក្រៅពីការអនុវត្តដោយខ្លួនឯងនោះទេ។ កាតព្វកិច្ចកើតឡើងដោយឆន្ទៈរបស់គូភាគី អាស្រ័យលើគូភាគីអាចដាក់ខសន្យាបែបណាក៏បានឱ្យតែខ្លួនឃើញមានប្រយោជន៍សម្រាប់ខ្លួន ប៉ុន្តែការដាក់ខសន្យាត្រូវធ្វើយ៉ាងណាក៏ដោយកុំឱ្យតែបំពាន ទៅលើភាគីម្ខាងទៀតដែលនាំឱ្យមានការលុបចោល ឬមោឃៈភាព។

### កថាភាគទី២. អានុភាពនៃការទទួលការកាតព្វកិច្ច

ជាគោលការណ៍ នៅពេលដែលលក្ខខណ្ឌនៃការទទួលកាតព្វកិច្ចត្រូវបានបំពេញនាំឱ្យមានអានុភាពចំពោះម្ចាស់បំណុល កូនបំណុល និងទទួលកាតព្វកិច្ច។

- **សិទ្ធិរបស់ម្ចាស់បំណុល** : ទោះបីជាមានការទទួលកាតព្វកិច្ចដោយតតិយជនក៏ដោយ ក៏ម្ចាស់បំណុលមិនបាត់បង់នូវសិទ្ធិទទួលការសងចំពោះកូនបំណុលដែរ[45]។ ក៏ប៉ុន្តែ ប្រសិនបើម្ចាស់បំណុល និងអ្នកទទួលកាតព្វកិច្ច (តតិយជន) បានធ្វើការយល់ព្រមឱ្យកូនបំណុល រួចផុតពីកាតព្វកិច្ចហើយនោះដូច្នេះកូនបំណុលមិនមានកាតព្វកិច្ចអនុវត្តចំពោះម្ចាស់បំណុលទៀតឡើយ ហើយម្ចាស់បំណុលក៏មិនអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចបានដែរ។ ចំពោះអ្នកដែលត្រូវអ្នកអនុវត្តកាតព្វកិច្ចជំនួសកូនបំណុលនោះ សំដៅលើអ្នកទទួលកាតព្វកិច្ច (តតិយជន) ដោយត្រូវមានកាតួកិច្ចដូចកូនបំណុលដែលធ្លាប់មានជាមួយម្ចាស់បំណុលពីមុនមក[46]។

***ឧទាហរណ៍៖*** *លោក ក ជាអ្នកឱ្យខ្ចីបានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយលោក ខ ជាអ្នកខ្ចី នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងចំនួនទឹកប្រាក់ ៥០០០ដុល្លាអាមេរិក ហើយកំណត់សងនៅថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១៨ ។ នៅខ្វះតែមួយខែទៀតដល់ថ្ងៃអនុវត្តកាតព្វកិច្ច លោក ខ មានបញ្ហាសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង ដោយឃើញបែបនេះលោក គ ដែលត្រូវជាមិត្តភក្តិរបស់លោក ខ មានចិត្តអាណិតយ៉ាងខ្លាំង ក៏បានស្នើសុំលោក ក និងលោក ខ*

[44] មាត្រា ៥០៧, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[45] មាត្រា ៥០៩, កថាខណ្ឌទី១, វាក្យខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[46] មាត្រា ៥០៩, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

*ដើម្បីធ្វើការអនុវត្តកាតព្វកិច្ចជំនួស ហើយលោក ក និងលោក ខ ក៏បានយល់ព្រម។ នៅថ្ងៃកំណត់សងមកដល់ លោក គ ក៏បានអនុវត្តកាតព្វកិច្ចជំនួសលោក ខ។ អាស្រ័យហេតុនេះមានតែលោក គ តែប៉ុណ្ណោះជាអ្នកអនុវត្តកាតព្វកិច្ចចំពោះលោក ក ដែលជាម្ចាស់បំណុល។*

- **ចំពោះកូនបំណុល** : ប្រសិនបើមានករណីការទទួលកាតព្វកិច្ចកើតឡើង នោះនឹងនាំឱ្យកូនបំណុលអាចរួចផុតពីកាតព្វកិច្ចទាំងមូល ឬមួយផ្នែក។ នៅក្នុងករណីដែលមានអ្នកទទួលកាតព្វកិច្ច (តតិយជន) ចំពោះកូនបំណុល ប៉ុន្តែការទទួលកាតព្វកិច្ចនោះពុំនាំឱ្យកូនបំណុលរួចផុតពីការអនុវត្តកាតព្វកិច្ចនោះទេ អ្នកទទួលកាតព្វកិច្ច (តតិយជន) និងកូនបំណុលត្រូវអនុវត្តកាតព្វកិច្ចដោយសាមគ្គីគ្នា[47]។ ដោយឡែកប្រសិនបើអ្នកទទួលកាតព្វកិច្ចបានឱ្យកូនបំណុលរួចផុតពីការអនុវត្តកាតព្វកិច្ច ដោយមានការយល់ព្រមពីម្ចាស់បំណុលបន្ថែមទៀតនោះ អ្នកដែលត្រូវអនុវត្តកាតព្វកិច្ចចំពោះម្ចាស់បំណុលមានតែអ្នកទទួលកាតព្វកិច្ចជំនួសកូនបំណុលតែប៉ុណ្ណោះដែលជាអ្នកអនុវត្តកាតព្វកិច្ច។
- **ចំពោះអ្នកទទួលកាតព្វកិច្ច** : អ្នកទទួលត្រូវមានកាតព្វកិច្ចចំពោះម្ចាស់បំណុលដូចអ្វីដែលកូនបំណុលធ្លាប់មានពីមុនមកជាមួយម្ចាស់បំណុល។ បើក្រឡេកទៅមើលមាត្រា ៥០៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ការបង្កើតនូវការទទួលកាតព្វកិច្ចអាចធ្វើឡើងដោយមានតែការព្រមព្រៀងរវាងម្ចាស់បំណុល និងអ្នកទទួលក៏មានអានុភាពដែរ ហេតុដូចនេះម្ចាស់បំណុលមិនអាចទាមទារឱ្យអ្នកទទួលធ្វើការអនុវត្តកាតព្វកិច្ចបានទេ។ ក្នុងករណីកូនបំណុលបានអនុវត្តកាតព្វកិច្ចមួយចំនួនចំពោះម្ចាស់បំណុលរួចមកហើយ អ្នកទទួលមានករណីកិច្ចអនុវត្តកាតព្វកិច្ចដែលនៅសេសសល់តែប៉ុណ្ណោះ។ ប្រសិនបើម្ចាស់បំណុលនៅតែទាមទារឱ្យអ្នកទទួលអនុវត្តកាតព្វកិច្ចដែលកូនបំណុលធ្លាប់អនុវត្តពីមុនរួចមកហើយនោះ អ្នកទទួលអាចយកការអនុវត្តកាតព្វកិច្ចដោយកូនបំណុលចំពោះម្ចាស់បំណុលមកធ្វើការតតាំងបាន[48]។

### កថាភាគទី៣. ការទទួលការអនុវត្តកាតព្វកិច្ច និងការតវ៉ាក្នុងការទទួលកាតព្វកិច្ច

ជាការពិតណាស់ នៅពេលដែលកាតព្វកិច្ចកើតមានឡើងប្រាកដណាស់នាំឱ្យកូនបំណុលមានករណីយកិច្ចអនុវត្តចំពោះម្ចាស់បំណុលមួយចំនួន។ បើទោះបីជាយ៉ាងក្តីក៏មានករណីលើកលែងផងដែរ ក្នុងករណីដែលកូនបំណុលចង់ឱ្យតតិយជនមកធ្វើការអនុវត្តជំនួសបានផងដែរ។

[47] មាត្រា ៥០៩, កថាខណ្ឌទី២, វាក្យខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[48] មាត្រា ៥១០, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.១. ការទទួលការអនុវត្តកាតព្វកិច្ច

ប្រសិនបើអ្នកទទួលមិនទទួលកាតព្វកិច្ច តែបានទទួលគ្រាន់តែការអនុវត្តកាតព្វកិច្ចតែប៉ុណ្ណោះតាមការព្រមព្រៀងគ្នារវាងកូនបំណុល និងអ្នកទទួល នោះម្ចាស់បំណុលមិនអាចទាមទារឱ្យអ្នកទទួលនោះអនុវត្តកាតព្វកិច្ចបានឡើយ[49]។ មានន័យថា អ្នកទទួលគ្រាន់តែបានទទួលការអនុវត្តកាតព្វកិច្ចក្នុងការបំពេញកិច្ចការណាមួយពីកូនបំណុលតែប៉ុណ្ណោះ ដោយមិនមែនជាអ្នកទទួលកាតព្វកិច្ចទាំងស្រុងនោះទេ។ លើសពីនេះកូនបំណុលនៅតែជាអ្នកមានកាតព្វកិច្ចរបស់ខ្លួនចំពោះម្ចាស់បំណុលដដែល។

### ៣.២. ការតវ៉ាក្នុងការទទួលកាតព្វកិច្ច

ក្រោយពេលដែលការទទួលកាតព្វកិច្ចមានអានុភាព នាំឱ្យអ្នកទទួលត្រូវតែអនុវត្តកាតព្វកិច្ចជំនួសកូនបំណុល។ ក្នុងន័យនេះមិនមែនអ្នកទទួលកាតព្វកិច្ចត្រូវអនុវត្តកាតព្វកិច្ចដែលកូនបំណុលមានទាំងអស់ពីមុននោះទេ អ្នកទទួលអាចយកហេតុផលដែលកូនបំណុលធ្លាប់អនុវត្តចំពោះម្ចាស់បំណុលពីមុនមកយកទៅតតាំងចំពោះម្ចាស់បំណុលបាន[50]។

## ផ្នែកទី៤. អនុប្បទានឋានៈក្នុងកិច្ចសន្យា

ជាគោលការណ៍ ភាគីណាមួយនៃកិច្ចសន្យាអាចធ្វើអនុប្បទាន (ផ្ទេរ) ឋានៈក្នុងកិច្ចសន្យារបស់ខ្លួនទៅតតិយជនបានដោយមិនចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតឡើយ។ ចំពោះឋានៈក្នុងកិច្ចសន្យារួមមាន **ឋានៈជាម្ចាស់បំណុល និងឋានៈជាកូនបំណុល** ។ ក្នុងករណីដែលការធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរបុគ្គលដែលមានបំណងធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យានោះ ត្រូវទទួលការយល់ព្រមអំពីអនុប្បទាននោះពីភាគីម្ខាងទៀតនៃកិច្ចសន្យានោះ[51]។

### កថាភាគទី១. លក្ខខណ្ឌដើម្បីបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា

ចំពោះអនុប្បទានឋានៈក្នុងកិច្ចសន្យា ត្រូវតែបំពេញនូវលក្ខខណ្ឌចាំបាច់មួយចំនួនដើម្បីធ្វើឱ្យមានអានុភាពដោយស្របទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

- **ការព្រមព្រៀង** : សិទ្ធិលើបំណុលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងកូនបំណុល និងម្ចាស់បំណុល តែប្រសិនបើម្ចាស់បំណុលចង់ធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាទៅឱ្យតតិយជនណាមួយ

[49] មាត្រា ៥១១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[50] មាត្រា ៥១០, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[51] មាត្រា ៥១២, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

គឺមិនចាំបាច់មានការយល់ព្រមពីកូនបំណុលនោះទេ ដោយសារតែក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ តម្រូវឱ្យមានតែការយល់ព្រមពីម្ចាស់បំណុល និងតតិយជនតែប៉ុណ្ណោះ។ បើទោះបីយ៉ាងណាក្តី ការព្រមព្រៀងចំពោះករណីមួយចំនួនមិនអាចធ្វើបានទេចំពោះអនុប្បទានឋានៈក្នុងកិច្ចសន្យា ដោយហេតុថាការធ្វើនោះមិនមានលក្ខណៈស្របតាមកិច្ចសន្យា។ បន្ថែមពីលើនេះដើម្បីបង្កើតជាលក្ខខណ្ឌតតាំងចំពោះកូនបំណុល តម្រូវឱ្យម្ចាស់បំណុលត្រូវតែធ្វើការជូនដំណឹងទៅកូនបំណុលជាមុន។ ចំណែកឯការលក្ខខណ្ឌតតាំងចំពោះតតិយជនវិញ ការជូនដំណឹងមិនអាចទទួលបានទេ ប្រសិនបើការជូនដំណឹងនោះមិនបានធ្វើជាលិខិតដែលមានកាលបរិច្ឆេទស្ពាល[52]។

- **គ្មានការសន្យាពិសេស** : បើទោះជាម្ចាស់បំណុលអាចធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលក៏ដោយ ប្រសិនបើនៅពេលភាគីម្ចាស់បំណុល និងកូនបំណុលបានបង្កើតកិច្ចសន្យា ហើយបានធ្វើការដាក់លក្ខខណ្ឌហាមឃាត់មិនឱ្យធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាទៅឱ្យតតិយជន ដូច្នេះម្ចាស់បំណុលមិនអាចធ្វើបានទេ បើទោះបីជាមានច្បាប់ចែងក៏ដោយ ព្រោះវាជាការសម្តែងឆន្ទៈរបស់ភាគីក្នុងការហាមឃាត់[53]។ តែផ្ទុយទៅវិញ ប្រសិនបើតតិយជនបានទទួលការធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យា ហើយមិនបានដឹងអំពីការហាមឃាត់រវាងម្ចាស់បំណុល និងកូនបំណុលអំពីការធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាទេ កូនបំណុលមិនអាចតតាំងជាមួយតតិយជនបានទេ លើកលែងតែតតិយជននោះមានកំហុសធ្ងន់ធ្ងរ[54]។

### កថាភាគទី២. លក្ខខណ្ឌតតាំង

ដើម្បីតតាំងចំពោះភាគីម្ខាងទៀតនៃកិច្ចសន្យា និងតតិយជន អនុប្បទាននេះតម្រូវឱ្យមានលក្ខខណ្ឌតតាំងដែលបានកំណត់ក្នុងមាត្រា ៥០៣ (លក្ខខណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ[55]។ មានន័យថា អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មិនធ្វើការតតាំងជាមួយចំពោះកូនបំណុល ឬតតិយជនផ្សេងទៀតបានទេ បើអនុប្បទាយីមិនបានជូនដំណឹងទៅកូនបំណុលអំពីអនុប្បទាននេះ ឬកូនបំណុលមិនបានផ្តល់នូវការយល់ព្រមអំពីទម្រង់នៃការជូនដំណឹង ឬការយល់ព្រម។ ដោយហេតុថាការជូនដំណឹង ឬការយល់ព្រមអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បាន។ ដរាបណាលក្ខខ័ណ្ឌនេះត្រូវបានបំពេញ ហេតុដូចនេះហើយអនុប្បទានិកអាចតតាំងអនុប្បទានសិទ្ធិលើបំណុល

52 មាត្រា ៥០៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
53 មាត្រា ៥០១, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
54 មាត្រា ៥០១, កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
55 មាត្រា ៥០៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជាមួយកូនបំណុលបាន ហើយអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចក្នុងនាមជាម្ចាស់បំណុលថ្មី។ ផ្ទុយមកវិញ ដើម្បីធ្វើការតតាំងអនុប្បទានសិទ្ធិ លើបំណុលចំពោះតតិយជនដែលមិនមែនជាកូនបំណុល (ឧទាហរណ៍៖ តតិយជនដែលអះអាងថាខ្លួនបានទទួលអនុប្បទានសិទ្ធិលើបំណុល) ចំពោះការជូនដំណឹង ឬការយល់ព្រម ត្រូវតែធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្តាពរ។ ក្នុងន័យនេះ លិខិតដែលមានកាលបរិច្ឆេទស្តាពរ សំដៅទៅលើឯកសារដែលមានភាពច្បាស់លាស់ និងភាពត្រឹមត្រូវនៃកាលបរិច្ឆេទដែលត្រូវបានសរសេរលើឯកសារនោះត្រូវបានធានាដូចជាឯកសារដែលបានរៀបចំដោយស្ថាប័នរដ្ឋ ឬលិខិតយថាភូត ដែលរៀបចំដោយសារការី ជាដើម។

## កថាភាគទី៣. អានុភាពនៃអនុប្បទានឋានៈក្នុងកិច្ចសន្យា

ជាគោលការណ៍ ប្រសិនបើអនុប្បទានឋានៈក្នុងកិច្ចសន្យាត្រូវបានធ្វើឡើង ដូច្នេះសិទ្ធិ និងកាតព្វកិច្ចទាំងអស់ដែលអនុប្បទាយីធ្លាប់មាន (សិទ្ធិលុបចោល សិទ្ធិរំលាយ) ត្រូវផ្ទេរទៅអនុប្បទានិក លើកលែងតែមានការបង្ហាញឆន្ទៈពិសេស[56]។

- **ចំពោះការជូនដំណឹង និងការយល់ព្រម**[57] : ប្រសិនបើកូនបំណុលបានទទួលការជូនដំណឹង និងបានឆ្លើយយល់ព្រមទៅម្ចាស់បំណុលឱ្យមានការធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យា វាបានធ្វើឱ្យកូនបំណុលបាត់បង់នូវលក្ខខណ្ឌតតាំងជាមួយម្ចាស់បំណុល បើទោះបីជាខ្លួនអាចមានហេតុណាមួយយកមកតតាំងជាមួយក៏ដោយ។ ដោយឡែកប្រសិនម្ចាស់បំណុលបានត្រឹមតែជូនដំណឹងទៅតតិយជន ដោយមិនបានជូនដំណឹងទៅកូនបំណុលទេ ដូច្នេះកូនបំណុលអាចយកហេតុនោះមកតតាំងជាមួយតតិយជនបាន។
- **ការតវ៉ា និងការអនុវត្ត**[58] : ក្នុងករណីដែលការធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាត្រូវបានកើតឡើងប្រាកដណាស់នឹងនាំឱ្យមានការផ្លាស់ប្តូរម្ចាស់បំណុលថ្មីមកជំនួស ហេតុនេះកូនបំណុលអាចយកហេតុផលទាំងឡាយណាដែលខ្លួនធ្លាប់ធ្វើចំពោះម្ចាស់បំណុលម្ចាស់បំណុលចាស់មកតតាំងជាមួយម្ចាស់បំណុលថ្មីបាន។

***ឧទាហរណ៍៖*** *លោក ក ជាម្ចាស់បំណុលលោក ខ ចំនួន ១០០០០$ តាមរយៈកិច្ចសន្យា ខ្ចីបរិភោគ បង្កើតឡើងនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ ដោយកំណត់សងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២០។ នៅពេលខ្ចីបានកន្លះឆ្នាំលោក ខ បានយកប្រាក់ចំនួន ២០០០$ ទៅសងលោក ក ហើយគាត់ក៏បានយល់*

[56] មាត្រា ៥១៤, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[57] មាត្រា ៥០៥, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[58] មាត្រា ៥១០, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

*ព្រមទទួល នាពេលមួយខែបន្ទាប់លោក ក បានធ្វើអនុប្បទានឋានៈក្នុង កិច្ចសន្យាឱ្យទៅលោក គ ដោយមានការយល់ព្រមពីលោក ខ ។ អាស្រ័យហេតុនេះ លោក គ ជាអ្នកមានសិទ្ធិទទួលការសងពីលោក ខ ចំនួន ៨០០០$ ដែលនៅសល់ តែប្រសិនបើ គ ទាមទារឱ្យអនុវត្តកាតព្វកិច្ចចំនួន ១០០០០$ នោះ លោក ខ អាចយកហេតុដែលខ្លួនធ្លាប់បានអនុវត្តចំពោះម្ចាស់បំណុលពីមុនមកតតាំងបាន។*

-

# ជំពូកទី៣
# របបគតិយុត្តនៃការរំលត់សិទ្ធិ
# លើបំណុល

# ជំពូកទី៣

# របបគតិយុត្តនៃការរំលត់សិទ្ធិលើបំណុល

## ផ្នែកទី១. ការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពគូភាគី

ចំពោះការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពគូភាគី សំដៅដល់ស្ថានភាពមួយដែលភាគីជាអ្នកធ្វើឱ្យកាតព្វកិច្ចនោះរលត់ដោយប្រើប្រាស់នូវលក្ខខណ្ឌ ឬបំពេញលក្ខខណ្ឌសំខាន់ៗដូចជា៖ **ការសង ការទូទាត់ ការលើកលែង នវកម្ម** ឬ**ព្យាកុលភាព**ជាដើម។

### កថាភាគទី១. ការសង

ការសង សំដៅទៅលើសកម្មភាពរំលត់កាតព្វកិច្ចតាមរយៈការបំពេញនូវខ្លឹមសារនៃកាតព្វកិច្ច ពោលគឺសំដៅលើអនុវត្តកាតព្វកិច្ចនោះឯង[59]។

#### ១.១. អ្នកសង

ជាគោលការណ៍ កូនបំណុល គឺជាអ្នកដែលមានកាតព្វកិច្ចត្រូវសងទៅម្ចាស់បំណុល។ ក៏ប៉ុន្តែត្រង់ចំណុចនេះមិនមានលក្ខខណ្ឌដាច់ខាតនោះទេ ចំពោះការសងក៏អាចធ្វើឡើងដោយតតិយជនបានផងដែរ ក្នុងករណីដែលគោលបំណងនៃការរំលត់កាតព្វកិច្ចអាចសម្រេចដោយការសងរបស់តតិយជនបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់បំណុលជាមុនសិន[60]។ បន្ថែមពីនេះ ម្ចាស់បំណុល និងកូនបំណុលអាចធ្វើការព្រមព្រៀងគ្នាជាមុនមិនទទួលស្គាល់ការសងដោយតតិយបាន[61] ព្រោះថាការសងរបស់តតិយជននោះផ្ទុយនឹងឆន្ទៈរបស់ភាគីម្ខាងទៀតនៃកិច្ចសន្យា ជាអាទិ៍។

***ឧទាហរណ៍៖*** *ចំពោះកិច្ចសន្យាការងារ ដែលផ្តល់សេវាការងារ ឬកិច្ចសន្យាគូររូបគំនូរជាដើមគ្មានភាពសមរម្យក្នុងការទទួលស្គាល់សកម្មភាពដែលតតិយជនបានធ្វើជំនួសកូនបំណុលថាជាការសងនោះទេ។*

#### ១.២. សមត្ថភាពចាត់ចែងរបស់អ្នកសង

អ្នកសងត្រូវតែជាម្ចាស់កម្មសិទ្ធិលើវត្ថុលើវត្ថុដែលជាកម្មវត្ថុនៃការសង ឬមានសមត្ថភាពចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃការសង[62]។ ក្នុងករណីដែលអ្នកសងមិនមែនជាម្ចាស់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការ

---

[59] សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ៖ មេធាវី ហេង បូរ៉ា ទំព័រទី១៥៦

[60] មាត្រា ៤៣៤, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[61] មាត្រា ៤៣៤, កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[62] មាត្រា ៤៣៥, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

សងទេ ការសងនោះមិនមានសុពលភាពឡើយ ហើយអ្នកសងនោះមិនអាចយកវត្ថុ នោះមកវិញបាននោះទេ លើកលែងតែមានការសងម្តងទៀតដែលមានសុពលភាព។ ប៉ុន្តែអ្នកដែលមានកម្មសិទ្ធិលើវត្ថុនោះ អាចយកវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនពីអ្នកទទួលការសងមកវិញបាន[63]។

***ឧទាហរណ៍៖*** *បុគ្គល ក ដែលជាម្ចាស់រថយន្តបានយករថយន្តរបស់ខ្លួនទៅជួសជុលនៅយានដ្ឋានរបស់លោក គ។ បន្ទាប់ពីជួសជុលរួចរាល់ចំណាយអស់ប្រាក់ ១០០ ដុល្លារ ពេលនោះ លោក ខ ដែលត្រូវជាមិត្តភក្តិរបស់លោក ក បានចេញលុយសង ១០០ ដុល្លារថ្លៃជួសជុល រថយន្តនោះ។ ក្នុងករណីនេះ ការសងរបស់លោក ខ មិនមានសុពលភាពឡើយ ព្រោះលោក ខ មិនមែនជាម្ចាស់កម្មវត្ថុនៃរថយន្តនោះទេ។*

ចំពោះអ្នកសងគ្មានសមត្ថភាពក្នុងការចាត់ចែងវត្ថុដែលជាកម្មវត្ថុនៃការសងទេ មានដូចជាការសងត្រូវបានធ្វើដោយអនីតិជន ឬជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងករណីនេះបើទោះបីជាអនីតិជន ឬជនដែលត្រូវបានកម្រិតសមត្ថភាពមានកម្មសិទ្ធិលើវត្ថុនោះក៏ដោយ ក៏សកម្មភាពនៃការសងដែលខ្លួនធ្វើអាចត្រូវបានលុបចោលដោយសារមូលហេតុនៃការកម្រិតសមត្ថភាព[64]។

## ១.៣. សិទ្ធិទទួលការសង និងការកម្រិតសិទ្ធិទទួលការសងដោយការរឹបអូស

ផ្អែកលើសិទ្ធិលើបំណុល កូនបំណុលត្រូវតែសងទៅបុគ្គលណាដែលជាអ្នកមានសិទ្ធិទទួលការសងឱ្យបានច្បាស់លាស់ទើបការសងនោះមានអានុភាព។ មិនត្រឹមតែប៉ុណ្ណោះ ការសងក៏មិនអាចធ្វើបានឡើយក្នុងករណីដែលការសងនោះត្រូវបានកម្រិតសិទ្ធិទទួលការសងដោយរឹបអូស។

### ១.៣.១. សិទ្ធិទទួលការសង

ការសងនឹងមានសុពលភាព លុះត្រាតែធ្វើចំពោះម្ចាស់បំណុល ឬអ្នកដទៃទៀតដែលមានសិទ្ធិទទួលការសង[65]។ ជារឿងធម្មតាទៅហើយដែលម្ចាស់បំណុលមានសិទ្ធិទទួលការសង ក៏ប៉ុន្តែចំពោះអ្នកមានសិទ្ធិទទួលការសងក្រៅពីម្ចាស់បំណុលរួមមាន៖ អ្នកតំណាងដែលទទួលការប្រគល់សិទ្ធិពីម្ចាស់បំណុលឱ្យទទួលការសង បុគ្គលដែលទទួលសិទ្ធិពីម្ចាស់បំណុលឱ្យទទួលការសងក្នុងនាមខ្លួនឯងផ្ទាល់ និងបុគ្គលដែលត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការប្រមូលដោយតុលាការដោយការរឹបអូសសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល[66]។

[63] មាត្រា ៤៣៥, កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[64] មាត្រា ៤៣៥, កថាខណ្ឌទី៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[65] មាត្រា ៤៣៧, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[66] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២, គន្លឹះទី៤ ទំព័រទី១៦០

ដោយឡែក ចំពោះករណីដែលកូនបំណុលបានសងដល់អ្នកដែលគ្មានសិទ្ធិទទួលការសង កូនបំណុលនោះត្រូវសងទៅម្ចាស់បំណុលជាថ្មីម្តងទៀតតាមការទាមទារពីម្ចាស់បំណុលនោះ។ ក្នុងករណីនេះ អ្នកសងអាចធ្វើការទាមទារឱ្យអ្នកគ្មានសិទ្ធិដែលបានទទួលការសងនោះប្រគល់កម្មវត្ថុនៃការសងមកវិញបាន[67]។

### ១.៣.២. ការកម្រិតសិទ្ធិការសងដោយការរឹបអូស

នៅក្នុងករណីសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលត្រូវបានរឹបអូស ដោយដីកាសម្រេចរឹបអូសរបស់តុលាការ ម្ចាស់បំណុលនោះមិនមានសិទ្ធិទទួលការសងពីកូនបំណុលរបស់ខ្លួន ហើយកូនបំណុលនោះក៏មិនអាចសងទៅម្ចាស់បំណុលបានឡើយ[68]។

### ១.៤. វិធីសង

ជាគោលការណ៍ កូនបំណុលត្រូវសងទៅតាមខ្លឹមសារនៃកាតព្វកិច្ច និងតាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់[69]។ ត្រង់អត្ថន័យនេះបានសេចក្តីថា កូនបំណុលត្រូវតែសងទៅម្ចាស់បំណុលឱ្យគ្រប់ចំនួននៅពេលដល់កំណត់កាតព្វកិច្ច រួមទាំងធ្វើការសងនៅម៉ោងធ្វើការ និងបានសងនៅទីកន្លែងដែលត្រូវសងឱ្យបានត្រឹមត្រូវដោយពុំមានចេតនាទុច្ចរិតណាមួយ ធ្វើឱ្យម្ចាស់បំណុលទទួលរងការខូចផលប្រយោជន៍ណាមួយឡើយ។

### ១.៤.១. ការសងមួយភាគ

ម្ចាស់បំណុលមិនមានករណីយកិច្ចទទួលការសងមួយភាគនៃកាតព្វកិច្ចទេ។ មានន័យថាម្ចាស់បំណុលមិនត្រូវបានបង្ខំឱ្យទទួលយកការសងមួយភាគនោះទេ ត្រូវតែទទួលបានការសងគ្រប់ចំនួនដែលបានកំណត់នៅក្នុងកិច្ចសន្យា ប៉ុន្តែម្ចាស់បំណុលក៏អាចទទួលការសងមួយភាគពីកូនបំណុលបានផងដែរដោយគ្រាន់តែមានការយល់ព្រម និងដឹងថាជាការសងមួយភាគដែលមានសុពលភាពត្រឹមទំហំដែលបានសង [70]។

***ឧទាហរណ៍៖*** *លោក ក បានជំពាក់ប្រាក់លោក ខ ចំនួន ១០០០ ដុល្លារ ប៉ុន្តែដោយសារ លោក ក មានប្រាក់តែ ៥០០ ដុល្លារ លោក ក ក៏ស្នើសុំផ្តល់ការសងត្រឹម ៥០០ ដុល្លារ នោះទៅលោក ខ។ ក្នុងករណីនេះលោក ខ មិនមានករណីយកិច្ចទទួលការសង ៥០០ ដុល្លារ ដែលជាការសងមួយភាគនោះទេ។ ផ្ទុយមកវិញ បើសិនជាលោក ខ ដែលជាម្ចាស់បំណុលយល់ព្រមទទួលការសង មួយភាគនោះចំនួនការប្រាក់នឹងត្រូវគណនាត្រឹមចំនួនប្រាក់ដែលលោក ក នៅសល់បន្ទាប់ពីសងទៅលោក ខ។*

---

[67] មាត្រា ៤៣៧, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[68] មាត្រា ៤៣៨, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[69] មាត្រា ៤៤០, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[70] មាត្រា ៤៤១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

#### ១.៤.២. ការសងដោយយកវត្ថុជំនួស

ក្នុងករណីដែលកូនបំណុលបានធ្វើការផ្តល់តាវកាលិកផ្សេងពីតាវកាលិកដែលជាបន្ទុកដើមរបស់ខ្លួនជាជំនួសវិញ ដោយទទួលការយល់ព្រមពីម្ចាស់បំណុល តាវកាលិកនោះមានអានុភាពដូចនឹងការសងដែរ[71]។

***ឧទាហរណ៍៖*** *លោក ក បានជំពាក់ប្រាក់លោក ខ ដោយគិតទាំងការប្រាក់សរុបចំនួន ៥០០០០ ដុល្លារ ហើយលោក ក មិនមានប្រាក់ដើម្បីសងបំណុលទៅលោក ខ នោះទេ ប៉ុន្តែលោក ក មានដីផ្ទាល់ខ្លួនមួយកន្លែងដែលមានតម្លៃ ៥០០០០ ដុល្លារ ដូច្នេះ លោក ក ក៏ស្នើសុំទៅលោក ខ ដែលជាម្ចាស់បំណុលឱ្យទទួលយកដីនោះ ហើយពេលនោះលោក ខ បានយល់ព្រម។ ដូចនេះ លោក ក ដែលជាកូនបំណុលបានផ្តល់តាវកាលិកផ្សេងពីតាវកាលិកដែលជាបន្ទុកដើមរបស់ខ្លួន ជាជំនួសវិញដោយទទួលការយល់ព្រមពីលោក ខ ដែលជាម្ចាស់បំណុលតាវកាលិននោះមានអានុភាពដូចគ្នានឹងការសងដែរ។*

### ១.៥. ការកាត់បំណុល

ការកាត់បំណុល មានន័យថានៅពេលដែលកូនបំណុលត្រូវសងកាតព្វកិច្ចច្រើន តើកាតព្វកិច្ចណាដែលត្រូវសងមុន និងកាតព្វកិច្ចណាត្រូវសងតាមក្រោយ។ យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ការកាត់បំណុលត្រូវបែងចែកជាពីរធំៗ គឺ**ការកាត់បំណុលដោយការជ្រើសរើស** និង**ការកាត់បំណុលតាមច្បាប់កំណត់**។

#### ១.៥.១. ការកាត់បំណុលដោយការជ្រើសរើស

ក្នុងករណីដែលកូនបំណុល ត្រូវទទួលបន្ទុកនូវកាតព្វកិច្ចច្រើនដែលមានគោលបំណងប្រភេទដូចគ្នាចំពោះម្ចាស់បំណុលតែម្នាក់ ប្រសិនបើតាវកាលិកដែលត្រូវបានផ្តល់ជាការសងនៅមិនទាន់គ្រប់គ្រាន់ដើម្បីឱ្យកាតព្វកិច្ចទាំងអស់រលត់នៅឡើយទេ អ្នកសងអាចជ្រើសរើសយកកាតព្វកិច្ចណាដែលត្រូវកាត់ដោយការសងនោះនៅពេលដែលខ្លួនផ្តល់តាវកាលិកបាន។ បានសេចក្តីថា កូនបំណុលមានសិទ្ធិជ្រើសរើសតាវកាលិកដែលត្រូវបានផ្តល់ដោយការសងណាមួយមកមុនបាន ដោយគ្រាន់តែមានធ្វើការជូនដំណឹងទៅម្ចាស់បំណុល[72]។

***ឧទាហរណ៍៖*** *លោក ក ជាកូនបំណុលដែលមានកាតព្វកិច្ចចំពោះលោក ខ ដែលជាម្ចាស់បំណុលចំនួន ៥០០ ដុល្លា ចំពោះថ្លៃលក់ ចំនួន ៣០០ ដុល្លា ជាកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគ និងចំនួន ៧០០ ដុល្លា ជាកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគ។ ប្រសិនបើកូនបំណុលលោក ក បានសងចំនួន ៥០០ ដុល្លា បញ្ហានិងកើតមានឡើងត្រង់ចំណុចថា តើត្រូវកាត់បំណុលចំពោះកាតព្វកិច្ចណាមួយក្នុងចំណោមកាតព្វកិច្ចទាំង*

[71] មាត្រា ៤៤២, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[72] មាត្រា ៤៤៩, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

*៣ខាងលើ។ ដូច្នេះលោក ក អាចសងប្រាក់ចំនួន ៥០០ ដុល្លាបាន ដោយគ្រាន់តែជូនដំណឹងទៅម្ចាស់បំណុល លោក ខ និងតម្រូវឱ្យមានបទដ្ឋានជាក់លាក់ ណាមួយសម្រាប់ការកាត់បំណុល។*

គួរបញ្ជាក់ផងដែរថា ប្រសិនបើអ្នកសង ឬកូនបំណុល មិនបានជ្រើសរើសការកាត់បំណុលដោយការជ្រើសរើសនោះទេ អ្នកទទួលការសងមានសិទ្ធិជ្រើសរើសកាតព្វកិច្ចណាមួយដែលត្រូវកាត់ដោយការសងនោះ នៅពេលដែលខ្លួនទទួលការសងបាន[73]។

### ១.៥.២. ការកាត់បំណុលតាមច្បាប់បានកំណត់

ការកាត់បំណុលតាមច្បាប់បានកំណត់ គឺសំដៅដល់ស្ថានភាពមួយដែលគ្មានភាគីណាមួយ (អ្នកសង និងអ្នកទទួលការសង) មិនបានធ្វើការជ្រើសយកការកាត់បំណុលដោយការជ្រើសរើសទេ ដូច្នេះការកាត់បំណុលនឹងអនុលោមទៅតាមបញ្ញត្តិច្បាប់កំណត់[74]។ ចំពោះការកាត់បំណុលតាមច្បាប់បានកំណត់មានស្ថានភាពជាច្រើនដូចជា៖

- ក្នុងចំណោមកាតព្វកិច្ចទាំងអស់ ប្រសិនបើមានកាតព្វកិច្ចណាមួយដែលពេលកំណត់ត្រូវសងបានមកដល់ និងកាតព្វកិច្ចផ្សេងទៀតដែលពេលកំណត់ត្រូវសងមិនទាន់មកដល់ នោះត្រូវកាត់កាតព្វកិច្ចដែលដល់ពេលកំណត់ជាមុនសិន។
- ប្រសិនបើពេលកំណត់ដែលត្រូវសងចំពោះកាតព្វកិច្ចទាំងអស់បានមកដល់ហើយ ឬមិនទាន់មកដល់នៅឡើយ នោះត្រូវកាត់កាតព្វកិច្ចដែលមានប្រយោជន៍ក្នុងការសងច្រើនជាងគេសម្រាប់កូនបំណុល។
- ប្រសិនបើផលប្រយោជន៍ក្នុងការសងមានភាពស្មើគ្នាចំពោះកូនបំណុល នោះត្រូវកាត់កាតព្វកិច្ចដែលពេលកំណត់ត្រូវសងបានមកដល់មុនគេ ឬនឹងមកដល់មុនគេ ។
- ប្រសិនបើកាតព្វកិច្ចទាំងអស់ មានប្រយោជន៍ក្នុងការសងដូចគ្នាចំពោះកូនបំណុល និងមានពេលកំណត់ដែលត្រូវសងដូចគ្នា នោះត្រូវកាត់ដោយគិតជាសមាមាត្រតាមចំនួនទឹកប្រាក់នៃកាតព្វកិច្ចនីមួយៗ។

## កថាភាគទី២. ការទូទាត់

ការទូទាត់ជាលក្ខខណ្ឌ ឬមធ្យោបាយមួយតាមផ្លូវច្បាប់ដើម្បីរលត់កាតព្វកិច្ចដែលកូនបំណុលមានចំពោះម្ចាស់បំណុល ដែលតាមរយៈនេះ គឺមានស្ថានភាពមួយចំនួនដូចជា៖ លក្ខខណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ និងកិច្ចសន្យាទូទាត់។

[73] មាត្រា ៤៤៩, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[74] មាត្រា ៤៥០, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ២.១. លក្ខខណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់

ការទូទាត់ដែលច្បាប់បានកំណត់ មានន័យថាការទូទាត់នោះបានធ្វើឡើងតាមមាត្រា ៤៦៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដោយបានកំណត់ថា ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ច ដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក ប្រសិនបើកាតព្វកិច្ចទាំងពីរត្រូវដល់ពេល កំណត់សងហើយ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមកដោយយកចំនួនប្រាក់ស្មើគ្នាដោយបង្ហាញ ឆន្ទៈឯកតោភាគី[75]។ មានន័យថា ទោះបីជាគ្មានការព្រមព្រៀងគ្នាអំពីការទូទាត់រវាងភាគីទាំងពីរក៏ដោយក៏ការ ទូទាត់អាចធ្វើបាន ដោយការបង្ហាញឆន្ទៈឯកតោភាគីបានឱ្យតែកាតព្វកិច្ចទាំងពីរមានគោលបំណង និងត្រូវបាន ដល់កំណត់ពេលសងដូចគ្នា។

## ២.២. កិច្ចសន្យាទូទាត់

ជាគោលការណ៍ ភាគីតែម្ខាងអាចបង្ហាញឆន្ទៈឯកតោភាគី ដើម្បីធ្វើការទូទាត់បាននៅពេលណាដែល លក្ខខណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ត្រូវបានបំពេញ។ ប៉ុន្តែ ទោះបីជាលក្ខខណ្ឌនៃការទូទាត់ដែលច្បាប់ បានកំណត់មិនត្រូវបានបំពេញក៏គូភាគីនៃកិច្ចសន្យាទូទាត់អាចព្រមព្រៀងគ្នាធ្វើការរំលត់កាតព្វកិច្ច ឬសិទ្ធិលើ បំណុលតាមរយៈការទូទាត់បានដែរ។

កិច្ចសន្យាទូទាត់ ជាកិច្ចសន្យាដែលរំលត់កាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកតាមការព្រមព្រៀងរបស់ គូភាគី ឬសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ទោះបីជាកាតព្វកិច្ចរបស់គូភាគីមិនមានគោលបំណងដូចគ្នាទៅ វិញទៅមកក៏ដោយ[76]។ ក៏ប៉ុន្តែមិនត្រូវធ្វើឱ្យខាតបង់ផលប្រយោជន៍តតិយជន ដោយសារការទូទាត់របស់គូភាគី នោះទេ។

## ២.៣. វិធីទូទាត់

ចំពោះការទូទាត់ត្រូវតែធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ពីភាគីម្ខាងទៅភាគីម្ខាងទៀត[77]។ ក្នុងន័យនេះ បានសេចក្តីថា កាតព្វកិច្ចទាំងពីរត្រូវដល់កំណត់ពេលសងដែលជាពេលវេលាត្រូវកំណត់សងកាតព្វកិច្ចនូវសិទ្ធិ លើបំណុល ដោយភាគីម្ខាងបានបង្ហាញឆន្ទៈអំពីការទូទាត់ចំពោះភាគីម្ខាងទៀត។ ហេតុនេះចំពោះសិទ្ធិលើ បំណុលរបស់ភាគីដែលបានធ្វើការទូទាត់ហើយនោះមានអានុភាពនៃសិទ្ធិលើបំណុលដែលត្រូវបានសង[78]។

---

[75] មាត្រា ៤៦៤, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[76] មាត្រា ៤៦៤, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[77] មាត្រា ៤៦៥, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[78] សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្រ្តាចារ្យៈ មេធាវី ហេង បូរ៉ា ទំព័រទី១៦៧

ដោយឡែក ការកម្រិតចំពោះការទូទាត់ សំដៅដល់សិទ្ធិលើបំណុលមួយចំនួនត្រូវបានកម្រិតដោយច្បាប់នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដើម្បីការពារផលប្រយោជន៍ភាគីណាមួយ ឬតតិយជនជៀសវាងការខាតបង់ដោយការទូទាត់។

មូលហេតុមួយចំនួនសម្រាប់ការកម្រិតចំពោះការទូទាត់មានដូចខាងក្រោមៈ

- **កាតព្វកិច្ចមិនអនុញ្ញាតឱ្យធ្វើការទូទាត់**

យោងតាមមាត្រា ៤៦៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីបានចែងថា ក្នុងករណីដែលលក្ខណៈនៃកាតព្វកិច្ចណាមួយ ឬទាំងពីរមិនអនុញ្ញាតឱ្យធ្វើការទូទាត់ទេ គូភាគីមិនអាចទូទាត់បានទេ។ មានន័យថា ករណីដែលមិនសមនឹងអនុញ្ញាតឱ្យភាគីធ្វើការទូទាត់ ដោយសារសិទ្ធិលើបំណុលណាមួយ ឬទាំងពីរក្នុងចំណោមសិទ្ធិលើបំណុលចំពោះគ្នាទៅវិញទៅមក គឺជាសិទ្ធិលើចំណុលពិសេសដែលភាគីត្រូវតែទទួលបានការបង់ប្រាក់។

***ឧទាហរណ៍៖*** *សិទ្ធិលើបំណុលចំពោះប្រាក់ឈ្នួល ជាអាទិ៍ គឺជាសិទ្ធិលើបំណុលដែលកម្មករនិយោជិតត្រូវការសម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ ហើយនិយោជកត្រូវតែបង់ជូនកម្មករនិយោជិត។ ដូចនេះ ក្នុងករណីដែលនិយោជកមានសិទ្ធិលើបំណុលចំពោះកម្ចីដល់កម្មករនិយោជិត មិនត្រឹមត្រូវនោះទេក្នុងការរំលត់សិទ្ធិលើបំណុលចំពោះប្រាក់ឈ្នួល ដោយអនុញ្ញាតឱ្យនិយោជកធ្វើការទូទាត់។*

- **ការសន្យាពិសេសមិនធ្វើការទូទាត់**

មួយវិញទៀត ភាគីទាំងសងខាងធ្វើការសន្យាពិសេសមិនធ្វើការទូទាត់ កូនបំណុលនីមួយៗមិនអាចធ្វើការទូទាត់បានឡើយ។ ប៉ុន្តែ ចំពោះការសន្យាពិសេសមិនធ្វើការទូទាត់នេះមិនអាចអះអាងចំពោះតតិយជនសុចរិតបានឡើយ[79]។

### កថាភាគទី៣. ការលើកលែងរបស់ម្ចាស់បំណុល

ក្នុងករណីដែលម្ចាស់បំណុលបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល កាតព្វកិច្ចនោះត្រូវរលត់[80]។ យើងអាចធ្វើការសន្និដ្ឋានបានថា ការលើកលែងរបស់ម្ចាស់បំណុល គឺជាសកម្មភាពឯកតោភាគី

[79] មាត្រា ៤៦៥, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[80] មាត្រា ៤៧៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

របស់ម្ចាស់បំណុលដែលធ្វើឱ្យរលត់សិទ្ធិលើបំណុលរបស់កូនបំណុលនោះដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលឡើយ។

**៣.១. ការលើកលែងតែមួយផ្នែក**

ការលើកលែងតែមួយផ្នែក ម្ចាស់បំណុលអាចលើកលែងកាតព្វកិច្ចតែមួយផ្នែកបាន[81]។ មានន័យថា នៅក្នុងចំណោមសិទ្ធិលើបំណុល ឬកាតព្វកិច្ចជាច្រើនដែលម្ចាស់បំណុលមានចំពោះកូនបំណុល ម្ចាស់បំណុលអាចជ្រើសរើសកាតព្វកិច្ចណាមួយដើម្បីធ្វើឱ្យរលត់កាតព្វកិច្ចនោះ។

***ឧទាហរណ៍៖*** *លោក ខ បានជំពាក់ប្រាក់លោក ក ចំនួន ៥០០០ ដុល្លារ ដោយក្នុងនោះ គិតទាំងការប្រាក់ ២៥០ ដុល្លារផងដែរ។ លោក ក បានសម្រេចចិត្តមិនយកការប្រាក់ចំនួន ២៥០ ដុល្លារពីលោក ខ ដែលជាកូនបំណុលឡើយ។ នេះបង្ហាញឱ្យឃើញថា លោក ក ដែលជាម្ចាស់បំណុលបានបង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចមួយផ្នែកទៅលើលោក ខ ដែលជាកូនបំណុល។*

**៣.២. ករណីដែលកម្រិតការលើកលែង**

បើទោះបីជាម្ចាស់បំណុលមានសិទ្ធិលើបំណុលក៏ដោយ ក៏មិនមានន័យថាម្ចាស់បំណុលសុទ្ធតែអាចលើកលែងនូវកាតព្វកិច្ចដោយឯកតោភាគីបានទាំងអស់ដែរ។ តួយ៉ាង ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានរឹបអូសដោយតតិយជន ឬសិទ្ធិចាត់ចែងរបស់ម្ចាស់បំណុលត្រូវបានកម្រិតដោយមូលហេតុផ្សេងៗ ម្ចាស់បំណុលមិនអាចលើកលែងកាតព្វកិច្ចបានឡើយ[82]។

***ឧទាហរណ៍៖*** *លោក ក ជាម្ចាស់ភាគហ៊ុន ៦០ភាគរយ នៅក្នុងក្រុមហ៊ុនទឹកបរិសុទ្ធកម្ពុជា ហើយ លោក គ ជាតំណាងចែកចាយទឹកបរិសុទ្ធនោះ ដោយលោក គ បានជំពាក់ប្រាក់លោក ក ចំនួន ១០០០ ដុល្លារ (ជាទឹកបរិសុទ្ធនោះ) ពេលនោះ លោក ក ដែលជាមិត្តភក្តិជិតស្និតជាមួយ លោក គ បានសន្យាថាមិនយកលុយ ១០០០ ដុល្លារនោះទេ បើលោក គ ទៅផឹកស៊ីជាមួយខ្លួន។ បន្ទាប់ពីផឹកស៊ីរួច លោក ក ក៏សម្រេចចិត្តថាលើកលែងបំណុលនោះចោលមែន ប៉ុន្តែ លោក ខ បានទាមទារទៅលោក គ ឱ្យបង់ប្រាក់ចំនួន ១០០០ ដុល្លាទៅក្រុមហ៊ុនទឹកបរិសុទ្ធកម្ពុជា ព្រោះលោក ខ មិនយល់បានព្រមដោយហេតុថាលោក ខ ក៏មានភាគហ៊ុនចំនួន ៤០ ភាគរយដែរនៅក្នុងក្រុមហ៊ុននោះ។ ដូច្នេះ លោក ក ត្រូវតែចេញមុខសងប្រាក់ជំនួសលោក គ ព្រោះប្រាក់នោះក៏មានផលប្រយោជន៍របស់លោក ខ ដែរ។*

[81] មាត្រា ៤៧៤, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[82] មាត្រា ៤៧៥, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**កថាភាគទី៤. នវកម្ម**

នវកម្ម គឺជាមូលហេតុមួយក្នុងមូលហេតុផ្សេងៗដែលនាំឱ្យមានការរំលត់កាតព្វកិច្ចបាន។ ចំពោះនវកម្ម សំដៅទៅលើកិច្ចសន្យារវាងម្ចាស់បំណុល និងកូនបំណុលដែលរំលត់កាតព្វកិច្ចដើម និងបង្កើតកាតព្វកិច្ចថ្មី ជំនួសកាតព្វកិច្ចដើមនោះ[83]។ ទោះបីជាក្នុងបទបញ្ញត្តិស្តីពីនវកម្មមិនបានបែងចែកអំពីប្រភេទនៃនវកម្មក៏ដោយ ក៏យើងអាចធ្វើការសន្និដ្ឋានបានថានវកម្ម មាន **៣ប្រភេទ** គឺៈ

- **នវកម្មដោយការប្តូរគោលបំណងនៃកាតព្វកិច្ច**
- **នវកម្មដោយការជំនួសម្ចាស់បំណុល**
- **នវកម្មដែលប្តូរកូនបំណុល។**

**៤.១. នវកម្មដោយការប្តូរគោលបំណងនៃកាតព្វកិច្ច**

តាមការជាក់ស្តែង នវកម្មដែលប្តូរគោលបំណងនៃកាតព្វកិច្ច គឺជាស្ថានភាពដែលមានគោលបំណង ផ្តល់តាវកាលិកជាវត្ថុប្តូរទៅជាកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ឬកាតព្វកិច្ចចំពោះថ្លៃលក់ ប្តូរទៅជា**កាតព្វកិច្ចជាការខ្ចីបរិភោគ**។

**៤.២. នវកម្មដោយការជំនួសម្ចាស់បំណុល**

ចំណែកនវកម្មដែលប្តូរម្ចាស់បំណុល គឺស្រដៀងនឹងអនុប្បទានសិទ្ធិលើបំណុលត្រង់ចំណុចថាម្ចាស់ បំណុលត្រូវបានប្តូរ ប៉ុន្តែនវកម្មនេះខុសពីអនុប្បទានសិទ្ធិលើបំណុល ដោយសារកាតព្វកិច្ចដើមត្រូវរលត់ ហើយកាតព្វកិច្ចថ្មីកើតឡើង។ ហេតុដូច្នេះ យោងតាមកិច្ចសន្យានវកម្មដែលប្តូរម្ចាស់បំណុល ជាគោលការណ៍ ប្រាតិភោគដែលធានាកាតព្វកិច្ចដើមត្រូវរលត់ ហើយការតវ៉ាដែលកូនបំណុលធ្លាប់មានចំពោះម្ចាស់បំណុលដើម ក៏មិនអាចយកអះអាងតតាំងនឹងម្ចាស់បំណុលថ្មីបានដែរ។

**៤.៣. នវកម្មដោយការប្តូរកូនបំណុល**

នវកម្មដែលប្តូរកូនបំណុល សំដៅទៅលើការរំលត់កាតព្វកិច្ចរវាងម្ចាស់បំណុល ក និង កូនបំណុល ខ ហើយបង្កើតនូវកាតព្វកិច្ចថ្មីដោយយក គ មកប្តូរកូនបំណុល។ ដើម្បីឱ្យនវកម្មនេះមាន សុពលភាពត្រូវមានការ យល់ព្រមពី គ ជាមុនសិន។ ដូច្នេះ នវកម្មដែលប្តូរកូនបំណុលចាំបាច់ត្រូវមានការយល់ព្រមពីភាគីទាំង ៣ គឺ ក

[83] មាត្រា ៤៧៦, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ខ និង គ ដែលមិនមានបញ្ចូលក្នុងនវកម្មក្នុងមាត្រា ៤៧៦ ដែលអាចធ្វើបានដោយការព្រមព្រៀងតែរវាងកូនបំណុល និងម្ចាស់បំណុលប៉ុណ្ណោះ។

**កថាខណ្ឌទី៥. ព្យាកុលភាព**

បើទោះបីជាភាគីម្ខាងមានកាតព្វកិច្ចចំពោះភាគីម្ខាងទៀតក៏ដោយ ក៏កាតព្វកិច្ចនោះ ត្រូវបានរលត់ផងដែរតាមរយៈព្យាកុលភាព។ ចំពោះព្យាកុលភាពដែលពាក់ព័ន្ធនឹងសិទ្ធិលើបំណុល និងកាតព្វកិច្ច គឺជាស្ថានភាពមួយនៃកិច្ចសន្យារវាងម្ចាស់បំណុល និងកូនបំណុល ដោយសិទ្ធិលើបំណុលធ្លាក់ទៅលើបុគ្គលតែម្នាក់នោះនាំឱ្យសិទ្ធិលើបំណុល និងកាតព្វកិច្ចត្រូវរលត់ដោយព្យាកុលភាព។ លើកលែងតែសិទ្ធិលើបំណុលនោះជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជនដែលជាហេតុនាំឱ្យសិទ្ធិលើបំណុលមិនអាចរលត់ដោយព្យាកុលភាពឡើយ [84]។

***ឧទាហរណ៍៖*** *លោក ក បានខ្ចីប្រាក់ចំនួន ៥០០០ ដុល្លាអាមេរិក ពីលោក ខ ដែលជាឪពុក របស់ខ្លួនដោយកំណត់សងនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨ មិនយូប៉ុន្មានលោក ខ ក៏បានទទួល មរណភាព (កំណត់សងមិនទាន់មកដល់)។ ដូច្នេះលោក ក ដែលជាសន្តតិជន របស់លោក ខ ត្រូវបានទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់លោក ខ នៅពេលនេះហើយលោក ក ជាកូនបំណុលផង និងជាម្ចាស់បំណុលផង ហេតុដូចនេះសិទ្ធិលើបំណុល និងកាតព្វកិច្ចត្រូវបានរលត់ដោយព្យាកុលភាព។*

## ផ្នែកទី២. ការរំលត់សិទ្ធិលើបំណុលតាមបញ្ញត្តិច្បាប់

ដោយឡែក ចំពោះការរលត់សិទ្ធិលើបំណុលតាមបញ្ញត្តិច្បាប់ សំដៅដល់ស្ថានភាពមួយដែលភាគីមិនបានធ្វើឱ្យកាតព្វកិច្ចនោះរលត់ដោយប្រើប្រាស់នូវលក្ខខណ្ឌមួយចំនួនដូចជា៖ ការសង ការទូទាត់ ការលើកលែងរបស់ម្ចាស់បំណុល នវកម្ម និងព្យាកុលភាព ជាអាទិ៍។ ហេតុដូចនេះ ការរំលត់សិទ្ធិលើបំណុលត្រូវតែអនុលោមតាមបញ្ញត្តិច្បាប់កំណត់។

ដូច្នេះយើងនឹងធ្វើការពន្យល់បកស្រាយឱ្យបានក្បោះក្បាយទៅលើមូលហេតុគតិយុត្តដែលបណ្តាលឱ្យសិទ្ធិលើបំណុលត្រូវបានរលត់តាមបញ្ញត្តិច្បាប់ដូចជា៖

- **អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល**
- **ការរំលាយកិច្ចសន្យា**
- **អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល**

[84] មាត្រា ៤៧៩, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- **ការអនុវត្តសិទ្ធិលុបចោល។**

**កថាភាគទី១. អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល**

ការទទួលបន្ទុកហានិភ័យ គឺជាការទទួលរងនូវការខូចខាតនៅពេលដែលកម្មវត្ថុត្រូវបានបាត់បង់ ឬខូចខាតក្នុងកំឡុងពេលបង្កើតកិច្ចសន្យា រហូតដល់ពេលអនុវត្តកិច្ចសន្យា។ នៅពេលដែលការទទួលបន្ទុកហានិភ័យកើតឡើងនាំឱ្យសិទ្ធិលើបំណុលត្រូវរលត់ លុះត្រាតែគ្មានកំហុសរបស់កូនបំណុល[85]។

គួរបញ្ជាក់ផងដែរថា ដើម្បីកំណត់ពីអត្ថិភាពនៃអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចត្រូវតែបំពេញលក្ខខណ្ឌមួយចំនួនរួមមាន ៖

- **កិច្ចសន្យាអញ្ញមញ្ញ** : គឺជាកិច្ចសន្យាដែលគូភាគីមានកាតព្វកិច្ចបំពេញឱ្យគ្នាទៅវិញទៅមក។ ប្រសិនបើជាកិច្ចសន្យាឯកតោភាគីមិនចូលក្នុងលក្ខខណ្ឌនោះទេ ព្រោះមានភាគីតែម្ខាងប៉ុណ្ណោះដែលធ្វើសកម្មភាព។
- **អលទ្ធភាពក្នុងការអនុវត្ត** : បើគ្មានលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចទេ នោះកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព ហើយអលទ្ធភាពនេះមិនត្រូវរាប់បញ្ចូលទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ច និងសង្គមនោះទេ។
- **គ្មានកំហុសរបស់កូនបំណុល** : សំដៅដល់ការអនុវត្តកាតព្វកិច្ចរបស់កូនបំណុលដែលគ្មានកំហុសនាំឱ្យកាតព្វកិច្ចត្រូវរលត់។ ផ្ទុយមកវិញ បើការអនុវត្តរបស់កូនបំណុលមានកំហុសនោះម្ចាស់បំណុលអាចទាមទារសំណងការខូចខាតបាន ដោយផ្អែកលើការខូចខាតនោះ។

***ឧទាហរណ៍៖*** *អ្នកស្រី ក បានបង្កើតកិច្ចសន្យាលក់-ទិញរថយន្តជាមួយលោក ខ ក្នុងតម្លៃ ១០,០០០ ដុល្លារអាមេរិក ដោយកំណត់យកថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ជាថ្ងៃដែលភាគីទាំងពីរ ត្រូវអនុវត្តកាតព្វកិច្ច (អ្នកស្រី ក ប្រគល់រថយន្ត និងលោក ខ ប្រគល់ប្រាក់)។ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ អ្នកស្រី ក បានរៀបទុកដាក់រថយន្តត្រឹមត្រូវក្នុងឃ្លាំងរថយន្តរបស់ខ្លួន ប៉ុន្តែនៅយប់នោះ ក៏មានក្រុមចោរមួយក្រុមបានចូលលួចរថយន្តដែលរៀបចំទុកលក់ឱ្យលោក ខ យកទៅបាត់ទៅ។ ក្នុងករណីនេះទោះបីជាដល់ថ្ងៃអនុវត្តកាតព្វកិច្ចក៏ដោយ ភាគីទាំងពីរមិនអាចទាមទារឱ្យបំពេញទៅវិញទៅមកនូវការអនុវត្តកាតព្វកិច្ចបានឡើយព្រោះអ្នកស្រី ក អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចនោះ។*

[85] មាត្រា ៤១៥, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## កថាភាគទី២. ការរំលាយកិច្ចសន្យា

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមទាំងបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច[86]។ បានសេចក្តីថា កិច្ចសន្យាត្រូវបានបង្កើតឡើងតាមការព្រមព្រៀងរបស់ភាគីដោយមានកាតព្វកិច្ចបំពេញឱ្យគ្នាទៅវិញទៅមក ក្នុងករណីដែលភាគីម្ខាងមិនអាចសម្រេចគោលបំណងក្នុងពេលបង្កើតកិច្ចសន្យាបានដោយសារការមិនអនុវត្តកាតព្វកិច្ច ឬការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរនាំឱ្យភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបាន[87]។

### ២.១. លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា

គ្រប់កិច្ចសន្យាទាំងអស់មិនមែនសុទ្ធសឹងតែអាចរំលាយទៅតាមទំនើងចិត្តរបស់ភាគីបាននោះទេ ភាគីអាចធ្វើការរំលាយកិច្ចសន្យាបាន លុះត្រាតែបានបំពេញលក្ខខណ្ឌនៅក្នុងក្រមរដ្ឋប្បវេណី។

- ***កិច្ចសន្យាអញ្ញមញ្ញ***

ជាកិច្ចសន្យាដែលភាគីបំពេញកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ក្នុងករណីភាគីណាមួយមិនបានបំពេញ ឬផ្តល់តាវកាលិកទៅឱ្យភាគីម្ខាងបានទេ ហេតុដូច្នេះភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបាន។

***ឧទាហរណ៍៖*** *កញ្ញា ក បានបង្កើតកិច្ចសន្យាលក់ទិញម៉ូតូនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ជាមួយលោក ខ ដោយកំណត់ថ្ងៃប្រគល់ម៉ូតូ និងប្រគល់ប្រាក់នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។ លុះដល់ថ្ងៃប្រគល់ម៉ូតូ កញ្ញា ក មិនបានប្រគល់ម៉ូតូជូនលោក ខ នោះទេ។ នៅក្នុងករណីនេះ លោក ខ អាចធ្វើការរំលាយកិច្ចសន្យាដោយបង្ហាញឆន្ទៈបាន។*

- ***ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ***

ចំពោះការបំពានកិច្ចសន្យាធ្ងន់ធ្ងរ សំដៅទៅលើការករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបានដោយសារការបំពានរបស់ភាគីម្ខាងទៀត។ ត្រូវចាត់ថាមានការការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ[88] ក្នុងករណីដូចខាងក្រោម៖

ក. ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះទេ។

---

[86] មាត្រា ៣១១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[87] មាត្រា ៤០៧, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[88] មាត្រា ៤០៨, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ខ. ភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ។

គ. ភាគីមិនអាចអនុវត្តករណីកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ។

ឃ. ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់ទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចបាននាពេលអនាគតបាន។

***ឧទាហរណ៍៖*** *លោកស្រី ក បានបង្កើតកតិសន្យាជាមួយលោក ខ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ ដោយបានកំណត់ថ្ងៃបង់ថ្លៃឈ្នួលនៅថ្ងៃទី០១ នៅរៀងរាល់ដើមខែ។ មិនបានយូប៉ុន្មាន លោក ខ មិនបានបង់ប្រាក់ឈ្នួលទៅតាមកំណត់នៅក្នុងកិច្ចសន្យាឱ្យទៅលោកស្រី ក នោះទេ បើទោះបីជាលោកស្រី ក បានធ្វើការដាស់តឿន និងទុកអំឡុងពេលសមរម្យឱ្យអនុវត្ត ក៏លោក ខ នៅតែមិនអនុវត្តកាតព្វកិច្ច។ ដូច្នេះ លោកស្រី ក អាចធ្វើការរំលាយកិច្ចសន្យាជាមួយលោក ខ បាន។*

### ២.២. ប្រភេទនៃការរំលាយកិច្ចសន្យា

ក្រោយពេលកិច្ចសន្យាមានអានុភាព នាំឱ្យភាគីមានសិទ្ធិ និងករណីយកិច្ចក្នុងការអនុវត្តកាតព្វកិច្ច បើសិនភាគីណាមួយមិនអនុវត្តកាតព្វកិច្ច នោះភាគីម្ខាងទៀតអាចធ្វើការជ្រើសរើសការរំលាយកិច្ចសន្យាបាន។

- **ការរំលាយកិច្ចសន្យាដោយសារការមិនអនុវត្តកាតព្វកិច្ចតាមបទប្បញ្ញត្តិទូទៅ** ៖ សំដៅដល់ការរំលាយកិច្ចសន្យាដោយសារការមិនអនុវត្តកាតព្វកិច្ច ដែលបានបញ្ញត្តិនៅក្នុងមាត្រា ៤០៧ និងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
- **ការរំលាយកិច្ចសន្យាដោយសារការព្រមព្រៀង**[89] ៖ សំដៅដល់ការរំលាយដោយផ្អែកលើការបង្ហាញឆន្ទៈត្រូវគ្នារបស់ភាគីនៃកិច្ចសន្យា ដែលពុំមានបំណងបន្តកិច្ចសន្យាដោយមិនពិចារណាអំពីមូលហេតុនៃការរំលាយ។
- **ការរំលាយកិច្ចសន្យាដែលមានកំណត់នៅក្នុងកិច្ចសន្យា**[90] ៖ គឺជាការរំលាយផ្អែកលើមូលហេតុដែលមានកំណត់នៅក្នុងកិច្ចសន្យាទុកជាមុនអំឡុងពេលមកដល់ ឬមុនអំឡុងពេលមិនទាន់មកដល់ដោយសារតែការមិនអនុវត្តកាតព្វកិច្ច។

[89] មាត្រា ៤១៤, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[90] មាត្រា ៤១៤, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**កថាភាគទី៣. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល**

គោលបំណងដែលនាំឱ្យមានការកំណត់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះឡើង ក្នុងច្បាប់គឺដើម្បីគ្រប់គ្រងឱ្យមានស្ថេរភាព និងការថែរក្សានូវសណ្តាប់ធ្នាប់សង្គម ដោយកំណត់នូវពេលវេលាជាក់លាក់ និងមិនអនុញ្ញាតឱ្យទុកជម្លោះចោលក្នុងរយៈពេលកំណត់ ដោយជួយជម្រុញឱ្យម្ចាស់បំណុលប្រញាប់ប្រញាល់ក្នុងការដាក់ពាក្យបណ្តឹង និងអាចបង្កនូវភាពងាយស្រួលដល់តុលាការក្នុងការទទួលបាននូវភស្តុតាងដែលនៅល្អងាយស្រួលពិនិត្យ ព្រមទាំងសាក្សីដែលមាននៅការចងចាំបានល្អ ប្រសិនបើម្ចាស់បំណុលមិនបានការពារសិទ្ធិរបស់ខ្លួនទេនោះ គឺមានន័យថាម្ចាស់បំណុលមិនគួរទទួលបានសិទ្ធិនេះតទៅទៀតឡើយ។ ម៉្យាងវិញទៀតវិធាននៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏មានគោលបំណងក្នុងការការពារដល់កូនបំណុល តាមរយៈការរឹតត្បិតសិទ្ធិរបស់ម្ចាស់បំណុលឱ្យមានប្រសិទ្ធិភាពត្រឹមត្រូវតែកាលកំណត់ជាក់លាក់មួយតែប៉ុណ្ណោះ ប្រសិនបើកូនបំណុលអាចត្រូវបានគេប្តឹងដោយពុំមានកាលកំណត់នោះ មានន័យថាកូនបំណុលនឹងទទួលបាននូវភាពយុត្តិធម៌ឡើយ ព្រោះថាការកំណត់នូវអំឡុងពេលអាជ្ញាកាលនោះ។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិក្នុងអំឡុងពេលដែលត្រូវបានកំណត់[91]។ នៅក្នុងអត្ថន័យនេះបានសេចក្តីថាប្រសិនបើពេលកំណត់ត្រូវបានកន្លងផុតទៅហើយ ម្ចាស់បំណុលបានព្រងើយកន្តើយក្នុងការអនុវត្តសិទ្ធិរបស់ខ្លួននាំឱ្យម្ចាស់បំណុលនឹងត្រូវបាត់បង់សិទ្ធិ ឬផ្លោះសិទ្ធិនោះ។

តួយ៉ាង ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ផ្តើមពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន[92]។ ពេលដែលអាចអនុវត្តសិទ្ធិលើបំណុលបាន មានន័យថាពេលដែលមានឧបសគ្គតាមផ្លូវច្បាប់ក្នុងការអនុវត្តសិទ្ធិលើបំណុលនោះ។ ជារួម ម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាននៅពេលដែលលែងមានឧបសគ្គតាមផ្លូវច្បាប់នៅក្នុងការអនុវត្តសិទ្ធិ ពោលគឺឧបសគ្គតាមផ្លូវច្បាប់ដែលហាមឃាត់មិនឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិរបស់ខ្លួន។

***ឧទាហរណ៍៖*** *នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ដែលមានថេរវេលាកំណត់ពេលឱ្យសងក្នុងរយៈពេលនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤។ ដូច្នេះប្រសិនបើរយៈពេលមួយឆ្នាំមិនទាន់បានកន្លងផុតភាគីម្ខាងនៃកិច្ចសន្យា*

[91] មាត្រា ៤៨០, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[92] មាត្រា ៤៨១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

*មិនអាចទាមទារឱ្យភាគីទៀតសងមុនពេលកំណត់ឡើយ ដែលនេះបានបង្ហាញឱ្យឃើញពីឧបសគ្គតាមផ្លូវច្បាប់នៅក្នុងការអនុវត្តសិទ្ធិ។*

យ៉ាងណាមិញ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេង[93]។ មានន័យថាម្ចាស់បំណុលត្រូវតែអនុវត្តសិទ្ធិលើកូនបំណុលក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលបាន ក្នុងករណីម្ចាស់បំណុលមិនបានអនុវត្តសិទ្ធិលើបំណុលតាមបញ្ញត្តិច្បាប់កំណត់ទេម្ចាស់ត្រូវបានបាត់បង់សិទ្ធិអនុវត្តលើបំណុលចំពោះកូនបំណុលជាក់ជាមិនខាន។ គួរបញ្ជាក់ផងដែរចំពោះចំណុចចាប់ផ្តើមនៃអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលអាចប្រែប្រួលទៅតាមករណីនីមួយៗ។

***ឧទាហរណ៍៖*** *នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ កូនបំណុល ក បានខ្ចីប្រាក់ពីម្ចាស់បំណុល ខ ចំនួន ៥០០០ ដុល្លាអាមេរិក ដែលមានកំណត់សងនៅ២ឆ្នាំ។ ចំពោះករណីនេះ បើពេលកំណត់ត្រូវសងបានមកដល់ម្ចាស់បំណុលពុំបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទាមទារប្រាក់ពីកូនបំណុល ហើយរយៈពេល៥ឆ្នាំក៏បានកន្លងផុតនោះ ដូចនេះម្ចាស់បំណុលនឹងបាត់បង់សិទ្ធិក្នុងការទាមទារចំពោះកូនបំណុល។*

ប៉ុន្តែតាមរយៈមាត្រា ៤៨៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិថា៖ ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករ ឬពាណិជ្ជករបានលក់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ និងថ្លៃសេវាដែលផលិតករ ឬពាណិជ្ជករផ្តល់ឱ្យអ្នកដែលមិនមែនជាពាណិជ្ជករអាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះមានអំឡុងពេល ២ (ពីរ) ឆ្នាំ។ ចំពោះសិទ្ធិលើបំណុលដែលមានអំឡុងពេលអាជ្ញាយុកាលខ្លីនេះ គឺស្ថិតក្នុងប្រតិបត្តិការរបស់អ្នកប្រើប្រាស់ ដែលជាធម្មតាតែងតែមានការលំបាកក្នុងថែរក្សាទុកនូវភស្តុតាងផ្សេងៗ។

***ឧទាហរណ៍៖*** *លោក ក បានទិញកុំព្យូទ័រមួយគ្រឿងមានតម្លៃ១០០០ ដុល្លាអាមេរិក នៅហាង របស់លោក ខ និងបានយកកុំព្យូទ័រនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ក៏ប៉ុន្តែលោក ក ពុំមានប្រាក់ គ្រប់គ្រាន់ឱ្យលោក ខ នោះទេ។ ដូច្នេះលោក ខ និងលោក ក បានព្រមព្រៀងគ្នាលើកាលកំណត់សងប្រាក់ថ្លៃលក់កុំព្យូទ័រ ដែលនៅខ្វះក្នុងរយៈពេល០៥ខែទៀត គឺនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ តែលោក ក នៅតែមិនបានបង់ប្រាក់ថ្លៃលក់កុំព្យូទ័រគ្រប់ចំនួនជូនលោក ខ នោះទេ។ ក្នុងករណីនេះ សិទ្ធិលើបំណុលនេះនឹងត្រូវរលត់ ប្រសិនបើអំឡុងពេល២ឆ្នាំបានកន្លងផុត គិតពីពេលដែលកំណត់ សងបានកន្លងហួស នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៧។*

---

[93] មាត្រា ៤៨២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.១. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅដល់ការបញ្ឈប់ដំណើរការនៃអាជ្ញាយុកាល ក្នុងករណីនេះការផ្អាកនូវអាជ្ញាយុកាល គឺមិនត្រឹមតែផ្អាកដំណើរការនៃអាជ្ញាយុកាលនោះមួយរយៈពេលទេ ត្រូវចាត់ទុកថាអំឡុងពេលនៃអាជ្ញាយុកាលដែលមានដំណើរកន្លងមកនេះ ពុំមានអត្ថន័យតាមច្បាប់ឡើយ ឬត្រូវចាត់ទុកជាមោឃៈ។ ដូចនេះហើយពេលដែលហេតុនៃការផ្អាកនោះបានរលត់ទៅ អំឡុងពេលនៃអាជ្ញាយុកាល នឹងចាប់ផ្ដើមគិត ឬចាប់ផ្ដើមរាប់សារជាថ្មីម្ដងទៀត[94]។

បើក្រឡេកទៅមើល ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដើម្បីធ្វើការផ្អាកអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុលបានត្រូវតែបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់។ ចំពោះលក្ខខណ្ឌដែលច្បាប់ បានកំណត់ស្ថិតក្នុងស្ថានភាពដូចជា៖

- **ការទាមទារតាមផ្លូវតុលាការ។**
- **សកម្មភាពអនុវត្តដោយបង្ខំ ឬសកម្មភាពចាត់ចែងរក្សាការពារ។**
- **ការទទួលស្គាល់កាតព្វកិច្ច។**

#### ៣.១.១. ការទាមទារតាមផ្លូវតុលាការ

ការទាមទារតាមផ្លូវតុលាការ មិនត្រូវបានបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ក្នុងករណីដែលបណ្ដឹងត្រូវបានលើកចោល ឬត្រូវបានដកវិញ[95]។ ត្រង់ចំណុចនេះបានសេចក្ដីថា ម្ចាស់បំណុលមានសិទ្ធិគ្រប់គ្រាន់ក្នុងផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន ដោយគ្រាន់តែធ្វើការ ដាក់ពាក្យបណ្ដឹងទាមទារតាមផ្លូវតុលាការ ហើយត្រូវតុលាការបានធ្វើការវិនិច្ឆ័យទៅលើពាក្យបណ្ដឹងនោះ។ ហេតុដូច្នេះ ការដាក់ពាក្យបណ្ដឹងទាមទារតាមផ្លូវតុលាការ គឺជាហេតុមួយដែលនាំឱ្យមានការផ្អាកអាជ្ញាយុកាល។

***ឧទាហរណ៍៖*** *លោក ក បង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយលោក ខ ចំនួន១០០០ ដុល្លាអាមេរិក នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដោយកំណត់សងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ក៏ប៉ុន្តែនៅ ពេលដែលដល់កំណត់ថ្ងៃសង លោក ក ដែលជាកូនបំណុលមិនបានធ្វើការសងប្រាក់ទៅ លោក ខ ដែលជាម្ចាស់បំណុលឡើយ។ បើទោះបីជាដល់ថ្ងៃកំណត់ពេលសងហើយក៏ដោយ លោក ខ នៅតែ ប្រងើយកន្តើយមិនធ្វើការទាមទារប្រាក់ពីលោ ក អស់រយៈពេល៣ឆ្នាំ ស្រាប់តែនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥*

[94] សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ៖ មេធាវី ហេង បូរ៉ា ទំព័រទី១៧៩

[95] មាត្រា ៤៩១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

*លោក ខ បានដាក់ពាក្យបណ្តឹងទាមទារប្រាក់ពីលោក ក តាមផ្លូវតុលាការ ហើយតុលាការក៏បានយកពាក្យបណ្តឹងនោះមកធ្វើការវិនិច្ឆ័យ។ ក្នុងករណីនេះ សិទ្ធិលើបំណុលមិនត្រូវបានរលត់ នោះទេ ដោយសារតែលោក ខ បានធ្វើការផ្អាកអំឡុងពេលនៃការរំលត់សិទ្ធិលើបំណុលនោះបានទាន់ពេលវេលានៃច្បាប់កំណត់។ ដូច្នេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលត្រូវបានផ្អាកដោយការទាមទារតាមផ្លូវតុលាការនឹងចាប់ផ្តើមគិតជាថ្មីម្តងទៀត បន្ទាប់ពីសេចក្តីសម្រេចចូលជាស្ថាពរ។*

### ៣.១.២. សកម្មភាពអនុវត្តដោយបង្ខំ ឬសកម្មភាពចាត់ចែងរក្សាការពារ

សកម្មភាពភាពអនុវត្តដោយបង្ខំ សំដៅទៅលើសកម្មភាពដែលមានគោលដៅដើម្បីរឹបអូសការនូវសិទ្ធទាមទារផ្សេងទៀត ដូចជាការអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វត្ថុជាដើម និងការអនុវត្តសិទ្ធិប្រាតិភោគ។ ចំណែកឯសកម្មភាពចាត់ចែងរក្សាការពារ សំដៅទៅលើការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន។ តាមការពិតសកម្មភាពទាំងពីរនេះបញ្ជាក់យ៉ាងច្បាស់លាស់នូវការអះអាងសិទ្ធិពីសំណាក់ម្ចាស់បំណុល ហេតុដូច្នេះហើយទើបក្រមរដ្ឋប្បវេណីចាត់ទុកថាជាហេតុនាំឱ្យផ្អាកអាជ្ញាយុកាល។ ដោយឡែកអាជ្ញាយុកាលត្រូវបានផ្អាកនៅពេលដែលបានដាក់ពាក្យសុំអនុវត្តដោយបង្ខំ ឬដាក់ពាក្យចាត់ចែងរក្សាការពារ។ ក៏ប៉ុន្តែនៅក្នុងករណីដែលការចាត់ចែងអនុវត្តដោយបង្ខំ ឬដាក់ពាក្យចាត់ចែងរក្សាការពារត្រូវបានលុបចោលតាមពាក្យសុំរបស់ពាក្យភាគី ឬដោយសារខ្វះលក្ខខណ្ឌតាមច្បាប់ គឺត្រូវបានចាត់ទុកថាមិនមានការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ ដោយយោងតាមមាត្រា ៤៩២ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

***ឧទាហរណ៍៖*** *លោក ក បានឱ្យប្រាក់ទៅលោក ខ ខ្ចីចំនួន ៥០ លានរៀលដោយកំណត់សងក្នុងរយៈពេលមួយឆ្នាំ។ ក៏ប៉ុន្តែ នៅថ្ងៃដល់កំណត់សងលោក ខ មិនបានសងប្រាក់ទៅលោក ក ឡើយ ហើយ ៤ ឆ្នាំក្រោយមក ទើបលោក ក បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារដើម្បីរឹបអូសជាបណ្តោះអាសន្ននូវរថយន្តមួយគ្រឿងរបស់លោក ក។ នៅក្នុងករណីដូចនេះ គេត្រូវចាត់ទុកថាអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលលោក ក មានចំពោះលោក ខ ត្រូវបានផ្អាកដោយសារការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ។*

### ៣.១.៣. ការទទួលស្គាល់កាតព្វកិច្ច

បន្ថែមពីលើនេះ ការទទួលស្គាល់កាតព្វកិច្ច គឺជាស្ថានភាពដែលកូនបំណុលបានទទួលស្គាល់អត្ថិភាពនៃកាតព្វកិច្ចដោយបានធ្វើសកម្មភាពផ្សេងៗ នាំឱ្យម្ចាស់បំណុលមានជំនឿជឿជាក់ទៅលើកូនបំណុលមិនបាន

អនុវត្តសិទ្ធិរបស់ខ្លួននោះទេ។ គួរបញ្ជាក់ផងដែរ សកម្មភាពផ្សេងៗរបស់កូនបំណុលដែលចាត់ទុកថាជាការទទួលស្គាល់កាតព្វកិច្ច ពោលគឺការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេងៗ ជាអាទិ៍[96]។

***ឧទាហរណ៍៖*** *លោក ក បានឱ្យប្រាក់លោក ខ ខ្ចីចំនួន ១០លានរៀល ដោយលោក ក មានករណីយកិច្ចត្រូវបង់ការប្រាក់ចំនួន ៥ ម៉ឺនរៀល ក្នុងមួយខែ ក៏ប៉ុន្តែគូភាគីមិនបានព្រមព្រៀងអំពីការកំណត់សងឱ្យបានច្បាស់លាស់ណាមួយឡើយ។ ទោះបីជាយ៉ាងនេះក្តី លោក ខ បានបង់ការប្រាក់ជាទៀងទាត់ឱ្យទៅលោក ក ជារៀងរាល់ខែ ក្នុងអំឡុងពេល៥ ឆ្នាំ។ ដោយសារតែមូលហេតុ នេះហើយទើបលោក ក មិនដែលទាមទារឱ្យលោក ខ សងប្រាក់ដើមឱ្យរូបគាត់នោះទេ។ នៅក្នុងករណីបែបនេះ សកម្មភាពបង់ការប្រាក់ជារៀងរាល់ខែ គឺជាមូលហេតុនៃការផ្អាកអាជ្ញាយុកាល ដូច្នេះទោះបីជាលោក ក មិនបានទាមទារប្រាក់ដើមចំនួន ១០ លានរៀល ពីលោក ខ ក្នុងអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីពេលបង្កើតកិច្ចសន្យាខ្ចីបរិភោគមកក៏ដោយ ក៏សិទ្ធិលើបំណុលនេះមិនរលត់ឡើយ។*

### ៣.២. អានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ដូចបានពន្យល់ជូនរួចមកហើយថា នៅពេលដែលមានហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលដែលបានដំណើរការកន្លងមកត្រូវចាត់ទុកថាពុំមានអត្ថន័យតាមផ្លូវច្បាប់ឡើយ។ ដូចនេះ ត្រូវចាប់ផ្តើមគិតអំឡុងពេលនៃអាជ្ញាយុកាលជាថ្មីម្តងទៀត ក្រោយពីហេតុនៃការផ្អាកត្រូវបានចប់[97]។ ជាក់ស្តែងចំពោះការទាមទារតាមផ្លូវតុលាការ ហេតុនៃការផ្អាកត្រូវចប់នៅពេលដែលសេចក្តីសម្រេចបានចូលជាស្ថាពរ ហើយហេតុនៃការផ្អាកនោះក៏ត្រូវចប់ដែរ កាលបើនីតិវិធីនៃការអនុវត្តដោយបង្ខំ ឬការចាត់ចែងរក្សាការពារបានបញ្ចប់នោះ[98]។ មួយវិញទៀត សម្រាប់ហេតុផលនៃការផ្អាកដែលជាការទទួលស្គាល់កាតព្វកិច្ចវិញហេតុនៃការផ្អាកបានចប់ដំណាលគ្នានឹងពេលដែលអានុភាពនៃការផ្អាកបានកើតឡើង។

### ៣.៣. ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ម៉្យាងវិញទៀត ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺជាការបញ្ឈប់នៃដំណើរការនៃអាជ្ញាយុកាលតែក្នុងអំឡុងពេលដែលត្រូវបង្អង់តែប៉ុណ្ណោះ។ ចំពោះការបង្អង់នូវអាជ្ញាយុកាល គឺគ្រាន់តែជាការធ្វើកុំឱ្យអាជ្ញាយុកាលបានសម្រេចប៉ុណ្ណោះ។ វាមានន័យថាគ្រាន់តែជាការបញ្ឈប់នូវដំណើរការនៃអាជ្ញាយុកាល នៅក្នុងដំណាក់កាលចុងក្រោយដែលជាពេលបញ្ចប់អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិ

---

[96] មាត្រា ៤៨៩, ចំណុច គ, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[97] មាត្រា ៤៩៤, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[98] មាត្រា ៤៩៤, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

លើបំណុល[99]។ និយាយបានម្យ៉ាងទៀតថា ការបង្អង់ការសម្រេចអាជ្ញាយុកាល គឺជាការបញ្ឈប់ដំណើរការអាជ្ញាយុកាលសម្រាប់តែអំឡុងពេលនៃការបង្អង់ប៉ុណ្ណោះ ដោយមិនធ្វើឱ្យអំឡុងពេលដែលបានដំណើរការកន្លងមកត្រូវចាត់ជាអសារបង់នោះទេ។

តួយ៉ាង មូលហេតុនៃការបង្អង់នៃការរំលត់សិទ្ធិលើបំណុលរួមមានដូចតទៅ៖

- **ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយការដាស់តឿនរបស់គូភាគី។**
- **ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយការដាស់តឿនតាមផ្លូវតុលាការ។**
- **ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ។**
- **ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលរវាងប្ដីប្រពន្ធ។**
- **ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយមហន្តរាយធម្មជាតិ។**

### ៣.៣.១. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយការដាស់តឿនរបស់គូភាគី

យោងតាមមាត្រា ៤៩៥ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិថា ប្រសិនបើអ្នកមានសិទ្ធិដាស់តឿននៅពេលណាមួយក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះមិនត្រូវបានសម្រេចចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ ខែ (ប្រាំមួយ) ខែ បន្ទាប់ពីការដាស់តឿនឡើយ។ ប៉ុន្តែបើទោះបីជាអ្នកមានសិទ្ធិដាស់តឿនម្តងទៀតក៏ដោយ ក៏មិនអាចពន្យឹតការសម្រេចអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលដោយការដាស់តឿនម្តងទៀតនោះដែរ។ ដូច្នេះបានសេចក្តីថា ឱ្យតែស្ថិតនៅក្នុងអំឡុងពេលនៃអាជ្ញាយុកាលដើម ម្ចាស់បំណុលអាចធ្វើការដាស់តឿនប៉ុន្មានដងក៏បានដែរ ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែបន្ទាប់ពីការដាស់តឿនចុងក្រោយ។

***ឧទាហរណ៍៖*** *សិទ្ធិលើបំណុលមួយត្រូវសង នៅខែមេសា ឆ្នាំ២០១០។ ក៏ប៉ុន្តែ នៅខែកុម្ភៈ ឆ្នាំ២០១៥ (នៅសល់ ២ ខែទៀត ត្រូវផុតអាជ្ញាយុកាល ពោលគឺ ខែមេសា ឆ្នាំ២០១៥) ម្ចាស់បំណុលបានធ្វើការដាស់តឿនឱ្យកូនបំណុលសង។ នៅក្នុងករណីនេះ នឹងត្រូវពន្យាពេលការសម្រេចអាជ្ញាយុកាល ៦ ខែ គិតចាប់ពីពេលដាស់តឿន ពោលគឺហូតដល់ខែ សីហា ឆ្នាំ២០១៥។ ក៏ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលបានធ្វើការដាស់តឿនឱ្យកូនបំណុលសង នៅខែមីនា ឆ្នាំ២០១៥ (ស្ថិតក្នុងអំឡុងពេលអាជ្ញាយុកាលដើម) នោះការពន្យាអំឡុងពេលនៃការសម្រេចអាជ្ញាយុកាល ៦ ខែ ត្រូវគិតចាប់ពីខែ មីនា ឆ្នាំ២០១៥។ ផ្ទុយទៅវិញ*

[99] សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ៖ មេធាវី ហេង បូរ៉ា ទំព័រទី១៨០

*ប្រសិនបើម្ចាស់បំណុលបានធ្វើការដាស់តឿនឱ្យកូនបំណុលនៅខែ ឧសភា ឆ្នាំ២០១៥ ការពន្យឺតអំឡុងពេលនៃការសម្រេចអាជ្ញាយុកាល ៦ ខែ មិនត្រូវចាប់រាប់ពីខែ ឧសភា នោះទេ ក៏ប៉ុន្តែត្រូវគិតចាប់ពីពេលដាស់តឿនចុងក្រោយនៃអាជ្ញាយុកាលដើម ពោលគឺ ខែមីនា ឆ្នាំ២០១៥។*

### ៣.៣.២. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយការដាស់តឿនតាមផ្លូវតុលាការ

ម្យ៉ាងវិញទៀត ត្រូវបានចាត់ទុកថាជាការដាស់តឿនតាមផ្លូវតុលាការ ចាប់ពីពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្តឹងត្រូវបានលើកចោល ឬដកវិញនោះ[100]។ ដូច្នេះអាជ្ញាយុកាលមិនអាចសម្រេចបានឡើយក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីការលើកបណ្តឹងចោល ឬការដកពាក្យបណ្តឹង។ ក្នុងន័យប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើអ្នកមានសិទ្ធិបានអះអាងពីសិទ្ធិរបស់ខ្លួនក្នុងនាមជាចុងចម្លើយនៅក្នុងបណ្តឹង ក៏ត្រូវចាត់ទុកថាអ្នកនោះបានដាស់តឿនជាបន្តនៅក្នុងអំឡុងពេលបណ្តឹងនេះតែម្តង។ នៅក្នុងករណីនេះ អាជ្ញាយុកាលមិនត្រូវសម្រេចឡើយក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីសាលក្រម ឬសាលដីកានៃបណ្តឹងនោះចូលជាស្ថាពរ[101]។

### ៣.៣.៣. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ

ការបង្អង់អាជ្ញាយុកាលក្នុងករណីអនីជន ឬជននៅក្រោមអាណាព្យាបាលទូទៅ គឺធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់អនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ ពីការដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានសម្រេច ដោយសារតែជននោះពុំបានចាត់វិធានការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានដោយខ្លួនឯង។ ដូច្នេះហើយប្រសិនបើអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅគ្មានអ្នកតំណាងដែលច្បាប់បានកំណត់នៅអំឡុងពេល ៦ ខែមុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាល តួយ៉ាងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែ ក្រោយពីជននោះក្លាយជាសមត្ថជន ឬមានអ្នកតំណាងដែលច្បាប់កំណត់[102]។

***ឧទាហរណ៍៖*** *កុមារី ក ជាអនីតិជនអាយុ១៦ ឆ្នាំ ហើយត្រូវឪពុកម្តាយស្លាប់ចោលដោយសារគ្រោះថ្នាក់ចរាចរណ៍។ ពេលដែលឪពុកម្តាយរបស់កុមារី ក នៅរស់ លោក ខ បានជំពាក់ប្រាក់ឪពុកម្តាយរបស់កុមារី ក ចំនួន ៨៥០០ ដុល្លារអាមេរិក ដូចនេះសិទ្ធិលើបំណុលនេះត្រូវបានបន្តទៅកុមារី ខ*

[100] មាត្រា ៤៩៥, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[101] មាត្រា ៤៩៥, កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[102] មាត្រា ៤៩៦, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

*ដែលជាកូនរបស់ពួកគាត់។ ចំពោះករណីនេះ ប្រសិនបើកុមារី ក ពុំបានដឹងអំពីអាជ្ញាយុកាលនៃសិទ្ធិលើបំណុលរបស់ខ្លួនដែលមានបន្តពីឪពុកម្តាយរបស់ខ្លួន ហើយក៏ពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ក្នុងអំឡុងពេល ៦ ខែ មុនអំឡុងពេលផុតអាជ្ញាយុកាល នោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចឡើយ បន្ទាប់ពីកុមារី ក បានក្លាយជាសមត្ថជន ឬមានអ្នកតំណាងដែលច្បាប់បានកំណត់។*

### ៣.៣.៤. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលរវាងប្តីប្រពន្ធ

ការចាត់វិធានការ ចំពោះការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរវាងប្តីប្រពន្ធជារឿងមួយដែលមានការពិបាក ហេតុនេះច្បាប់បានទុករយៈពេលមួយសមស្រប ក្រោយពីការរំលាយអាពាហ៍ពិពាហ៍ដើម្បីបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ក្នុងករណីមានចែងក្នុងមាត្រា ៤៩៧ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ចំពោះសិទ្ធិដែលសហព័ទ្ធម្ខាងទៀតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែ ក្រោយពីការរំលាយអាពាហ៍ពិពាហ៍ឡើយ។

***ឧទាហរណ៍៖*** *លោក ក និងលោកស្រី ខ ជាប្តីប្រពន្ធនឹងគ្នា។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤ លោក ក បានខ្ចីប្រាក់ពីអ្នកស្រី ខ ចំនួន ៥០០០០ ដុល្លាអាមេរិក ដើម្បីយកទៅវិនិយោគទុនដោយសន្យាថាសងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើ បំណុល៥ឆ្នាំ គឺនៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០ ហើយនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ អ្នកទាំងពីរបានលែងលះគ្នាហើយសាលក្រមបានចូលជាស្ថាពរនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤។ នៅក្នុងករណីនេះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែ ក្រោយពីសាលក្រមលែងលះចូលជាស្ថាពរ។*

### ៣.៣.៥. ការបង្អង់នៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ

ចុងក្រោយ ចំពោះការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារមហន្តរាយធម្មជាតិ សំដៅទៅលើករណីអ្នកដែលមានសិទ្ធិមិនអាចចាត់វិធានការឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិដូចជា ខ្យល់ព្យុះ រញ្ជួយដី ទឹកជំនន់ និងករណីប្រធានសក្តិផ្សេងៗជាដើម នៅពេលណាមួយក្នុងរយៈពេល ៦ ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល នោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីប្រធានសក្តិនោះបានកន្លងផុតឡើយ[103]។

[103] មាត្រា ៤៩៨, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

***ឧទាហរណ៍៖*** *លោក ក បានកិច្ចសន្យាលក់ទិញរថយន្តម៉ាក Rang Rover ជាមួយលោក ខ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤។ នៅក្នុងកិច្ចសន្យា លោក ក និងលោក ខ បានព្រមព្រៀងគ្នាថា លោក ក ត្រូវប្រគល់រថយន្តម៉ាក Rang Rover ឱ្យទៅលោ ខ នៅថ្ងៃបង្កើតកិច្ចសន្យា ហើយលោក ខ ត្រូវបង់ប្រាក់លក់ទិញ៤ខែក្រោយថ្ងៃបង្កើតកិច្ចសន្យាគឺនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤។ ប៉ុន្តែ លុះដល់ថ្ងៃកំណត់សងលោក ខ ពុំបានបង់ប្រាក់ថ្លៃលក់ទិញឱ្យទៅលោក ក នោះទេ។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ មុនថ្ងៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរលត់ ( នៅសល់រយៈពេល១ខែ )ក៏ស្រាប់តែមានទឹកជំនន់កើតឡើងដែលជាហេតុធ្វើឱ្យលោក ក មិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបានទាន់ពេលវេលា ហើយនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ទឹកជំនន់បានស្រកវិញ ជារួមមកអាជ្ញាយុកាលនៃរំលត់សិទ្ធិលើបំណុលត្រូវបានបង្អង់ចំនួន ៦ ខែ បន្ទាប់ពីថ្ងៃទឹកជំនន់ត្រូវបានស្រក គឺចាប់ពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។*

### ៣.៤. អានុភាពនៃការបង្អង់អាជ្ញាយុកាល

ដូចដែលបានពន្យល់ខាងលើរួចមកហើយ ការបង្អង់ គឺជាការបញ្ឈប់ដំណើរការនៃអាជ្ញាយុកាលតែនៅក្នុងអំឡុងពេលដែលត្រូវបង្អង់នោះតែប៉ុណ្ណោះ។ ការបង្អង់អាជ្ញាយុកាល គឺគ្រាន់តែជាការធ្វើកុំឱ្យអាជ្ញាយុកាលមានសម្រេចមានន័យថា វាគ្រាន់តែជាការបញ្ឈប់នូវដំណើរការនៃអាជ្ញាយុកាលនៅដំណាក់ចុងក្រោយដែលជាពេលបញ្ចប់នៃអំឡុងពេលនៃអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ដូច្នេះយើងអាចធ្វើការទាញសេចក្តីសន្និដ្ឋានបានថា ការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវរាប់អាជ្ញាយុកាលបន្តទៀតនៅពេលដែលមូលហេតុនៃការបង្អង់ត្រូវបានបញ្ចប់ដែលការបង្អង់នេះមានភាពខុសគ្នាពីការផ្អាកអាជ្ញាយុកាល។

## កថាភាគទី៤. ការអនុវត្តសិទ្ធិលុបចោល

ទោះបីជាកិច្ចសន្យាត្រូវបានបង្កើតឡើងក៏ដោយ ក៏កិច្ចសន្យាទាំងនោះមិនប្រាកដថាអាចអនុវត្តបាននោះទេ។ កិច្ចសន្យាមួយចំនួនអាចត្រូវបានភាគីសុំលុបចោល ហើយកិច្ចសន្យាមួយចំនួនទៀតត្រូវបានច្បាប់ចាត់ទុកជាមោឃៈភាព ដោយសារតែមានវិការៈ ឬដោយសារការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។

លើសពីនេះទៅទៀត ក្រៅពីកិច្ចសន្យា សកម្មភាពឯកតោភាគីក៏ត្រូវបានចាត់ទុកជាមោឃៈ ឬត្រូវលុបចោលតាមរយៈការបង្ហាញឆន្ទៈមានវិការៈ ឬការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពជាដើម។

### ៤.១. លក្ខខណ្ឌនៃការលុបចោល

ប្រសិនបើមានមូលហេតុនៃការលុបចោលសកម្មភាពនោះ អ្នកមានសិទ្ធិអាចលុបចោលសកម្មនោះបាន[104]។ មូលហេតុនៃការលុបចោលមានដូចជា ការបង្ហាញឆន្ទៈដែលមានវិការៈ (មាត្រា ៣៤៦ ដល់ មាត្រា ៣៥១ នៃក្រមរដ្ឋវេណី) កង្វះសមត្ថភាពខាងឆន្ទៈ (មាត្រា ១៤ នៃក្រមរដ្ឋប្បវេណី) និងការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព (មាត្រា១៨ មាត្រា២៦ និងមាត្រា៣០ នៃក្រមរដ្ឋប្បវេណី)។

ជាគោលការណ៍ **អ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យាដោយសារការបង្ហាញឆន្ទៈមានវិការៈ** រួមមាន៖

- អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះ
- សន្តតិជនរបស់អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ ឬ
- អ្នកទទួលបន្តឋានៈក្នុងកិច្ចសន្យាពីអ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ[105]។

បន្ថែមពីនេះទៀត **អ្នកដែលមានសិទ្ធិលុបចោលចំពោះការលុបចោលដោយមូលហេតុគ្មានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ** មានដូចជា៖

- អ្នកបង្ហាញឆន្ទៈ
- អ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកដែលបង្ហាញឆន្ទៈ
- ហិតូបត្ថម្ភកៈនៃអ្នកបង្ហាញឆន្ទៈ
- សន្តតិជនរបស់អ្នកបង្ហាញឆន្ទៈ
- អច្ច័យលាភីសកលរបស់អ្នកបង្ហាញឆន្ទៈ[106]។

#### ៤.១.១. វិការៈក្នុងការបង្ហាញឆន្ទៈ

កិច្ចសន្យាមានអានុភាព នៅពេលការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរស្របគ្នាទៅវិញទៅមក។ ហេតុដូច្នេះហើយ ប្រសិនបើគ្មានការបង្ហាញឆន្ទៈដែលមានអានុភាពដែលជាធាតុផ្សំនៃកិច្ចសន្យាទេ កិច្ចសន្យានោះពុំមានចំណងចងភាគីទាំងពីរទេ ទោះបីជាកិច្ចសន្យាហាក់ដូចជាត្រូវបានបង្កើតឡើងបើមើលទៅពីខាងក្រៅក៏ដោយ។ តាមន័យនេះបានសេចក្ដីថា ការបង្ហាញឆន្ទៈដែលមានសុពលភាព គឺជាលក្ខខណ្ឌដើម្បីឱ្យកិច្ចសន្យាមាន

[104] មាត្រា ៣៥៨, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[105] មាត្រា ៣៥៩, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[106] មាត្រា ៣៥៩, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អានុភាពចងភាគីទាំងពីរនៃកិច្ចសន្យា ហើយមូលហេតុដែលកំណត់ស្ថានភាពបែបនេះដើម្បីរកដំណោះស្រាយតាមផ្លូវច្បាប់ ចំពោះករណីដែលការបង្ហាញឆន្ទៈរបស់ភាគីនីមួយៗមានវិការៈពីព្រោះការបង្ហាញឆន្ទៈបែបនេះមិនត្រូវបានទទួលស្គាល់នោះទេ ដោយដំណោះស្រាយចំពោះបញ្ហានេះ គឺជាការលុបចោលកិច្ចសន្យា។

តួយ៉ាង ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានកំណត់អំពីស្ថានភាពដែលចាត់ទុកថាជាការបង្ហាញឆន្ទៈរបស់ភាគីដែលមានវិការៈមានដូចជា៖

- ***ការភាន់ច្រលំ*** គឺជាករណីដែលអ្នកបង្ហាញឆន្ទៈធ្វើការបង្ហាញឆន្ទៈដែលមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈពិតរបស់ខ្លួន ហើយគេមិនដឹងអំពីភាពខុសគ្នានេះនៅពេលដែលគេធ្វើការបង្ហាញឆន្ទៈឡើយ[107]។

ជារួមមក ចំពោះការភាន់ច្រលំត្រូវបានស្ថិតក្នុងស្ថានភាពដូចជា៖ **ការភាន់ច្រលំលើចំណុចសំខាន់ៗដែលជាកម្មវត្ថុនៃកិច្ចសន្យា**[108] **ការភាន់ច្រលំទៅលើចំណុចនៃកិច្ចសន្យាដែលភាគីយល់ថាសំខាន់**[109] និង **ការភាន់ច្រលំដោយភាគីទាំងសងខាង**[110]។

***ឧទាហរណ៍៖*** *បុគ្គលម្នាក់និយាយថា គេចង់ទិញមាស ស (ការបង្ហាញឆន្ទៈ) នៅពេលដែលគេមានបំណងពិតប្រាកដគឺ ប្លាទីន (ឆន្ទៈពិត) ពីព្រោះគាត់គិតថាមាស ស និងប្លាទីនជាវត្ថុដូចគ្នា។*

- ***ការឆបោក*** មានន័យថា បុគ្គលណាម្នាក់ ឬតតិយជនបានធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រលំដោយសារមធ្យោបាយឆបោក ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួនដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន និងមិនបានដឹងពីភាពខុសគ្នានេះនៅពេលដែលធ្វើការបង្ហាញឆន្ទៈ[111]។ គោលបំណងនៃការឆបោកធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រលំដោយភាគីម្ខាងទៀត ឬតតិយជនបានដឹងថាសកម្មភាពរបស់ខ្លួន គឺជាសកម្មភាពឆបោក និងអ្នកដែលបង្ហាញឆន្ទៈមានការភាន់ច្រលំដោយសារតែសកម្មភាពឆបោករបស់ខ្លួន។ ចំពោះការឆបោកត្រូវបានបែងចែកជាពីរ៖ **ការឆបោកដោយភាគីម្ខាងទៀត**[112] និង**ការឆបោកដោយតតិយជន**[113]។

[107] មាត្រា ៣៤៦, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[108] មាត្រា ៣៤៦, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[109] មាត្រា ៣៤៦, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[110] មាត្រា ៣៤៦, កថាខណ្ឌទី៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[111] សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ មេធាវី ហេង បូរ៉ា ទំព័រទី៦៣

[112] មាត្រា ៣៤៧, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[113] មាត្រា ៣៤៧, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

***ឧទាហរណ៍៖*** *លោក ក មានដីមួយកន្លែងស្ថិតនៅខេត្តកណ្តាល ហើយលោក គ បានប្រាប់ អ្នកស្រី ខ ថាដីរបស់លោក ក នឹងមានការអភិវឌ្ឍន៍ឆាប់ៗនេះ។ គ្រាន់តែឮដូច្នេះ លោកស្រី ខ ក៏បាន ទិញដីនោះពីលោក ក។ នៅក្នុងករណីនេះ លោកស្រី ខ មានការភាន់ច្រលំដោយសារតែជឿលើការឆបោករបស់លោក គ។*

- ***ព័ត៌មានមិនពិត*** សំដៅទៅលើករណីដែលហេតុ ដែលត្រូវបានលើកឡើងដោយភាគីដែលជាមូលដ្ឋាននៅក្នុងការបង្កើតកិច្ចសន្យា គឺខុសពីការពិត។ ទន្ទឹមនឹងនេះ ប្រសិនបើអ្នកបង្ហាញឆន្ទៈបានដឹងថាហេតុនោះមិនមែនជាការពិតនោះ ខ្លួននឹងមិនបង្ហាញឆន្ទៈទេ។ ដូច្នេះ អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាដោយសារការបង្ហាញឆន្ទៈនោះមានវិការៈ។ នៅក្នុងករណីនៃព័ត៌មានមិនពិតគេតម្រូវឱ្យភាគីម្ខាងទៀតមិនបានដឹងថាហេតុដែលគាត់បានលើកឡើងនេះមិនមែនជាការពិត[114]។

- ***ការរំលោភលើស្ថានភាព*** សំដៅទៅលើករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះនូវការលំបាកផ្នែកសេដ្ឋកិច្ច ឬសង្គម ឬបានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ[115]។

- ***ការគម្រាមកំហែង*** សំដៅទៅលើករណីដែលអ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួនដែលផ្ទុយនឹងគោលបំណងរបស់ខ្លួនដោយមានការភ័យខ្លាចដែលបានបង្កឡើងដោយភាគីម្ខាងទៀត ឬតតិយជន[116]។

- ***អំពើកេងយកចំណេញហួសហេតុ*** គឺជាស្ថានភាពដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ខ្លៅ ឬការខ្វះបទពិសោធន៍ហើយយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ[117]។

### ៤.១.២. កង្វះសមត្ថភាពខាងឆន្ទៈ

ចំពោះករណីការកង្វះសមត្ថភាពខាងឆន្ទៈ គឺសំដៅលើសកម្មភាពដែលភាគីបានធ្វើមិនយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន[118]។ បានសេចក្តីថានៅពេលដែលរូបវន្តបុគ្គលបានធ្វើសកម្មភាពនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងធ្វើការវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ច្បាប់ទទួលស្គាល់ដោយអនុញ្ញាតឱ្យលុបចោលវិញបានទោះបីជាមិនមែនជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ។

---

114 សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ ទំព័រទី១៣២

115 សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ ទំព័រទី១៣៣

116 សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ៖ មេធាវី ហេង បូរ៉ា ទំព័រទី៦៥

117 មាត្រា ៣៥១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

118 មាត្រា ១៤, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៤.១.៣. ជនកម្រិតសមត្ថភាព

នៅពេលសកម្មភាព ឬបង្កើតទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយដើម្បីទទួលបានការការពារតាមផ្លូវច្បាប់ ត្រូវតែទាមទារឱ្យច្បាប់ទទួលស្គាល់ថាមានសមត្ថភាពនៃកម្មភាពជាមុនសិន។យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិអំពីស្ថានភាពស្តីពីជនដែលត្រូវបានកម្រិតសមត្ថភាពមានដូចជា៖ **អនីតិជន, ជននៅក្រោមអាណាព្យាបាលទូទៅ** និង**ជននៅក្រោមហិតូបត្ថម្ភ**។

- **អនីតិជន** សំដៅទៅលើជនដែលមានអាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ[119]។ ហេតុដូចនេះនៅពេលដែលអនីតិជនធ្វើសកម្មភាពដោយមិនទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននាំឱ្យសកម្មភាពនេះអាចលុបចោលបាន លើកលែងតែសកម្មភាពទទួលសិទ្ធិ ឬសកម្មភាពរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងទៅនឹងសកម្មភាពរស់នៅប្រចាំថ្ងៃ[120]។

- **ជននៅក្រោមអាណាព្យាបាលទូទៅ** គឺជាជនស្ថិតនៅក្រោមស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យ ដោយសារតែវិបត្តិផ្នែកស្មារតីដូចជា ជនដែលមិនអាចធ្វើសកម្មភាពសម្រាប់ជីវភាពប្រចាំថ្ងៃ ជនដែលមិនដឹងថាមានរឿងអ្វីកើតឡើងជុំវិញខ្លួនឯង គ្រួសារ ឬសង្គមជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ[121]។ ក្នុងករណីបែបនេះ ចំពោះសកម្មភាពដែលបានធ្វើឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅដោយផ្ទាល់ លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃសាមីខ្លួន ឬអ្នកអាណាព្យាបាលទូទៅអាចលុបចោលបាន[122]។

- **ជននៅក្រោមហិតូបត្ថម្ភ** គឺជាអ្នកមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី[123]។ នៅពេលដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើសកម្មភាពដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ លើកលែងតែសកម្មភាពដែលទាក់ទងជីវភាពរស់នៅប្រចាំថ្ងៃហិតូបត្ថម្ភកៈអាចលុបចោលសកម្មភាពនោះបាន[124]។

---

[119] មាត្រា ១៧, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[120] មាត្រា ១៨, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[121] សៀវភៅនីតិរដ្ឋប្បវេណី (បុគ្គលភាពគតិយុត្ត) បង្រៀនដោយសាស្ត្រាចារ្យ៖ មេធាវី អ៊ីវ ប៉ូលី ទំព័រទី៦

[122] មាត្រា ២៦, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[123] សៀវភៅនីតិរដ្ឋប្បវេណី (បុគ្គលភាពគតិយុត្ត) បង្រៀនដោយសាស្ត្រាចារ្យ៖ មេធាវី អ៊ីវ ប៉ូលី ទំព័រទី៧

[124] មាត្រា ៣០, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៤.២. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល

សិទ្ធិលុបចោល និងសិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើងដោយសារការលុបចោលនឹងត្រូវរលត់ បើមិនប្រើសិទ្ធិនេះក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន[125]។ ពេលដែលអាចផ្តល់សច្ចានុមតិបាន គឺពេលដែលអ្នកមានសិទ្ធិលុបចោលដឹងអំពីមូលហេតុនៃការលុបចោល ឬពេលដែលសមត្ថភាពដែលបានកម្រិតបានត្រឡប់មកភាពដើមវិញ។ លើសពីនេះទៅទៀត ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពនោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ[126]។

### ៤.៣. អានុភាពនៃការលុបចោល

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោលបានធ្វើការលុបចោលសកម្មភាពនោះ[127]។ ក៏ប៉ុន្តែ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោលបានធ្វើការលុបចោលសកម្មភាពដែលអាចលុបចោលបាន ហើយសកម្មភាពនោះត្រូវចាត់ទុកថាជាមោឃៈភាពតាំងពីដំបូង[128] មានន័យថាការលុបចោលកិច្ចសន្យាមានអានុភាពប្រតិសកម្ម។

### ៤.៤. លក្ខខណ្ឌនៃការមោឃៈភាព

ជាការពិតណាស់ទោះបីជាកិច្ចសន្យា ឬសកម្មភាពឯកតោភាគីត្រូវបានបង្កើតឡើងក៏ដោយប្រសិនបើអត្ថន័យនៃកិច្ចសន្យានោះមានភាពផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ នោះកិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ និងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈភាពដោយសារសកម្មភាពនោះ ផ្ទុយនឹងទម្រង់ដែលច្បាប់បានទាមទារដោយក្រមនេះ ឬច្បាប់ផ្សេង។ ចំពោះការមោឃៈភាព មិនមែនតែភាគីនៃកិច្ចសន្យា ឬសកម្មភាពឯកតោភាគីទេរួមទាំងបុគ្គលផ្សេងទៀតក៏អាចអះអាងអំពីមោឃៈភាពនៃសកម្មភាពនោះបានដែរ[129]។

---

[125] មាត្រា ៣៦៣, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[126] មាត្រា ៣៦៣, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[127] មាត្រា ៣៥៨, កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[128] មាត្រា ៣៥៨, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[129] មាត្រា ៣៥៧, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៤.៤.១ ការបង្ហាញឆន្ទៈមិនពិត

ការបង្ហាញឆន្ទៈមិនពិត គឺជាស្ថានភាពនៃការឃុបឃិតជាមួយភាគីម្ខាងទៀតក្នុងការបង្កើតកិច្ចសន្យា ដោយត្រូវបំពេញលក្ខខណ្ឌដូចជា អ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈមិនពិត អ្នកបង្ហាញឆន្ទៈ និងភាគីម្ខាងទៀតឃុបឃិតគ្នាដើម្បីបង្កើតកិច្ចសន្យា។ ជាគោលការណ៍ មោឃភាពនៃកិច្ចសន្យាមិនអាចអះអាងចំពោះតតិយជនសុចរិត និងគ្មានកំហុស ប៉ុន្តែការបង្ហាញឆន្ទៈមិនពិត មិនផ្ទុយនឹងច្បាប់ ឬសណ្តាប់ធ្នាប់សាធារណៈនោះទេ ទោះបីជាបែបនេះក៏ដោយ ក៏ត្រូវការពារតតិយជនដែលបានជឿជាក់ទៅលើស្ថានភាពដែលបានកើតឡើងដោយការបង្ហាញឆន្ទៈមិនពិតនោះ ហេតុនេះអ្នកបង្ហាញឆន្ទៈមិនអាចអះអាងអំពីមោឃភាពនៃកិច្ចសន្យាចំពោះតតិយជន និងគ្មានកំហុសដនោះទេ[130]។

***ឧទាហរណ៍៖*** *ដើម្បីជៀសវាងការរឹបអូសរបស់ម្ចាស់បំណុល លោក ក បង្ហាញឆន្ទៈថាឱ្យដី របស់គាត់ (កិច្ចសន្យាប្រទានកម្ម) ទៅលោក ខ ប៉ុន្តែភាពពិតលោក ក គ្មានឆន្ទៈពិតប្រាកដក្នុងការឱ្យដីបសើគាត់ទៅលោក ខ ឡើយហើយលោក ខ ក៏បានដឹងថាឆន្ទៈរបស់លោក ក ដែលឱ្យដីរបស់គាត់មកខ្លួន គឺជាឆន្ទៈមិនពិត នៅតែសហការជាមួយលោក ក បង្កើតកិច្ចសន្យាប្រទានកម្ម ដូច្នេះកិច្ចសន្យាបែបនេះត្រូវចាត់ទុកជាមោឃៈ។*

### ៤.៤.២. កិច្ចសន្យាផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ

អត្ថន័យនៃកិច្ចសន្យាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺជាបញ្ញត្តិដែលព្យាយាមបង្ខំភាគីនៃកិច្ចសន្យាឱ្យគោរពតាមអត្ថន័យពិតប្រាកដនៃបញ្ញត្តិនោះ ឬហាមឃាត់មិនឱ្យកិច្ចសន្យាមានអត្ថន័យខុសពីអត្ថន័យបញ្ញត្តិនោះ។ ហេតុនេះកិច្ចសន្យាទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងបញ្ញត្តិដែលអនុវត្តបង្ខំកិច្ចសន្យានោះត្រូវបានចាត់ទុកជាមោឃៈ[131]។

### ៤.៤.៣. កិច្ចសន្យាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ

លើសពីនេះទៅទៀត ចំពោះអត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ[132] ត្រូវកំណត់ដោយយុត្តិសាស្ត្ររបស់តុលាការកំពូល ប៉ុន្តែយើងអាចកំណត់បានថាសកម្មមួយចំនួនបានបំពានសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អដូចជា ការជួញដូរមនុស្ស សរីរាង្គ គ្រឿងញៀន ជាអាទិ៍ និងទោះបីជាយ៉ាងណាក៏ដោយការវាយតម្លៃពីភាពផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ អាស្រ័យលើភាពជាក់ស្តែងនៅក្នុងសង្គមនីមួយៗ។ មួយវិញទៀត ចំពោះការវាយតម្លៃសង្គមមានការប្រែប្រួល

---

[130] មាត្រា ៣៥៣, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[131] មាត្រា ៣៥៤, កថាខណ្ឌទី១, ចំណុច ក, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[132] មាត្រា ៣៥៤, កថាខណ្ឌទី១, ចំណុច ខ, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ហេតុនេះ យើងត្រូវវិនិច្ឆ័យចំពោះសកម្មភាពបំពានសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អនៅពេលបង្កើតកិច្ចសន្យា។

### ៤.៤.៤. កិច្ចសន្យាផ្ទុយនឹងទម្រង់នៃច្បាប់កំណត់

ទោះបីជាអត្ថន័យនៃកិច្ចសន្យា ឬសកម្មភាពឯកតោភាគីមិនផ្ទុយទៅនឹងបញ្ញត្តិអនុវត្តដោយបង្ខំ ឬសណ្តាប់ធ្នាប់សាធារណៈក៏ដោយ តែបើសកម្មភាពនោះផ្ទុយទៅនឹងទម្រង់ដែលច្បាប់កំណត់ក៏ត្រូវចាត់ទុកថាជាមោឃៈផងដែ[133]។

***ឧទាហរណ៍៖*** *លោក ក និងលោកស្រី ខ បានព្រមព្រៀងគ្នាលក់ទិញអចលនវត្ថុ ប៉ុន្តែមិនបានធ្វើឡើងជាលិខិតយថាភូតទេ ក្នុងករណីនេះកិច្ចសន្យាត្រូវចាត់ទុកជាមោឃៈ។*

### ៤.៥. អានុភាពនៃការមោឃៈភាព

នៅពេលដែលសកម្មភាពមួយត្រូវបានចាត់ទុកថាជាមោឃៈ មានន័យថាសកម្មភាពនោះមិននាំឱ្យបង្កើតអានុភាពតាំងពីដំបូង[134]។ ការណ៍ដែលនរណាម្នាក់អះអាងអំពីមោឃភាពនៃសកម្មភាពនោះ គឺជាការបញ្ជាក់ថាសកម្មភាពនោះមិនមានសុពលភាពតាំងពីដំបូង ហើយមិនធ្លាប់មានអានុភាពអ្វីទាល់តែសោះ។ និយាយរួមសកម្មភាពដែលត្រូវបានចាត់ទុកថាជាមោឃៈ ទោះបីជាមិនមាននរណាម្នាក់អះអាងអំពីមោឃភាពនៃកិច្ចសន្យាក៏ដោយក៏មិនមានអានុភាពដែរ។

[133] មាត្រា ៣៥៧, កថាខណ្ឌទី២, ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[134] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ ទំព័រទី១០៩

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ក្រោយពីយើងបានធ្វើការខិតខំសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណាស្តីពី "**អនុប្បទាន និងការរំលត់សិទ្ធិលើបំណុល**" រួចមក យើងខ្ញុំទទួលបាននូវបទពិសោធន៍ និងចំណេះដឹងយ៉ាងច្រើនអំពីប្រធានបទមួយនេះ។ កាន់តែពិសេសជាងនេះទៅទៀត ប្រធានបទខាងលើនេះបានផ្តល់ជាអត្ថប្រយោជន៍យ៉ាងច្រើនក្រៃលែងទៅដល់អ្នកសិក្សាស្រាវជ្រាវទាក់ទងនឹងបញ្ហាទាំងអស់នេះ ហើយសារណាមួយនេះក៏អាចក្លាយជាជំនួយស្មារតីសំខាន់បំផុតសម្រាប់បងប្អូនមិត្តនិស្សិតអ្នកអានទាំងអស់ ដោយសារតែសារណាមួយនេះបានធ្វើការពន្យល់យ៉ាងក្បោះក្បាយពីសារតានៃកាតព្វកិច្ច របបគតិយុត្តនៃអនុប្បទានសិទ្ធិលើបំណុល និងរបបគតិយុត្តនៃការរំលត់សិទ្ធិលើបំណុល។ មិនត្រឹមតែប៉ុណ្ណោះ សារៈសំខាន់ដែលកើតចេញពីការយល់ដឹងអំពីអនុប្បទាន និងការរំលត់សិទ្ធិលើបំណុល គឺជាកត្តាមួយយ៉ាងសំខាន់ក្នុងទំនាក់ទំនងប្រចាំថ្ងៃដោយបានការពារនូវផលប្រយោជន៍សារធារណៈ ព្រមទាំងចំពោះគូភាគីនៃកិច្ចសន្យា។

អនុប្បទានសិទ្ធិលើបំណុលត្រូវបានបញ្ញត្តិចាប់ពីមាត្រា៥០១ ដល់មាត្រា៥០៦ វាជាប្រតិបត្តិការមួយដែលមានភាគីពីរ គឺអនុប្បទាយី និងអនុប្បទានិក។ អនុប្បទាយីធ្វើអនុប្បទានសិទ្ធិលើបំណុលដែលខ្លួនមានលើកូនបំណុលឱ្យទៅអនុប្បទានិក ដែលបន្ទាប់មកអនុប្បទានិកនឹងក្លាយជាម្ចាស់បំណុលថ្មីរបស់កូនបំណុលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលម្ចាស់បំណុលមានលើកូនបំណុល។ អនុប្បទានសិទ្ធិលើបំណុលអាចធ្វើឡើងក្នុងគោលបំណងជាច្រើនដូចជា ដើម្បីដាក់សិទ្ធិលើបំណុលធ្វើជាប្រាតិភោគឱ្យអនុប្បទានិក ឬដើម្បីលក់សិទ្ធិលើបំណុលឱ្យទៅអនុប្បទានិក។ ទោះជាយ៉ាងណាការធ្វើអនុប្បទានសិទ្ធិលើបំណុលគឺមានអានុភាពតែអនុប្បទានិក និងអនុប្បទាយី តែប៉ុណ្ណោះប្រសិនបើអនុប្បទាយីមិនបានធ្វើការជូនដំណឹងស្តីពីការធ្វើអនុប្បទានទៅឱ្យកូនបំណុលនៃសិទ្ធិលើបំណុលនោះ ហើយថែមទាំងមិនអាចតតាំងជាមួយតតិយជនបានដែល ប្រសិនបើការជូនដំណឹងទៅកូនបំណុលនោះមិនបានធ្វើឡើងតាមរយៈលិខិតដែលមានកាលបរិច្ឆេទស្ថាពរ។ កាតព្វកិច្ច កើតឡើងមានឡើងនាំឱ្យកូនបំណុលមានករណីកិច្ចអនុវត្តមួយចំនួនចំពោះ ម្ចាស់បំណុល តែក៏មានករណីលើកលែងផងដែរ ប្រសិនបើកូនបំណុលចង់ឱ្យតតិយជនអនុវត្តជំនួស ដើម្បីឱ្យតតិយជនអនុវត្តកាតព្វកិច្ចបាន លុះត្រាតែបានបំពេញលក្ខខណ្ឌរួមមានការព្រមព្រៀង កាតព្វកិច្ចអាចអនុវត្តបាន និងគ្មានកាសន្យាពិសេស។ មួយវិញទៀត ការបង្កើតកាតព្វកិច្ចតែមួយលើកមិនចោទជាបញ្ហាចំពោះម្ចាស់បំណុល តែប្រសិនបើកាតព្វកិច្ចត្រូវបានបង្កើតច្រើនដង ប្រាកដណាស់ថាមានបញ្ហាស្មុគស្មាញចំពោះម្ចាស់បំណុលក្នុងការទទួលការអនុវត្តពីកូនបំណុល ដោយសារតែកូនបំណុលមានម្ចាស់បំណុលច្រើន។ ដូច្នេះ

អ្នកដែលមានសិទ្ធិលើកូនបំណុលដូចគ្នា អាចធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យាឱ្យទៅម្ចាស់បំណុលណាម្នាក់ក្នុងការទទួលការសងដោយមានអត្ថិភាព។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិអំពីការរលត់កាតព្វកិច្ចសម្រាប់អនុវត្តក្នុងទំនាក់ទំនងគតិយុត្តរវាងម្ចាស់បំណុល និងកូនបំណុល ដោយបានធ្វើការបង្ហាញយ៉ាងច្បាស់នូវសិទ្ធិ និងករណីកិច្ចចំពោះភាគី និងរឹតបន្តឹងនូវការអនុវត្តកាតព្វកិច្ចដោយសុចរិត និងជៀសវាងរាល់បញ្ហាគេចវេសមិនព្រមអនុវត្តកាតព្វកិច្ច។ នៅក្នុងនោះផងដែរ ចំពោះការរលត់កាតព្វកិច្ច ឬការរំលត់សិទ្ធិលើបំណុលត្រូវបានបែងចែកជាពីរដូចជា ការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពគូភាគី និងការរំលត់សិទ្ធិលើបំណុលតាមបញ្ញត្តិច្បាប់។ ចំពោះការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពគភាគី គឺជាការបង្ហាញឆន្ទៈរបស់គូភាគីក្នុងការរំលត់សិទ្ធិលើបំណុលដោយធ្វើការបំពេញនូវលក្ខខណ្ឌដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ រួមមាន ការសង ការទូទាត់ ការលើកលែងរបស់ម្ចាស់បំណុល នវកម្ម និងព្យាកុលភាព។ ដោយឡែក ចំពោះការរំលត់សិទ្ធិលើបំណុលតាមបញ្ញត្តិច្បាប់ សំដៅដល់ស្ថានភាពមួយដែលភាគីមិនបានធ្វើឱ្យកាតព្វកិច្ចនោះរលត់ដោយប្រើប្រាស់នូវលក្ខខណ្ឌមួយចំនួនដូចជាៈ ការសង ការទូទាត់ ការលើកលែង របស់ម្ចាស់បំណុល នវកម្ម និងព្យាកុលភាព ជាអាទិ៍។ ហេតុដូចនេះ ការរំលត់សិទ្ធិលើបំណុលត្រូវតែអនុលោមតាមបញ្ញត្តិច្បាប់កំណត់ ដែលជាស្ថានភាពមួយនៃការរំលត់កាតព្វកិច្ចដោយភាគីតែម្ខាងក្នុងកិច្ចសន្យាដោយធ្វើការបង្ហាញឆន្ទៈក្នុងការរំលត់កាតព្វកិច្ចនោះ។ ការបង្ហាញឆន្ទៈរំលត់កាតព្វកិច្ចដោយភាគីតែម្ខាងវាកើតឡើងតាមរយៈកំហុសរបស់ភាគីម្ខាងទៀតនៃកិច្ចសន្យាមិនព្រមអនុវត្តកាតព្វកិច្ច ឬបានធ្វើការអនុវត្តកាតព្វកិច្ចដោយបំពានទៅលើកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ បណ្តាលឱ្យមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យា។ ម៉្យាងវិញទៀត ទាក់ទងនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលក៏បានកំណត់អំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលផងដែរ សម្រាប់ការពារ ក៏ដូចជាជួយសង្គ្រោះដល់កូនបំណុលក្នុងករណីដែលម្ចាស់បំណុលធ្វេសប្រហែសមិនអើពើដល់សិទ្ធិលើបំណុល ដែលខ្លួនមានហួសរយៈពេលដែលកំណត់ដោយច្បាប់ដែលវាបានបង្ហាញឱ្យភាគី ដែលជាម្ចាស់បំណុលត្រូវតែយកចិត្តទុកដាក់ឱ្យរួសរាន់ក្នុងការអនុវត្តសិទ្ធិដែលខ្លួនមានជៀសវាងភាពធ្វេសប្រហែសបណ្តាលឱ្យបាត់បង់សិទ្ធិនោះ។ បន្ថែមពីនេះ កាតព្វកិច្ចនឹងត្រូវរលត់ផងដែរក្នុងករណីដែលកិច្ចសន្យានោះបង្កើតឡើងដោយជនកម្រិតសមត្ថភាព ឬការបង្ហាញឆន្ទៈមានវិការៈដែលនាំឱ្យភាគីម្ខាងអាចរំលត់កាតព្វកិច្ចបាន។ ជារួម ការរំលត់សិទ្ធិលើបំណុលតាមបញ្ញត្តិច្បាប់ រួមមានអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ការរំលាយកិច្ចសន្យាអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល និងការអនុវត្តសិទ្ធិលុបចោល។

# អនុសាសន៍

# អនុសាសន៍

ឆ្លើយតបទៅនឹងការសិក្សាស្រាវជ្រាវប្រធានបទ "**អនុប្បទាន និងការរំលត់សិទ្ធិលើបំណុល**" ក្នុងនាមយើងខ្ញុំជានិស្សិតដែលបានឆ្លងកាត់ការសិក្សាស្រាវជ្រាវអំពីប្រធានបទមួយនេះ ទោះបីជាក្នុងពេលការសិក្សាទៅលើប្រធានបទពុំសូវបានពេញ និងគ្រប់ចំណុចក៏ដោយ ចំពោះការយល់ឃើញវាពិតជាមានភាពចាំបាច់បំផុតសម្រាប់ឱ្យមានដំណើរការនៃការអនុវត្តប្រព្រឹត្តទៅស្របច្បាប់ ដោយលុបបំបាត់ភាពអសកម្មនានានៅក្នុងទំនាក់ទំនងគតិយុត្ត ដែលមានភាពចាំបាច់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ដូច្នេះយើងខ្ញុំសូមជូនជាទស្សនៈ ក៏ដូចជាដំណោះស្រាយដើម្បីឱ្យវិស័យនីតិរដ្ឋប្បវេណីមានភាពរីកចម្រើន។ ចំពោះប្រតិបត្តិការអនុប្បទានសិទ្ធិលើបំណុលមិនមានការផ្សព្វផ្សាយ និងឯកសារឱ្យបានទូលំទូលាយនោះទេ អាចជាឧបសគ្គសម្រាប់ការអនុវត្តប្រតិបត្តិការនេះ ពីព្រោះតម្លៃតាមផ្លូវច្បាប់នៃសិទ្ធិលើបំណុលក្នុងការយកមកធ្វើជាកម្មវត្ថុនៃការលក់ទិញ ឬធ្វើជាទ្រព្យធានា តាមរយៈយន្តការអនុប្បទានសិទ្ធិលើបំណុលនេះអាចនៅមិនទាន់យល់ដឹងឱ្យបានទូលំទូលាយនៅឡើយ។ ម៉្យាងវិញទៀត បើផ្អែកលើលក្ខខណ្ឌតតាំងដូចមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដើម្បីឱ្យមានការអនុវត្តប្រតិបត្តិការនេះឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ អនុប្បទាយី និងកូនបំណុល ត្រូវទទួលរងការដាក់បន្ទុកផ្នែកហិរញ្ញវត្ថុ និងស្មារតីយ៉ាងខ្លាំង ហើយលក្ខខណ្ឌតតាំងបច្ចុប្បន្ន ក៏មិនអាចធានាការពារនូវផលប្រយោជន៍របស់តតិយជនឱ្យបានល្អនោះដែរ។ អាស្រ័យហេតុនេះ ការផ្សព្វផ្សាយ និងការអភិវឌ្ឍលិខិតបទដ្ឋានគតិយុត្តលើអនុប្បទានសិទ្ធិលើបំណុលដូចជាការបង្កើតឱ្យមានយន្តការក្នុងការចុះបញ្ជីអនុប្បទានសិទ្ធិលើបំណុល តាមរយៈប្រព័ន្ធអនឡាញជាមួយនឹងឯកសារតម្រូវមួយចំនួនតូច ឬការសម្របសម្រួលនូវលក្ខខណ្ឌក្នុងការធ្វើលិខិតដែលកាលបរិច្ឆេទស្ថាពរពិតជាមានសារៈសំខាន់ ដោយហេតុថាតតិយជនមិនចាំបាច់ពឹងផ្អែកលើកូនបំណុលទាំងស្រុងដើម្បីទទួលបានដំណឹងពីស្ថានភាពរបស់សិទ្ធិលើបំណុល ហើយលក្ខខណ្ឌតតាំងអាចធ្វើឡើងជាមួយការចំណាយតិច និងមានភាពងាយស្រួល។

ផ្អែកតាមសម័យកាលបច្ចុប្បន្ន ឃើញមានការការវិវឌ្ឍទៅជាបន្តបន្ទាប់មុខឥតរហែ ហេតុដូចនេះហើយក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រ កម្ពុជា ឆ្នាំ២០០៧ គួរតែមានការធ្វើវិសោធន៍កម្មទាក់ទងនឹងផ្នែកអនុប្បទាន និងការរំលត់សិទ្ធិលើបំណុល ដោយហេតុថាមាត្រាមួយចំនួនហាក់បីដូចជាមិនមានលក្ខណៈសមប្រកបក្នុងស្ថានភាពសង្គម ហើយបានបង្កើតជាឱកាសឱ្យភាគីដែលមានគោលបំណងទុច្ចរិតបានបំពានទៅលើភាគីដែលសុចរិត។ ប្រសិនបើបន្តការអនុវត្តបែបនេះតទៅមុខប្រាកដណាស់ នឹងធ្វើឱ្យប្រជាពលរដ្ឋដែលសុចរិតមានការបាត់បង់ទំនុកចិត្តទៅលើប្រព័ន្ធនីតិរដ្ឋនៅកម្ពុជាសង្គមមួយមានភាពរីកចម្រើនទៅបានដោយផ្អែកលើមូលដ្ឋានច្បាប់ជាចម្បង។

# ឯកសារយោង

# ឯកសារយោង


## ១. បទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, នស/រកម/១២០៧/០៣០, កាលបរិច្ឆេទប្រកាសឱ្យប្រើ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ រៀបរាងដោយៈ ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ, កែសម្រួលលើកទី១, បោះពុម្ពនៅ រាជធានីភ្នំពេញ ដោយគម្រោងអភិវឌ្ឍវិស័យច្បាប់ និងតុលាការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ខែមេសា ឆ្នាំ២០១៣។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ គន្ថីទី៤ រៀបចំដោយៈ គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌, ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី រៀបរៀងដោយៈ គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា និងក្រុមការងារជប៉ុនដែលទទួលបន្ទុករៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ធ្វើនៅរាជធានីភ្នំពេញ ឆ្នាំ២០១១។

## ២. សៀវភៅច្បាប់ទូទៅ

- សៀវភៅនីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យៈ មេធាវី ហេង បូរ៉ា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំសិក្សា ២០២១-២០២២។
- នីតិរដ្ឋប្បវេណី បង្រៀនដោយសាស្ត្រាចារ្យៈ មេធាវី អ៊ីវ ប៉ូលី, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
- ព្រឹត្តិបត្រច្បាប់សាលាត្រាជូ, លេខទី២ ខែមករា ឆ្នាំ២០២២។

## ៣. វចនានុក្រមច្បាប់

- សន្ទានុក្រមរដ្ឋប្បវេណី

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

☞ ឧបសម្ព័ន្ធទី១ ៖ សារចារនៃភាគពុកិច្ច
☞ ឧបសម្ព័ន្ធទី២ ៖ របបគតិយុត្តនៃអនុប្បទានសិទ្ធិលើបំណុល
☞ ឧបសម្ព័ន្ធទី៣ ៖ របបគតិយុត្តនៃការរំលត់សិទ្ធិលើបំណុល

# ឧបសម្ព័ន្ធទី១

# គន្ថីទី ៤
# កាតព្វកិច្ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១
### ប្រភពនៃកាតព្វកិច្ច និង និយមន័យនៃពាក្យផ្សេងៗ

**មាត្រា ៣០៨.–** និយមន័យនៃកាតព្វកិច្ច

១-កាតព្វកិច្ចគឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត ។

២-បុគ្គលដែលមានករណីយកិច្ចហៅថា កូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល ។

៣-ម្ចាស់បំណុលមានសិទ្ធិត្រូវគ្នាទៅនឹងករណីយកិច្ចរបស់កូនបំណុល ។

**មាត្រា ៣០៩.–** ប្រភពនៃកាតព្វកិច្ច

១-កាតព្វកិច្ចកើតមានឡើងដោយកិច្ចសន្យា ដោយសកម្មភាពឯកតោភាគី ដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ ។

២-កាតព្វកិច្ចដែលកើតឡើងដោយកិច្ចសន្យា និង ដោយសកម្មភាពឯកតោភាគី គឺជាកាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ។

៣-កាតព្វកិច្ចដែលកើតឡើងដោយការគ្រប់គ្រងដោយឈឺឆ្អាល ដោយសេចក្តីចម្រើនដោយឥតហេតុ ដោយអំពើអនីត្យានុកូល និង ដោយបញ្ញត្តិនៃច្បាប់ គឺជាកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ។ បញ្ញត្តិពីជំពូកទី ៣ (ការអនុវត្តកិច្ចសន្យា) ដល់ជំពូកទី ៧ (ការរលត់កាតព្វកិច្ច) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកាតព្វកិច្ចដែលកំណត់

ដោយច្បាប់ ។

**មាត្រា ៣១០.–** និយមន័យនៃការបង្ហាញឆន្ទៈ

១-ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្ត ហៅថា ការបង្ហាញឆន្ទៈ ។

២-ការបង្ហាញឆន្ទៈ ត្រូវមានអានុភាព ចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះ បានទៅដល់ភាគីម្ខាងទៀត ។

**មាត្រា ៣១១.–** និយមន័យនៃកិច្ចសន្យា

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ។

**មាត្រា ៣១២.–** និយមន័យនៃសកម្មភាពឯកតោភាគី

១-សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) និង ផ្នែកទី ៤ (ការតំណាង) នៃជំពូកទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសកម្មភាពឯកតោភាគី ។

## ផ្នែកទី ២
## ប្រភេទ និង បែបយ៉ាងនៃកាតព្វកិច្ច

**មាត្រា ៣១៣.–** ប្រភេទនៃកាតព្វកិច្ច

ក្រៅពីគោលបំណងផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើវត្ថុ ឬ ប្រាក់ កាតព្វកិច្ចអាចមានគោលបំណងធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ ។

**មាត្រា ៣១៤.–** កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់

ចំពោះកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់អ្វីមួយ កូនបំណុលមានករណីយកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ ។

**មាត្រា ៣១៥.–** កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

១-ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ប្រសិនបើកម្មវត្ថុដែលត្រូវផ្ដល់ មានគុណភាពច្រើនយ៉ាង កូនបំណុលមានករណីយកិច្ចផ្ដល់នូវវត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់ ។ ក្នុងករណីដែលគូភាគីមិនកំណត់គុណភាពទេ កូនបំណុលមានករណីយកិច្ចផ្ដល់នូវវត្ថុដែលមានគុណភាពមធ្យម ។

២-ចំពោះកាតព្វកិច្ចដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុលបានកំណត់កម្មវត្ថុដែលត្រូវផ្ដល់ច្បាស់លាស់ និង ដែលបានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្ដល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុលមានករណីយកិច្ចផ្ដល់នូវវត្ថុនោះតែប៉ុណ្ណោះ ។

**មាត្រា ៣១៦.–** កាតព្វកិច្ចជាប្រាក់

១-ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ចជាប្រាក់ កូនបំណុលអាចសងជារូបិយវត្ថុផ្សេងៗ តាមការជ្រើសរើសរបស់ខ្លួនបាន ។ ប៉ុន្តែ ម្ចាស់បំណុល និង កូនបំណុលអាចកំណត់ការសងជារូបិយវត្ថុពិសេសបានដែរ ។

២-ក្នុងករណីដែលរូបិយវត្ថុពិសេសដែលបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច លែងជារូបិយវត្ថុស្របច្បាប់នៅពេលអនុវត្តកាតព្វកិច្ច កូនបំណុលអាចសងជារូបិយវត្ថុណាមួយផ្សេងទៀតបាន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការផ្ដល់នូវរូបិយវត្ថុបរទេស ត្រូវបានកំណត់ជាកម្មវត្ថុនៃកាតព្វកិច្ច ។

**មាត្រា ៣១៧.–** កាតព្វកិច្ចជារូបិយវត្ថុបរទេស

១-ក្នុងករណីដែលបានកំណត់ចំនួននៃកាតព្វកិច្ចជារូបិយវត្ថុបរទេស កូនបំណុលអាចសងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេស នៅកន្លែងដែលត្រូវអនុវត្តកាតព្វកិច្ចនោះនៅពេលកំណត់អនុវត្ត ។ ប៉ុន្តែ ប្រសិនបើមានការសន្យាពិសេសផ្សេងពីបញ្ញត្តិនេះ រវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តទៅតាមការសន្យាពិសេសនោះ ។

២-ក្នុងករណីដែលកូនបំណុលដែលមានការយឺតយ៉ាវក្នុងការអនុវត្ត សងជារូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលសង ដោយគិតទៅតាមអត្រាប្តូររូបិយប័ណ្ណបរទេសនៅពេលកំណត់អនុវត្ត ឬ នៅពេលដែលកូនបំណុលសងបាន ។ ប៉ុន្តែ ប្រសិនបើមានការសន្យាពិសេសផ្សេងពីបញ្ញត្តិនេះ រវាងម្ចាស់បំណុល និង កូនបំណុល ត្រូវអនុវត្តទៅតាមការសន្យាពិសេសនោះ ។

**មាត្រា ៣១៨.–** អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេ ត្រូវគិតអត្រាការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ ។

**មាត្រា ៣១៩.–** ការប្រាក់សមាស

ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពី ១ (មួយ) ឆ្នាំ ឡើងទៅ ហើយទោះបីជាម្ចាស់បំណុលបានដាស់តឿនឱ្យសងយ៉ាងណាក៏ដោយ ក៏កូនបំណុលមិនព្រមសងការប្រាក់នោះ ម្ចាស់បំណុលអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន ។

**មាត្រា ៣២០.–** កាតព្វកិច្ចអនិយ័ត

ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ត្រូវបានកំណត់ដោយការជ្រើសរើសក្នុងចំណោមការផ្តល់ច្រើនប្រភេទ កូនបំណុលត្រូវមានសិទ្ធិជ្រើសរើស ។ ប៉ុន្តែ ភាគីនៃកិច្ចសន្យាអាចឱ្យសិទ្ធិជ្រើសរើសនោះទៅម្ចាស់បំណុល ឬ តតិយជន តាមការកំណត់ផ្សេងបាន ។

## ជំពូកទី ១៤
## ការគ្រប់គ្រងដោយឈឺឆ្អាល

**មាត្រា ៧២៩.-** ករណីយកិច្ចគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ ការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល ។ បុគ្គលដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

២-អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវគ្រប់គ្រងដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេ ដើម្បីផលប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការនោះ ។

៣-ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានដឹងអំពីឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើអាចដឹងអំពីឆន្ទៈនោះបាន ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ ។

**មាត្រា ៧៣០.-** ការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ដើម្បីជៀសវាងគ្រោះថ្នាក់ នៅក្នុងសភាពបន្ទាន់ ចំពោះរូបកាយសាមីខ្លួន កិត្តិយស ឬ ទ្រព្យសម្បត្តិ លុះត្រាតែគ្មានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ តែប៉ុណ្ណោះទេ ទើបអ្នកគ្រប់គ្រងដោយឈឺឆ្អាល ពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាត ដែលកើតឡើងដោយសារការគ្រប់គ្រងនោះ ។

**មាត្រា ៧៣១.-** ករណីយកិច្ចជូនដំណឹងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ក្នុងករណីដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះពុំចាំបាច់ឡើយ ។

**មាត្រា ៧៣២.–** ករណីយកិច្ចបន្តការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះ រហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន ។ ប៉ុន្តែ ប្រសិនបើការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើច្បាស់ថានឹងធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន ត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ។

**មាត្រា ៧៣៣.–** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍ របស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល ។

**មាត្រា ៧៣៤.–** សិទ្ធិទាមទារសងសោហ៊ុយវិញរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ប្រសិនបើបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬ ចំណាយបង្កើនតម្លៃ ដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារ ចំពោះសាមីខ្លួនឱ្យសងវិញបាន ។

២-បញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានទទួលបន្ទុកកាតព្វកិច្ចដែលជាសោហ៊ុយដែលបានបង្កើនតម្លៃ ដើម្បីសាមីខ្លួន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្ត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ។

**មាត្រា ៧៣៥.–** សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវ-

កម្មរបស់អ្នកគ្រប់គ្រង ចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាលនោះបាន ។

## ជំពូកទី ១៥
## សេចក្តីចម្រើនដោយឥតហេតុ

**មាត្រា ៧៣៦.-** ល័ក្ខខ័ណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ

១-ទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឱ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ត្រឹមកម្រិតដែលផលប្រយោជន៍នោះមាន ។

២-នៅក្នុងករណីដែលបានទទួលការផ្តល់តាវកាលិកពីអ្នកដទៃ ដោយយោលតាមកិច្ចសន្យា ប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬ ត្រូវបានបាត់បង់អានុភាព បុគ្គលដែលបានទទួលការផ្តល់តាវកាលិកនោះ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ ដែលខ្លួនទទួលបានដោយសារការផ្តល់តាវកាលិកនោះ ឱ្យទៅអ្នកដទៃដែលបានផ្តល់តាវកាលិកនោះវិញ ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

**មាត្រា ៧៣៧.-** ករណីយកិច្ចសងរបស់អ្នកទទួលផលប្រយោជន៍ដោយគំនិតទុច្ចរិត

១-បុគ្គលដែលបានទទួលផលប្រយោជន៍ ដូចបានកំណត់នៅក្នុងមាត្រា ៧៣៦ (ល័ក្ខខ័ណ្ឌ និង អានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ) ខាងលើនេះ ក្នុងករណីដែលបានដឹងថាគ្មានមូលហេតុលើផ្លូវច្បាប់ ឬ ដឹងថាកិច្ចសន្យានោះពុំមានអានុភាព បុគ្គលដែលបានទទួលផលប្រយោជន៍ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលមាននៅពេលដែលបានដឹង និង ការប្រាក់ គិតចាប់ពីពេលដែលបានដឹង រហូតដល់ពេលសង ។

២-បើបុគ្គលដែលបានទទួលផលប្រយោជន៍ មានចេតនា ឬ កំហុស ចំពោះអានុភាពនៃកិច្ចសន្យាដែលត្រូវបានបាត់បង់ បុគ្គលដែលបានទទួលផលប្រយោជន៍នោះ

មានករណីយកិច្ចត្រូវសងផលប្រយោជន៍នោះ ដោយភ្ជាប់ជាមួយនឹងការប្រាក់ ដូចគ្នានឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះដែរ ។

៣-បើបុគ្គលដែលត្រូវបានបាត់បង់ផលប្រយោជន៍ ទទួលការខូចខាត ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បុគ្គលដែលបានទទួលផលប្រយោជន៍ត្រូវទទួលខុសត្រូវលើសំណងនៃការខូចខាតនោះ ។

**មាត្រា ៧៣៨.–** ការសងដោយគ្មានកាតព្វកិច្ច

បុគ្គលដែលបានសងកាតព្វកិច្ចដែលខ្លួនគ្មាន អាចទាមទារឱ្យសងតាវកាលិកនៃការសងនោះ មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលដឹងថា គ្មានកាតព្វកិច្ចនៅពេលសងនោះទេ បុគ្គលដែលបានសង មិនអាចទាមទារឱ្យសងតាវកាលិកនៃការសងនោះ មកវិញបានឡើយ ។

**មាត្រា ៧៣៩.–** ការសងនៅមុនកំណត់ពេល

ក្នុងករណីដែលបានផ្តល់តាវកាលិកនៃការសង ចំពោះកាតព្វកិច្ចដែលមិនទាន់ដល់កំណត់ពេលសងនៅឡើយ កូនបំណុលពុំអាចទាមទារឱ្យសងតាវកាលិកដែលត្រូវបានផ្តល់នោះ មកវិញបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលបានសង ដោយពុំបានដឹងអំពីកំណត់ពេលសងដែលមិនទាន់មកដល់នៅឡើយ ម្ចាស់បំណុលមានករណីយកិច្ចត្រូវសងផលប្រយោជន៍ ដែលបានទទួលដោយសារការសងនៅមុនកំណត់ពេលនោះ ។

**មាត្រា ៧៤០.–** ការសងកាតព្វកិច្ចរបស់អ្នកដទៃ

១-ក្នុងករណីដែលបុគ្គលក្រៅពីកូនបំណុល បានផ្តល់តាវកាលិកនៃការសង ដោយភាន់ច្រឡំអំពីកាតព្វកិច្ចរបស់អ្នកដទៃថាជាកាតព្វកិច្ចរបស់ខ្លួន អាចទាមទារឱ្យសងតាវកាលិកនោះ មកវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលម្ចាស់បំណុលពុំបានដឹងថា ការផ្តល់តាវកាលិកនោះ បណ្តាលមកពីការភាន់ច្រឡំរបស់បុគ្គលដែលបានផ្តល់តាវកាលិកនៃការសងនោះទេ ហើយបានបំផ្លាញលិខិតលាយល័ក្ខណ៍អក្សរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុល ឬបានបោះបង់ប្រាតិភោគចោល ដោយបានជឿជាក់ថាជាការសងដែលមានសុពលភាព

បុគ្គលដែលបានផ្តល់តាវកាលិកនោះ មិនអាចទាមទារឱ្យសងតាវកាលិកនោះ មកវិញបានឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងការអនុវត្តសិទ្ធិទាមទារសំណងរបស់បុគ្គលដែលបានផ្តល់តាវកាលិកនៃការសង ចំពោះកូនបំណុលឡើយ ។

**មាត្រា ៧៤១.–** ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

នៅក្នុងជំពូកទី ១៥ (សេចក្តីចម្រើនដោយឥតហេតុ) នេះ ក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតផលប្រយោជន៍ ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងនោះ ពុំត្រូវបានអនុញ្ញាតឡើយ ។

## ជំពូកទី ១៦
## អំពើអនីត្យានុកូល

**មាត្រា ៧៤២.–** និយមន័យនៃកំហុសចេតនា និង អចេតនា

នៅក្នុងជំពូកទី ១៦ (អំពើអនីត្យានុកូល) នេះ អំពើដោយមានកំហុសចេតនា ឬ អចេតនា សំដៅទៅលើ អំពើដែលត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :

ក-ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ ។

ខ-ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។

**មាត្រា ៧៤៣.–** ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យា-នុកូលទូទៅ

១-បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលកើតឡើងដោយអំពើនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ ។

៣-ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និង ការកើតឡើងនៃការខូចខាត និង ការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត ។

**មាត្រា ៧៤៤.–** សំណងនៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

បុគ្គលដែលទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រា ៧៤៣ (ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ) ខាងលើនេះ ត្រូវសងការខូចខាតចំពោះអ្វីដែលមិនមែនជាទ្រព្យសម្បត្តិផងដែរ ។

**មាត្រា ៧៤៥.–** អសមត្ថភាពក្នុងការទទួលខុសត្រូវ

១-ជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ ។

២-បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលស្ថានភាពនោះបណ្តាលមក ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ។

# ឧបសម្ព័ន្ធទី២

**មាត្រា ៤៩៩.–** តាវកាលិកដើម្បីបំពេញនូវសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ចំពោះតាវកាលិកដែលត្រូវបានផ្តល់ ដើម្បីបំពេញនូវសិទ្ធិលើបំណុលដែលផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ទោះបីជាអ្នកនោះផ្តល់តាវកាលិក ដោយមិនបានដឹងថា ផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ដោយ ក៏អ្នកនោះមិនអាចទាមទារឱ្យសងតាវកាលិកនោះវិញឡើយ ។

**មាត្រា ៥០០.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ មានអំឡុងពេល ១០ (ដប់) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ។ បញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ ។

## ជំពូកទី ៩
## អនុប្បទានសិទ្ធិលើបំណុល ការទទួលភារពកិច្ច

### ផ្នែកទី ១
### អនុប្បទានសិទ្ធិលើបំណុល

**មាត្រា ៥០១.–** ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន

១-សិទ្ធិលើបំណុល អាចធ្វើអនុប្បទានទៅឱ្យអ្នកផ្សេងបាន លើកលែងតែក្នុងករណីដែលសិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទានបាន ។ ក្នុងករណីនេះ អនុប្បទានិកនឹងក្លាយជាម្ចាស់បំណុលថ្មី ។

២-ទោះបីជាសិទ្ធិលើបំណុលមានលក្ខណៈអាចធ្វើអនុប្បទានបានក៏ដោយ ក៏គូភាគីអាចហាមមិនឱ្យធ្វើអនុប្បទាន ដោយការបង្ហាញឆន្ទៈបានដែរ ។

៣-ការបង្ហាញឆន្ទៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជនដែលមិនបានដឹងអំពីការបង្ហាញឆន្ទៈនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះមានកំហុសដ៏ធ្ងន់ធ្ងរ ។

**មាត្រា ៥០២.-** ការបង្កើតអនុប្បទានសិទ្ធិលើបំណុល

អនុប្បទានសិទ្ធិលើបំណុល ត្រូវមានអានុភាព តែដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុលដែលមានបំណងធ្វើអនុប្បទានសិទ្ធិលើបំណុល និង អនុប្បទានិកប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីយកអនុប្បទានសិទ្ធិលើបំណុលនេះទៅតតាំង ចំពោះកូនបំណុល និង តតិយជន ត្រូវមានល័ក្ខខ័ណ្ឌតតាំងដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ខាងក្រោមនេះ ។

**មាត្រា ៥០៣.-** ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មិនអាចតតាំងចំពោះកូនបំណុល ឬ តតិយជនផ្សេងទៀតបានឡើយ បើអនុប្បទាយីមិនបានជូនដំណឹងទៅកូនបំណុល ឬ កូនបំណុលមិនបានយល់ព្រម ចំពោះអនុប្បទាយី ឬ អនុប្បទានិក ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងនឹងតតិយជន ក្រៅពីកូនបំណុលបានឡើយ បើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាពរ ។

**មាត្រា ៥០៤.-** អាទិភាពនៃអនុប្បទានសិទ្ធិលើបំណុល ជាច្រើនដង

១-ក្នុងករណីដែលធ្វើអនុប្បទានសិទ្ធិលើបំណុលតែមួយ ត្រូវបានធ្វើឡើងជាច្រើនដង អាទិភាពនៃអនុប្បទាននោះ ត្រូវកំណត់ទៅតាមលំដាប់នៃពេលដែលការជូនដំណឹងដែលធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្លាពរ បានដល់កូនបំណុល ឬ ពេលដែលកូនបំណុលបានយល់ព្រមដោយលិខិតដែលមានកាលបរិច្ឆេទស្លាពរ ។ ក្នុងករណី

នេះ កូនបំណុលត្រូវសងបំណុលទៅអនុប្បទានិកដែលមានអាទិភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើមិនអាចកំណត់លំដាប់នៃពេលដែលការជូនដំណឹងបានដល់ ឬ ពេលដែលកូនបំណុលបានយល់ព្រមទេ ត្រូវចាត់ទុកថា ការជូនដំណឹងនីមួយៗបានដល់កូនបំណុល នៅពេលជាមួយគ្នា ឬ កូនបំណុលបានយល់ព្រមនៅពេលជាមួយគ្នា ។ ក្នុងករណីនេះ អនុប្បទានិកនីមួយៗអាចទាមទារឱ្យកូនបំណុលសងចំពោះសិទ្ធិលើបំណុលទាំងអស់ដែលខ្លួនបានទទួលដោយអនុប្បទាន ។ ពេលដែលកូនបំណុលបានសងចំពោះម្ចាស់បំណុលណាម្នាក់ កាតព្វកិច្ចត្រូវរលត់ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ កូនបំណុលអាចរួចផុតពីកាតព្វកិច្ចបាន ដោយតម្កល់នូវវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ចនោះ ។

**មាត្រា ៥០៥.–** អានុភាពនៃការជូនដំណឹង និង ការយល់ព្រម

១-ប្រសិនបើកូនបំណុលធ្វើការយល់ព្រមដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ដោយគ្មានការតវ៉ា ទោះបីជាខ្លួនមានហេតុដែលអាចតតាំងចំពោះអនុប្បទាយីក៏ដោយ ក៏កូនបំណុលមិនអាចយកហេតុនោះតតាំងចំពោះអនុប្បទាយីបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវរារាំងក្នុងការយកវត្ថុវិញ បើកូនបំណុលប្រគល់វត្ថុណាឱ្យអនុប្បទាយីដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន ឬ ក្នុងការចាត់ទុកថា កាតព្វកិច្ចមិនកើតឡើង បើកូនបំណុលទទួលបន្ទុកនូវកាតព្វកិច្ចចំពោះអនុប្បទាយី ដើម្បីរំលត់កាតព្វកិច្ចរបស់ខ្លួន ។

២-ប្រសិនបើអនុប្បទាយីបានជូនដំណឹងអំពីអនុប្បទានតែប៉ុណ្ណោះ កូនបំណុលអាចយកហេតុដែលកើតឡើងចំពោះអនុប្បទាយី រហូតដល់ពេលខ្លួនទទួលដំណឹងនោះទៅតតាំងចំពោះអនុប្បទានិកបាន ។

**មាត្រា ៥០៦.–** អនុប្បទានសិទ្ធិលើបំណុលដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ

បញ្ញត្តិនៃច្បាប់ពិសេសត្រូវយកមកអនុវត្ត ចំពោះអនុប្បទានសិទ្ធិលើបំណុលដែលកំណត់ការបញ្ជា ឬ សិទ្ធិលើបំណុលផ្សេងដែលត្រូវបានបញ្ជាក់ដោយមូលប័ត្រ ។

## ផ្នែកទី ២
## ការទទួលកាតព្វកិច្ច

**មាត្រា ៥០៧.–** ភាពដែលអាចទទួលកាតព្វកិច្ចបាន

១-ចំពោះកាតព្វកិច្ចដែលអាចអនុវត្តបានដោយតតិយជនក្រៅពីកូនបំណុល តតិយជនអាចទទួលកាតព្វកិច្ចនោះបាន ។

២-គូភាគីអាចហាមមិនឱ្យតតិយជនទទួលកាតព្វកិច្ច ដោយការបង្ហាញឆន្ទៈបាន ។

**មាត្រា ៥០៨.–** ការបង្កើតនូវការទទួលកាតព្វកិច្ច

ការទទួលកាតព្វកិច្ច ត្រូវមានអានុភាព ដោយការព្រមព្រៀងគ្នារវាងកូនបំណុល និង អ្នកទទួល ឬ ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង អ្នកទទួល ។

**មាត្រា ៥០៩.–** សិទ្ធិរបស់ម្ចាស់បំណុល

១-ទោះបីជាមានការទទួលកាតព្វកិច្ចក៏ដោយ ក៏ម្ចាស់បំណុលមិនបាត់បង់នូវសិទ្ធិចំពោះកូនបំណុលដែរ ។ ក្នុងករណីនេះ កូនបំណុល និង អ្នកទទួលកាតព្វកិច្ច ត្រូវទទួលបន្ទុកកាតព្វកិច្ចដោយសាមគ្គីភាព ចំពោះម្ចាស់បំណុល ។

២-អ្នកទទួលកាតព្វកិច្ច អាចឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ច ដោយទទួលការយល់ព្រមពីម្ចាស់បំណុលបាន ។

**មាត្រា ៥១០.–** ការតវ៉ា ក្នុងការទទួលកាតព្វកិច្ច

ក្នុងករណីដែលការទទួលកាតព្វកិច្ចត្រូវបានធ្វើឡើង អ្នកទទួលនេះអាចយកហេតុដែលកូនបំណុលធ្លាប់មានរហូតដល់ពេលដែលការទទួលកាតព្វកិច្ចនោះត្រូវបានធ្វើឡើងទៅតតាំងចំពោះម្ចាស់បំណុលបាន ។

**មាត្រា ៥១១.–** ការទទួលការអនុវត្តកាតព្វកិច្ច

ប្រសិនបើអ្នកទទួលមិនទទួលកាតព្វកិច្ច តែបានទទួលគ្រាន់តែការអនុវត្តកាតព្វកិច្ចតែប៉ុណ្ណោះ តាមការព្រមព្រៀងគ្នារវាងកូនបំណុល និង អ្នកទទួល នោះម្ចាស់បំណុលមិន

អាចទាមទារឱ្យអ្នកទទួលនោះ អនុវត្តកាតព្វកិច្ចបានឡើយ ។

## ផ្នែកទី ៣
## អនុប្បទានឋានៈក្នុងកិច្ចសន្យា

**មាត្រា ៥១២.–** អនុប្បទានឋានៈក្នុងកិច្ចសន្យា

១-បុគ្គលដែលបានធ្វើកិច្ចសន្យាជាមួយនឹងបុគ្គលផ្សេង អាចធ្វើអនុប្បទានឋានៈរបស់ខ្លួនដែលមាននៅក្នុងកិច្ចសន្យានោះ ទៅឱ្យតតិយជនបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលអនុប្បទានឋានៈនោះ មិនអាចធ្វើបាន តាមលក្ខណៈនៃកិច្ចសន្យា ។ ម្យ៉ាងទៀត គូភាគីនៃកិច្ចសន្យា អាចហាមមិនឱ្យធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យានោះ ដោយការព្រមព្រៀងគ្នាបាន ។ ក្នុងករណីនេះ បញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៥០១ (ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

២-ក្នុងករណីដែលអនុប្បទានឋានៈក្នុងកិច្ចសន្យា នឹងធ្វើឱ្យភាគីម្ខាងទៀតនៃកិច្ចសន្យានោះខូចប្រយោជន៍ធ្ងន់ធ្ងរ បុគ្គលដែលមានបំណងធ្វើអនុប្បទានឋានៈក្នុងកិច្ចសន្យានោះ ត្រូវទទួលការយល់ព្រមអំពីអនុប្បទាននោះ ពីភាគីម្ខាងទៀតនៃកិច្ចសន្យានោះ ។

**មាត្រា ៥១៣.–** ការបង្កើតអនុប្បទានឋានៈក្នុងកិច្ចសន្យា

អនុប្បទានឋានៈក្នុងកិច្ចសន្យា ត្រូវមានអានុភាព តែដោយការព្រមព្រៀងគ្នារវាងភាគីម្ខាងនៃកិច្ចសន្យាដែលមានបំណងធ្វើអនុប្បទានឋានៈនោះ និង អនុប្បទានិកប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីតតាំងចំពោះភាគីម្ខាងទៀតនៃកិច្ចសន្យា និង តតិយជន អនុប្បទាននេះត្រូវមានល័ក្ខខ័ណ្ឌតតាំងដែលបានកំណត់ក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) នៃក្រមនេះ ។

**មាត្រា ៥១៤.–** អានុភាពនៃអនុប្បទានឋានៈក្នុងកិច្ចសន្យា

ក្នុងករណីដែលអនុប្បទានឋានៈក្នុងកិច្ចសន្យាត្រូវបានធ្វើឡើង សិទ្ធិ និង កាតព្វកិច្ច

ទាំងអស់ដែលអនុប្បទាយីធ្លាប់មាន ត្រូវផ្ទេរទៅអនុប្បទានិក លើកលែងតែមានការបង្ហាញឆន្ទៈពិសេស ។ ក្នុងករណីនេះ បញ្ញត្តិនៃមាត្រា ៥០៥ (អានុភាពនៃការជូនដំណឹង និងការយល់ព្រម) ស្តីពីអនុប្បទានសិទ្ធិលើបំណុល និង មាត្រា ៥១០ (ការតវ៉ា ក្នុងការទទួលកាតព្វកិច្ច) ស្តីពីការទទួលកាតព្វកិច្ច នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

# ឧបសម្ព័ន្ធទី៣

# ជំពូកទី ៧
# ការរលត់កាតព្វកិច្ច

**មាត្រា ៤៣៣.–** មូលហេតុនៃការរលត់កាតព្វកិច្ច

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ :

ក-ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ព្យាកុលភាព ដូចបានកំណត់ពីផ្នែកទី ១ (ការសង) ដល់ផ្នែកទី ៥ (ព្យាកុលភាព) នៃជំពូកទី ៧ នេះ ។

ខ-អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយគ្មានកំហុសរបស់កូនបំណុល ដូចបានកំណត់ក្នុងជំពូកទី ៥ (ការទទួលបន្ទុកហានិភ័យ) នៃគន្ថីនេះ ។

គ-ការបំពេញល័ក្ខខ័ណ្ឌនៃការរំលាយដូចបានកំណត់ក្នុងផ្នែកទី ៣ (ល័ក្ខខ័ណ្ឌ កំណត់ពេល និង អំឡុងពេល) នៃជំពូកទី ១ ឬ ការរំលាយកិច្ចសន្យាដូចបានកំណត់ក្នុងផ្នែកទី ៤ (ការរំលាយកិច្ចសន្យា) នៃជំពូកទី ៤ នៃគន្ថីនេះ ។

ឃ-ការផុតអាជ្ញាយុកាលនៃការរលត់ដូចបានកំណត់ក្នុងជំពូកទី ៨ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) នៃគន្ថីនេះ ។

ង-ការអនុវត្តសិទ្ធិលុបចោលតាមបញ្ញត្តិនៃផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ជំពូកទី ២ នៃគន្ថីនេះ។

## ផ្នែកទី ១
## ការសង

### កថាភាគទី ១
### គោលការណ៍ទូទៅស្តីពីការសង

**មាត្រា ៤៣៤.–** អ្នកសង

១-ការសងអាចធ្វើឡើងដោយកូនបំណុលក៏បាន ដោយតតិយជនក៏បាន ។

២-ក្នុងករណីដែលគោលបំណងនៃកាតព្វកិច្ចមិនអាចសម្រេចដោយការសងរបស់តតិយជនបានទេ តតិយជននោះមិនអាចសងបានឡើយ លើកលែងតែមានការយល់ព្រម

## ផ្នែកទី ២
## ការទូទាត់

**មាត្រា ៤៦៤.-** លក្ខខណ្ឌនៃការទូទាត់ដែលច្បាប់បានកំណត់ និង កិច្ចសន្យាទូទាត់

១-ក្នុងករណីដែលបុគ្គលពីរនាក់ទទួលបន្ទុកនូវកាតព្វកិច្ចដែលមានគោលបំណងប្រភេទដូចគ្នាចំពោះគ្នាទៅវិញទៅមក ប្រសិនបើកាតព្វកិច្ចទាំងពីរត្រូវដល់ពេលកំណត់សងហើយ ភាគីម្ខាងអាចរំលត់កាតព្វកិច្ចទៅវិញទៅមក ដោយយកចំនួនប្រាក់ស្មើគ្នា ដោយបង្ហាញឆន្ទៈឯកតោភាគី ។

២-គូភាគីអាចធ្វើកិច្ចសន្យាទូទាត់ដែលរំលត់កាតព្វកិច្ចទៅវិញទៅមកបាន ទោះបីជាកាតព្វកិច្ចទាំងពីរនោះគ្មានគោលបំណងប្រភេទដូចគ្នាទៅវិញទៅមកក៏ដោយ ។ ប៉ុន្តែគូភាគីមិនអាចធ្វើឱ្យខូចផលប្រយោជន៍របស់តតិយជនបានឡើយ ។

**មាត្រា ៤៦៥.-** វិធីទូទាត់

១-ការទូទាត់ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈទូទាត់ ពីភាគីម្ខាង ទៅភាគីម្ខាងទៀត ។

២-ការបង្ហាញឆន្ទៈទូទាត់ អាចដាក់លក្ខខណ្ឌបង្អង់បាន តែមិនអាចដាក់លក្ខខណ្ឌរំលាយ ឬ កំណត់ពេលបានឡើយ ។

**មាត្រា ៤៦៦.-** ពេលដែលបង្កើតអានុភាពនៃការទូទាត់

ក្នុងករណីដែលលក្ខខណ្ឌនៃការទូទាត់ត្រូវបានបំពេញ ហើយនៅពេលឆន្ទៈទូទាត់ត្រូវបានបង្ហាញ អានុភាពដែលរំលត់កាតព្វកិច្ចដោយការទូទាត់ ត្រូវកើតឡើងដោយមានប្រតិសកម្ម តាំងពីពេលដែលកាតព្វកិច្ចទាំងពីរនោះសមស្របទៅនឹងការទូទាត់ ។

**មាត្រា ៤៦៧.-** ការកម្រិតចំពោះការទូទាត់

១-ក្នុងករណីដែលលក្ខណៈនៃកាតព្វកិច្ចណាមួយ ឬ ទាំងពីរ មិនអនុញ្ញាតឱ្យធ្វើការទូទាត់ទេ គូភាគីមិនអាចទូទាត់បានទេ ។

# ជំពូកទី ៥
# ការទទួលបន្ទុកហានិភ័យ

**មាត្រា ៤១៥.–** ការរលត់កាតព្វកិច្ចដោយអលទ្ធភាព

បើការអនុវត្តកាតព្វកិច្ចក្លាយជាអលទ្ធភាព ហើយកូនបំណុលគ្មានកំហុសចំពោះអលទ្ធភាពនោះ កាតព្វកិច្ចត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារតាវកាលិកបានទេ ។

**មាត្រា ៤១៦.–** ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់

១-ក្នុងកិច្ចសន្យាអញ្ញមញ្ញដែលមានអត្ថន័យផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ ក្នុងករណីដែលវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កូនបំណុលត្រូវទទួលបន្ទុកហានិភ័យនោះ ហើយមិនអាចទាមទារតាវកាលិកតប ពីម្ចាស់បំណុលបានទេ ។

២-លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា ហានិភ័យដោយសារការបាត់បង់ ឬ ខូចខាតវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវផ្ទេរទៅម្ចាស់បំណុលនៅពេលណាមួយក្នុងចំណោមពេលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ពេលដែលប្រគល់វត្ថុជាកម្មវត្ថុទៅម្ចាស់បំណុល ឬ ពេលដែលចុះបញ្ជីផ្ទេរអចលនវត្ថុ ឬ ពេលផ្សេងទៀតដែលយល់ឃើញថា ការគ្រប់គ្រងជាក់ស្តែងលើវត្ថុជាកម្មវត្ថុត្រូវបានផ្ទេរទៅម្ចាស់បំណុល ។

ខ-ពេលដែលកូនបំណុលបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចត្រឹមត្រូវ ។

គ-ពេលដែលម្ចាស់បំណុលប្រកែកមិនព្រមទទួលការអនុវត្តរបស់កូនបំណុលដោយគ្មានមូលហេតុត្រឹមត្រូវ ។

**មាត្រា ៤១៧.–** ការទទួលបន្ទុកហានិភ័យចំពោះសិទ្ធិផ្សេងទៀត

បញ្ញត្តិនៃមាត្រា ៤១៦ (ការទទួលបន្ទុកហានិភ័យក្នុងកិច្ចសន្យាផ្ទេរកម្មសិទ្ធិលើវត្ថុ

ឬ ឱ្យរំលាយកិច្ចសន្យាទេ ។ ក្នុងករណីដែលម្ចាស់បំណុលរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាតដែលជាការជំនួសកម្មវត្ថុនៃកិច្ចសន្យា ចំនួនទឹកប្រាក់នៃសំណងដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នាដោយគិតជាមុន អំពីការខូចខាតដែលកើតឡើងដោយការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចនោះ មិនត្រូវចងគូភាគីទេ ។

៥-ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង ។

**មាត្រា ៤០៤.-** គោលការណ៍នៃការសងការខូចខាតជាប្រាក់

ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីទាំងសងខាងបានកំណត់ផ្សេងពីនេះដោយការសន្យាពិសេស ។

**មាត្រា ៤០៥.-** ឧបាទេសកម្មនៃអ្នកសង

ប្រសិនបើម្ចាស់បំណុលបានទទួលនូវសំណងនៃការខូចខាតដោយការសងតម្លៃនៃវត្ថុ ឬ សិទ្ធិដែលជាអត្ថន័យនៃសិទ្ធិលើបំណុល កូនបំណុលត្រូវទទួលឋានៈដែលម្ចាស់បំណុលធ្លាប់មានចំពោះវត្ថុ ឬ សិទ្ធិនោះ ដោយស្វ័យប្រវត្តិ ។

**មាត្រា ៤០៦.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណង

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះកើតឡើង ។

## ផ្នែកទី ៤
## ការរំលាយកិច្ចសន្យា

**មាត្រា ៤០៧.-** ការរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច

ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

## ផ្នែកទី ៥
## ព្យាកុលភាព

**មាត្រា ៤៧៩.–** ព្យាកុលភាពរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ច

១-ក្នុងករណីដែលសិទ្ធិលើបំណុល និង កាតព្វកិច្ចធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិលើបំណុល និង កាតព្វកិច្ចនោះត្រូវរលត់ដោយព្យាកុលភាព ។

២-សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន សិទ្ធិនោះមិនត្រូវរលត់ដោយព្យាកុលភាពឡើយ ។

## ជំពូកទី ៨
## អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

**មាត្រា ៤៨០.–** និយមន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ ។

**មាត្រា ៤៨១.–** ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

**មាត្រា ៤៨២.–** អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។

**មាត្រា ៤៨៣.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលមានអំឡុងពេលខ្លី

ចំពោះសិទ្ធិលើបំណុលអំពីថ្លៃទំនិញដែលផលិតករ ឬ ពាណិជ្ជកររលក់ទៅឱ្យអ្នក

ឬ តាមវិធីផ្សេងទៀត អាចដកបានតែតាមវិធីដូចគ្នានឹងសំណើនោះ ។

## ផ្នែកទី ២
## វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.–** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី ២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី ៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ :

ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ។

ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។

គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។

**មាត្រា ៣៤៦.–** ការភាន់ច្រឡំ

១-ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២-ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

ខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល នោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ ។

## ផ្នែកទី ៣
## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤
## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិត្តូបត្ថម្ភ ។

### កថាភាគទី ១
### អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

អនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ហើយទោះបីជាទុកផ្នែកផ្សេងទៀត ក៏មិនធ្វើឱ្យខូចសេចក្តីសង្ឃឹមសមហេតុសមផលរបស់គូភាគីទេ នោះមានតែចំណុចដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អតែប៉ុណ្ណោះទេ ដែលត្រូវទុកជាមោឃៈ ។

**មាត្រា ៣៥៥.-** អលទ្ធភាពតាំងពីដំបូង

១-ទោះបីជាអត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចបានតាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះមិនត្រូវបានចាត់ទុកជាមោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងភាគីក្នុងការលុបចោលនូវកិច្ចសន្យាដោយយកមូលហេតុនៃការភាន់ច្រឡំឡើយ ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការភាន់ច្រឡំត្រូវបានបំពេញ ។

២-ក្នុងករណីដែលភាគីដែលគួរតែអាចដឹងថា អត្ថន័យនៃកិច្ចសន្យាមិនអាចសម្រេចតាំងពីដំបូងបាន នាំឱ្យមានការខូចខាតដល់ភាគីម្ខាងទៀតដោយសារការបង្កើតកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់ភាគីម្ខាងទៀត ដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៣៩៨ (ល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) នៃក្រមនេះ ។

## ផ្នែកទី ៣
## មោឃភាព និង ការលុបចោល

**មាត្រា ៣៥៦.-** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ក្នុងផ្នែកទី ៣ (មោឃភាព និង ការលុបចោល) នេះ សំដៅទៅលើកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ។

ចប់